ទស្សនាវដ្តីដែលចេញផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការ



- សេចក្តីកែតម្រូវរបស់ព្រះមហាក្សត្រ
- យុត្តិធម៌សម្រាប់កម្ពុជា

[illegible]

លេខ៣៧ ខែ មករា ឆ្នាំ២០០៣

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៧ ខែមករា ឆ្នាំ២០០៣


## មាតិកា


◆ សំបុត្រ៖ សៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់.................... ១

**ផ្នែកឯកសារ**

◆ សម្រេចកម្មេចតាមខ្សែបណ្តាញ..........................................២

◆ សេចក្តីប្រកាសរបស់ អៀង សារី......................................៤

◆ ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម..........................................៦

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស.........................................១២

◆ ប្រវត្តិរូប តាម៉ុក........................................................ ១៣

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្មេចនៅមន្ទីរស-២១..........១៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ភ្នែកងងឹតតែចិត្តនៅចាំ.................................................. ១៦

◆ សៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់.............................. ២០

◆ ជនជាតិចិននៅកម្ពុជា.................................................. ២៨

◆ បាត់ខ្លួនជារៀងរហូត.................................................. ៣៤

**ផ្នែកច្បាប់**

◆ សិទ្ធិរបស់ជនរងគ្រោះ.................................................. ៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ គម្រោងការពិសោធន៍សំខាន់ៗដែលអាចជាជំនួយដល់............ ៤១

◆ សេចក្តីកែតម្រូវរបស់ព្រះករុណា សម្តេចព្រះ នរោត្តម សីហនុ.. ៤៤

◆ យុត្តិធម៌សម្រាប់កម្ពុជា.................................................. ៥៤

◆ មេធាវី តាម៉ុក ប្រកាស..................................................៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ អ៊ីដែលប៉ាត្រូវការគឺ សន្តិភាព.......................................... ៥៨




លោកយាយ ចាន់ យឹម


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** យិន នាន, វ៉ាន់ថាន់ ពៅដារ៉ា, គឹម កែវកន្និដ្ឋា, ដេង ពង្សរ៉ាស៊ី, ឆេង វ៉េង, ច័ន្ទ សម្បត្តិ, ដាវីដ សែហ្វហ៊័រ
**អ្នកនិពន្ធនិងស្រាវជ្រាវ:** លី សុផល, សើ សាយប្រាណា **ជំនួយការនិពន្ធនាយក:** សាន់ កល្យាណ **និពន្ធនាយករង:** សួ ប៊ុនស៊ូ
**អ្នកបកប្រែ:** អេង កុកថាយ **និពន្ធនាយកខុទ្ទកាល:** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ:** មាស ប៊ុនថាន

*សំបុត្រ:*

# សៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់

អាន់ ហ្វ្រែង កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩២៩ ក្នុងទីក្រុងហ្វ្រែងហ្វឺត ប្រទេសអាល្លឺម៉ង់ ។ ក្នុងឆ្នាំ១៩៣៣ បន្ទាប់ពីពួកណាហ្ស៊ី បានចាប់ផ្តើមធ្វើបាបនិងសម្លាប់ជនជាតិជ្វីហ្វ អាន់ ហ្វ្រែង និងគ្រួសាររបស់នាងបានទៅរស់នៅប្រទេសហុល្លង់ ។ នៅខែឧសភា ឆ្នាំ១៩៤០ ពួកណាហ្ស៊ីបានចូលកាន់កាប់ប្រទេសហុល្លង់ ហើយនៅឆ្នាំ១៩៤២ អាន់ ហ្វ្រែង និងគ្រួសាររបស់នាងបានបង្ខំចិត្តចូលលាក់ខ្លួននៅក្នុងបន្ទប់សម្ងាត់ខាងក្រោយការិយាល័យធ្វើការរបស់ឪពុកនាងក្នុងទីក្រុងអាមស្ទែដាម ។ អាន់ បានស្លាប់នៅក្នុងជំរំប្រមូលផ្តុំ ប៊ីជិន-ប៊ែលសិន នៅអំឡុងចុងខែកុម្ភៈ និងនៅដើមខែមីនា ឆ្នាំ១៩៤៥ គឺមានរយៈពេលប្រហែល៣ខែមុនថ្ងៃខួបកំណើតគម្រប់អាយុ១៦ឆ្នាំរបស់នាង ។



សៀវភៅកំណត់ហេតុរបស់ អាន់ ហ្វ្រែង បានផ្តល់សេរីភាពដល់នាងក្នុងការបរិយាយអំពីអ្វីដែលនាងគិតចូលចិត្ត និងស្អប់ និងជាមធ្យោបាយមួយសម្រាប់ឲ្យនាងបង្ហាញនូវទុក្ខវេទនារបស់ជនជាតិជ្វីហ្វ ក្រោមការគាបសង្កត់របស់ពួកណាហ្ស៊ី ។ សៀវភៅកំណត់ហេតុរបស់ អាន់ ហ្វ្រែង បង្ហាញនូវការស្លាប់បាត់បង់ជីវិតរបស់មនុស្សស្លូតត្រង់យ៉ាងឈឺចាប់បំផុតនៅក្នុងរបបដឹកនាំដ៏ឆ្កួតលីលាមួយ ។ សៀវភៅនេះអាចជួយធ្វើឲ្យយើងបានយល់អំពីលក្ខណៈធម្មជាតិនៃការមិនរើសអើងនិងការភ័យរន្ធត់នៃអំពើប្រល័យពូជសាសន៍ដូចកើតមានឡើងកន្លងមក ដែលគឺជាបទឧក្រិដ្ឋកម្មអន្តរជាតិដ៏ធ្ងន់ធ្ងរបំផុត ។ សៀវភៅកំណត់ហេតុរបស់ អាន់ ហ្វ្រែង អាចជាជំនួយមួយយ៉ាងសំខាន់សម្រាប់យើងទាំងអស់គ្នាក្នុងការថែរក្សានិងការចងចាំអតីតកាលនៃអំពើអមនុស្សធម៌ដ៏ព្រៃផ្សៃដែលមនុស្សលោកអាចធ្វើទៅរួច ។

លើសពីនេះទៅទៀត សៀវភៅនេះធ្វើឲ្យយើងដឹងថា យើងទាំងអស់គ្នាមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការពារមិនឲ្យអំពើប្រល័យពូជសាសន៍កើតមានឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

ការបកប្រែសៀវភៅកំណត់ហេតុនេះចាប់ផ្តើមឡើងនៅដើមនិទាឃរដូវឆ្នាំ២០០០ ក្រោមការជួយជ្រោមជ្រែងដោយផ្ទាល់ពីសំណាក់លោកស្រីឡាទីស្យា វ៉ាន់ដិន អាស្សឹម ជាអតីតឯកអគ្គរាជទូតហុល្លង់ប្រចាំនៅកម្ពុជា ។ មូលនិធិបោះពុម្ពផ្សាយសៀវភៅនេះឧបត្ថម្ភដោយស្ថានទូតហុល្លង់ប្រចាំនៅទីក្រុងបាងកក ឆ្នាំ២០០២ ។

**ឆាំង យុ**

# សម្រេចកម្មេចតាមខ្សែបណ្តាញ


យ៉ាន់ ឃី

យ៉ាន់ ឃី ជាយុទ្ធជនធ្វើការនៅក្នុងក្រុមសួរចម្លើយនៅមន្ទីរ ស-២១ នៃរបបខ្មែរក្រហម ។ យ៉ាន់ ឃី បានត្រូវចាប់ខ្លួនតាមការឆ្លើយដាក់ជាខ្សែរយៈរបស់យុទ្ធមិត្ត ដែលអង្គការបានចាប់និងសួរចម្លើយ ។ យ៉ាន់ ឃី មានវាសនាមិនខុសពីមិត្តរួមការងារប៉ុន្មានឡើយ ករណីដូចជា ណុប នួន, អួយ ផនលី, ផិល គង់ ។ ក្រោយពីសួរចម្លើយរួច អ្នកទាំងនោះត្រូវអង្គការបញ្ជូនយកទៅសម្លាប់ចោលនៅទីវាលពិឃាតមនុស្សបឹងជើងឯក ។ (តាមរយៈបញ្ជីឈ្មោះអ្នកទោសកម្ទេចនៅមន្ទីរស-២១ បញ្ជាក់ថា អ្នកទោសទាំងបីនាក់នេះត្រូវបានកម្ទេចនៅក្នុងថ្ងៃតែមួយ គឺថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧) ។

មូលហេតុដែលនាំឲ្យមានការចាប់ខ្លួនរបស់ យ៉ាន់ ឃី គឺមានរៀបរាប់ដូចខាងក្រោមៈ

ត្រឹមឆ្នាំ១៩៧៧ យ៉ាន់ ឃី មានអាយុ១៩ឆ្នាំ ស្រុកកំណើតនៅភូមិលាវ ឃុំកោះធំស្រុក១៨ តំបន់២៥ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ទេស យ៉ាន់ ម្តាយឈ្មោះ ម៉ៅ សុន ។ យ៉ាន់ ឃី មានបងប្អូន៩នាក់គឺ បងប្រុសឈ្មោះ ទេស វី អាយុ២៤ ឆ្នាំ ធ្វើទាហាននៅភ្នំពេញ ។ បងស្រីឈ្មោះ ទេស សូត្រ អាយុ២២ ឆ្នាំ នៅជាមួយឪពុកម្តាយក្នុងសហករណ៍ភូមិលាវ ឃុំកោះធំ ស្រុក១៨ តំបន់២៥ ។ បងប្រុសឈ្មោះ ទេស ទ្រី អាយុ២០ ឆ្នាំ (ចូលបដិវត្តស្លាប់នៅឆ្នាំ១៩៧៧) ។ ប្អូនប្រុសឈ្មោះ ទេស លី អាយុ១៩ឆ្នាំ ចូលបដិវត្តគ្នាប់អង្គភាពមិនបាន ។ ប្អូនស្រីឈ្មោះ ទេស វឿន អាយុ១៥ឆ្នាំ ។ ប្អូនស្រីឈ្មោះ ទេស វើត អាយុ១៣ឆ្នាំ ។ ប្អូនប្រុសឈ្មោះ ទេស វ៉េត អាយុ១១ឆ្នាំ ប្អូនប្រុសឈ្មោះ ទេស រី អាយុ៨ឆ្នាំ ។ ប្អូនទាំងបួននាក់នេះរស់នៅជាមួយឪពុកម្តាយ ។

## ប្រវត្តិការងារ

យ៉ាន់ ឃី បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីអាយុ១៥ឆ្នាំមកម្ល៉េះ ។ នៅមុនឆ្នាំ១៩៧៥ យ៉ាន់ ឃី គឺជានីរសានៅក្នុងវរសេនាធំ២៧០ ។ យ៉ាន់ ឃី ធ្លាប់ធ្វើជានីរសាឲ្យសមមិត្ត ឆាន, សាវឿន (លេខាអនុសេនាធំ៦២ វរសេនាតូច១១៦) និងសមមិត្ត ឌី ។

ខែឧសភា ឆ្នាំ១៩៧៥ យ៉ាន់ ឃី និងមិត្តរួមការងារត្រូវអង្គការដកឲ្យទៅរៀនបច្ចេកទេសយោធានៅសាលាកងពល៧០៣ អស់រយៈពេលពីរខែ ។ ក្រោយពីបានបញ្ចប់វគ្គសិក្សាមក អង្គការបានចាត់តាំង យ៉ាន់ ឃី ធ្វើជាយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ខ្លួន ។

យ៉ាន់ ឃី បានសារភាពថា នៅដើមខែកុម្ភៈ ឆ្នាំដដែល ខ្លួនបានទទួលការបញ្ចុះបញ្ចូលឲ្យក្បត់ពីយុទ្ធជនម្នាក់ឈ្មោះ ណុប នួន (អ្នកសួរចម្លើយនៅក្រុមស្លូត) ។ នៅពេលជួប យ៉ាន់ ឃី ម្តងៗ ណុប នួន តែងតែលើកឡើងអំពីសភាពការណ៍របស់ខ្មាំងនៅភូមិឧត្តរថា មនុស្សក្បត់មានតាំងពីគណៈឃុំ គណៈតំបន់ គណៈភាគ (ឈ្មោះ ឃួន, ស្រេង) រហូតដល់ថ្នាក់កងពល (ឈ្មោះ អឿន, វឿន, សួង) និងនៅតាមតំបន់ ដើម្បីលើកទឹកចិត្ត យ៉ាន់ ឃី និងបញ្ចុះបញ្ចូល យ៉ាន់ ឃី ឲ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ ក្រៅពី ណុប នួន, យ៉ាន់ ឃី មានមិត្តភក្តិម្នាក់ទៀតឈ្មោះ ផនលី ធ្វើការនៅក្រុមសួរចម្លើយដែរ ។

យ៉ាន់ ឃី និង ផនលី (សួរចម្លើយនៅបន្ទប់ជិតគ្នា) តែងតែសួរគ្នាទៅវិញទៅមកអំពីសភាពការណ៍ខាងក្រៅថា ខ្មាំងប្រុងវាយអង្គការបដិវត្តជារៀងរាល់ថ្ងៃ ។ ផនលី និយាយប្រាប់ យ៉ាន់ ឃី ថា អ្នកទោសឈ្មោះ មេន សាខន ហៅ ម៉ុល អតីតពាណិជ្ជកម្មរដ្ឋបានឆ្លើយថា វាដឹងត្រឹម អាឃួន វាឆ្លើយដាក់ឈ្មោះ យ៉ា ។ ម៉ុល និយាយថា «ពួកវាមានផែនការវាយបដិវត្តនៅឆ្នាំ១៩៧៧ គឺពីខែ១រហូតដល់ខែ៤-៧៧» ។ ផនលី លើកឡើងជាបន្តបន្ទាប់ថា បើឈ្នះបដិវត្តវិញគឺពិតជាសប្បាយណាស់ គេរៀបចំរស់នៅជា

ឯកជនវិញ និងបង្កើតឲ្យមានល្បែងស្រីស្រាដូចពីសង្គមចាស់ ។

ផនលី និង យ៉ាន់ ឃី តែងតែនាំដំណឹងមកប្រាប់គ្នាទៅវិញទៅមក ។ ថ្ងៃមួយ ផនលី បានប្រាប់ យ៉ាន់ ឃី ថា កែវ បាន ត្រូវអង្គការសង្ស័យថាក្បត់ ព្រោះបានលួចនាឡិការបស់អង្គការ ។ ចំណែក សន និង តេង (ធ្វើការនៅក្នុងអង្គភាពយុទ្ធជនស្ទូរចម្លើយក្រុមកាចជាមួយ មិត្តប៊ួ) ក៏អង្គការមិនទុកចិត្តដែរ ហើយបានបញ្ជូនទៅធ្វើស្រែវិញ ។ នៅខែមេសា កែវ បាន និងឈ្មោះ ឃី គង់ ត្រូវអង្គការចាប់ខ្លួន ។ ផនលី ភ័យណាស់ ខ្លាចក្រែងថ្ងៃណាមួយខ្លួនត្រូវអង្គការចាប់ដែរ ព្រោះថាមិត្តភក្តិដែលធ្វើការជាមួយត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ដូចជា គិន មាន ជាដើម ហើយឈ្មោះ យ៉ែម, លិញ, សន, តេង ត្រូវអង្គការដកទៅបាត់ ។ ផនលី បានប្រាប់ យ៉ាន់ ឃី ថា «បើ បងស្ងួន ហៅយុទ្ធជនម្នាក់ ឬពីរនាក់ទៅកន្លែងគាត់នៅពេលយប់ ត្រូវឲ្យដំណឹងគ្នា ព្រោះថាយុទ្ធជនគ្មានភារកិច្ចអ្វីនឹងទៅជួបជាមួយ ស្ងួន ទេ មានតែប្រធានៗទើបមានភារកិច្ចទៅរាយការណ៍ ហើយបើទៅថ្ងៃមុខអង្គការ ឬបងស្ងួន ហៅ យើងត្រូវគេចខ្លួនតែម្តង» ។ ផនលី បានបបួល យ៉ាន់ ឃី រត់ទៅស្រុកយួនដើម្បីគេចខ្លួន ដោយហេតុថា អ្នកទាំងពីរមានជាប់ពាក់ព័ន្ធក្នុងចម្លើយរបស់ ឃី គង់ និង កែវ បាន ។

ផែនការត្រូវរត់ទៅស្រុកយួនគឺ ១) លួចកាំភ្លើងរបស់អ្នកយាមនៅតាមផ្លូវកាប់ជ្រុងចូលមកផ្ទះរបស់ ឌុច ប្រសិនបើអ្នកយាមដេញតាមទាន់ពាក់កណ្តាលផ្លូវ ត្រូវបាញ់សម្លាប់ខ្លួនឯងតែម្តង ។ ២) ពេលរត់ត្រូវចុះបណ្តែតខ្លួនតាមទឹកទន្លេមេគង្គទៅស្រុកយួន ។


ណុប នួន


កែវ បាន


គិន មាន

ថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៧ ម៉ោង១០:៣០នាទី ផនលី បានរត់ចេញពីមន្ទីរស-២១ ប៉ុន្តែត្រូវអង្គការចាប់បាន ។ ចំណែក យ៉ាន់ ឃី ត្រូវអង្គការឃាត់ខ្លួននៅស-២១យ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ ១៩៧៧ ។

**លី សុផល**

កងទ័ពបដិវត្តកម្ពុជា

មន្ទីរសេនាធិការ កម្មវត្ថុៈ សូមរាយការណ៍ជូន បង ដូចខាងក្រោមនេះ÷

**ស្នើដកសមាសភាពមិនល្អ ដូចរាយនាមខាងក្រោមនេះជា៣ផ្នែក÷**

១) ផ្នែកជូនទៅបង ឌុច ចំនួន៣នាក់ៈ ១-នារី វិន សកម្មភាពប្រជុំសម្ងាត់ និងបំផុសនារីឲ្យធ្វើឈឺ, ២-នារី យាន ទាក់ទងសីលធម៌បំផុសឲ្យលួច, ៣-ជាត់ នារី សកម្មភាពដូចខាងលើដែរ ។

២) ផ្នែកទៅបង ហុយ ចំនួន៧នាក់ៈ ១-អាត់ យុទ្ធជន កែពុំបានឈឺច្រើន, ២-សារឿន ជាប់ស្មាយត្រាណ ប៉ុន្តែការងារធ្វើកន្លងមកសេរី, ៣-ម៉ៅ យុទ្ធជន សេរីខ្ជិលធ្វើការងារ, ៤-ហុក យុទ្ធជនសេរី ខ្ជិលធ្វើការងារ, ៥-សុន សកម្មភាពពុតច្រើន, ៦-មករា សកម្មភាព ពុតច្រើន ខ្ជិល, ៧-គី លី សកម្មភាព ពុតច្រើន ខ្ជិល ។

៣) ផ្នែកទី៣ស្នើដកទៅឲ្យធ្វើស្រែនៅព្រៃសចំនួន២៦នាក់ ក្នុងឈ្មោះទាំង២៦នេះ គ្រាន់យើងកំពុងតាមដានមិនទាន់ប្រាកដជាក់ស្តែងនៅឡើយ ។

សូមស្នើមតិបងសម្រេច ។

ភាគរភាពបដិវត្ត

ថ្ងៃ៣០-១០-៧៧

រ៉ែន

# សេចក្ដីប្រកាសរបស់ អៀង សារី


អៀង សារី

ពេលដែលខ្ញុំបានឮដំណឹងតាមវិទ្យុផ្សាយសំឡេងរបស់កម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ៨ សីហា ១៩៩៦ ចោទប្រកាន់ខ្ញុំថា រត់ចោលជួរក្បត់ជាតិ ក្បត់ប្រជាជនមក ខ្ញុំដែលកំពុងព្យាបាលជំងឺ មានការរន្ធត់យ៉ាងខ្លាំង ពីព្រោះក្នុងជីវិតដឹកនាំតស៊ូរាប់សិបឆ្នាំដើម្បីជាតិនិងប្រជាជនរបស់ខ្ញុំ ខ្ញុំមិនដែលនឹកឃើញដីតិចតួចឡើយ នូវគំនិតថាខ្លួនខ្ញុំអាចទៅជាអ្នកក្បត់ជួជាតិនិងប្រជាជនខ្លួនឯងសោះ ។

ហេតុនេះ ខ្ញុំសុំបដិសេធទាំងស្រុងនូវការមួលបង្កាច់ដ៏កំសាកគ្មានហេតុផល គ្មានភស្តុតាងជាក់ស្តែង ហើយកម្មាភិបាល យុទ្ធជន គ្រួសារកងទ័ព និងប្រជាជនដែលធ្លាប់ស្គាល់ខ្ញុំ ក៏មិនអាចជឿបានទេ ។

បញ្ហាមួលបង្កាច់ ភូតភរ កុហក ជាការដែល សាឡុត ស ហៅ ប៉ុល ពត ប្រើជាយូរមកហើយ ក្នុងរយៈកាលតស៊ូជាប្រវត្តិសាស្ត្រមក ។ ពេលកាន់អំណាចផ្ដាច់ការ៣ឆ្នាំ ប៉ុល ពត សម្រេចបញ្ហាទាំងអស់ កាប់សម្លាប់ប្រជាជនដោយគ្មានការពិចារណាគិតគូរត្រឹមត្រូវអ្វីទាំងអស់ ហើយសំដៅសំខាន់ពង្រឹងអំណាចផ្ទាល់ខ្លួនរបស់វា ដោយបោសសម្អាតខ្មែរប្រមូលផ្ដុំនៅហាណូយក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ១៩៥៤ ដោយអត់រើសមុខនិងអត់មានកំហុសអ្វីទាំងអស់ ។ ទន្ទឹមនឹងនេះ សាឡុត ស ហៅ ប៉ុល ពត សម្រេចឲ្យដកប្រជាជនពីទីក្រុងភ្នំពេញ និងពីក្រុងនានាដោយគ្មានការពិចារណាល្អិតល្អន់ គ្មានការត្រៀមរៀបចំខាងជីវភាពនិងសង្គម ធ្វើឲ្យប្រជាជនរងទុក្ខវេទនាបាត់បង់គ្រួសារយ៉ាងអាណោចអាធ័ម ។ ក្រៅពីនេះ សាឡុត ស ហៅ ប៉ុល ពត កម្ទេចបញ្ញាជនដែលមកពីក្រៅប្រទេស ហើយមានឆន្ទៈចូលមករួមកសាងប្រទេសជាតិឡើងវិញ ដោយចោទប្រកាន់ថាជាភ្នាក់ងាររបស់ សេ.អ៊ី.អា កា.ហ្សេ.បេ និងភ្នាក់ងាររបស់ប្រទេសដែលគេបានទៅរៀនសូត្រ ។ បន្ថែមទៅទៀត ផ្ដាច់ការកម្ចាត់បោសសម្អាតបក្សកុម្មុយនិស្តកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ។ ផ្ដាច់ការចំពោះកម្មាភិបាលល្អដែលប្រជាជនគាំទ្រ ហើយមានលទ្ធភាពដឹកនាំជំនួស សាឡុត ស ហៅ ប៉ុល ពត បាន ។ ការបោសសម្អាតដ៏ឃោរឃៅនេះនាំឲ្យបក្សទាំងមូលមានការច្របូកច្របល់មន្ទិលសង្ស័យគ្នាទៅវិញទៅមកជាប់ ។

ក្រោយពីប្រកាសថាខ្ញុំក្បត់ជាតិរត់ចោលជួរមក កម្មាភិបាល និងកងទ័ព គ្រួសារកងទ័ព យុទ្ធមិត្ត និងគ្រួសារយុទ្ធមិត្តពលីក្នុងកងពល៤១៥ ប៉ៃលិន ៤៥០ ម៉ាឡៃ ២៥០ ស៊ីសូផុនខាងត្បូង ៥១៩ ស៊ីសូផុនខាងជើង បានសរសេរសំបុត្រមកខ្ញុំឲ្យជួយតាមដានបំភ្លឺជួរជួរកងទ័ពជាតិ ប្រជាជន ដែលត្រូវពួក ប៉ុល ពត តាម៉ុក សុន សេន កាត់ផ្ដាច់ និងមានទិសកម្ទេច៤៥០ និង ៤១៥ ដោយចោទថាក្បត់ជាតិនិងពុករលួយ ។

ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ សាឡុត ស ហៅ ប៉ុល ពត ដែលជាមេឃាតករឃោរឃៅព្រៃផ្សៃបំផុត បានឲ្យដៃជើងឈ្មោះ តាម៉ុក រួមជាមួយឈ្មោះ សុន សេន ហៅ ខៀវ នៅទីងមូលដ្ឋានដែលគេតាំងឈ្មោះថាជាអគ្គបញ្ជាការដ្ឋានជាន់ខ្ពស់ មកដោះស្រាយទំនាស់ក្នុងកងពល៤៥០ និង៤១៥ ដែលទំនាស់ចេញពីការតស៊ូរបស់ជួរកងទ័ពនិងប្រជាជន ប្រឆាំងអំពើផ្ដាច់ការ កាប់សម្លាប់ រឹបអូសទ្រព្យសម្បត្តិប្រជាជន និងមាក៏រដុតបំផ្លាញផ្ទះប្រជាជនរបស់ពួកក្បត់ជាតិ សាឡុត ស ហៅ ប៉ុល ពត, តា ម៉ុក និង ឈ្មោះ សុន សេន ហៅ ខៀវ ។ ក្នុងសភាពទំនាស់ដ៏ស្រួចស្រាវនេះ តាម៉ុក ដែលតាំងខ្លួនតំណាងមកដោះស្រាយបញ្ហា មិនហ៊ានដោះស្រាយអ្វីទេ ព្រោះទំនាស់នេះវាជាការវែកមុខអំពើផ្ដាច់ការ និងឧក្រិដ្ឋកម្មរបស់ឈ្មោះ សុន សេន ហៅ ខៀវ ដែលជាដៃគូផ្ដាច់ការរបស់ ប៉ុល ពត ។ ផ្ទុយទៅវិញ តាម៉ុក បែរជាយកឯកសារដែលជួរកងទ័ពប្រជាជនយើងមិនអាចទទួលបាន មកផ្សព្វផ្សាយ ហាក់ដូចជាយកសាំងទៅចាក់លើភ្លើង ឲ្យភ្លើងកំហឹងជួរកងទ័ពប្រជាជនរឹតតែឆាបឆេះសន្ធោសន្ធៅឡើងថែមទៀត ។

ឈរលើការវិភាគត្រឹមត្រូវនិងច្បាស់លាស់របស់ជួរកងទ័ពប្រជាជនក្នុងកងពល៤១៥ និង៤៥០ យើងយល់ច្បាស់ជាធាតុដើមរបស់ សាឡុត ស ហៅ ប៉ុល ពត, តាម៉ុក និង សុន សេន ហៅ ខៀវ បានវិលត្រឡប់មករករបបពង្ឆាំ ដ៏ឃោរឃៅព្រៃផ្សៃបំផុតវិញ ហើយដែលជាតិ ប្រជាជន និងសកលលោក ខ្លាចរអានិងស្អប់ខ្ពើមជាទីបំផុត ។

ស្ថិតចំពោះមុខគ្រោះអាសន្នដ៏ធ្ងន់ធ្ងរនេះ ជួរនិងកងទ័ពប្រជាជនទាំងពីរកងពលមិនដឹងជារកផ្លូវណាដោះស្រាយឲ្យភ្លឺស្វាងនិងកក់ក្ដៅណាសំដៅបញ្ចប់សង្គ្រាមនិងផ្សះផ្សាជាតិទៀតបានទេ ។ គេក៏បាត់ជំនឿ និងអស់សង្ឃឹមលើមេដឹកនាំឈ្មោះ សាឡុត ស ហៅ ប៉ុល ពត, តាម៉ុក និង សុន សេន ហៅ ខៀវ នេះទៀតផង ។ ដូច្នេះហើយ ជួរកងទ័ពប្រជាជនក្នុងកងពល៤១៥ ៤៥០ ព្រមទាំងមានការឧបត្ថម្ភពីកងពល២៥០និង៥១៩ផង បានសរសេរសំបុត្ររាយការណ៍ពីសភាពការណ៍ពិតជាក់ស្ដែង និងអំពើប្រព្រឹត្តរបស់ពួកឃាតករមួយក្ដាប់តូចនេះ គឺឈ្មោះ សាឡុត ស ហៅ ប៉ុល ពត, តាម៉ុក និង សុន សេន ហៅ ខៀវ ជូនមកខ្ញុំដែលជាអ្នកដឹកនាំចាស់មួយរូបរបស់កម្ពុជាប្រជាធិបតេយ្យ ដែលគេធ្លាប់ស្គាល់ថាជាអ្នកស្នេហាជាតិ ស្នេហាប្រជាជនពិតប្រាកដក្នុងជាតិទាំងមូល និងធ្លាប់ដឹកនាំតាមរបបប្រជាធិបតេយ្យ ហើយមានពិសោធន៍ធ្លាប់កសាងតំបន់ម៉ាឡៃឲ្យរីកចម្រើនជាបន្តបន្ទាប់ ដើម្បីឲ្យខ្ញុំវិលមកជួយដឹកនាំគ្រប់កងពល ។

ដូច្នេះហើយ ទោះជាខ្ញុំព្យាបាលជំងឺមិនទាន់ជាសះស្បើយហើយក៏ដោយ ក៏ខ្ញុំបានសម្រេចចិត្តមកបន្តការដឹកនាំដោយផ្ដាច់ខ្លួនពីការចាត់តាំងផ្ដាច់ការខាងនយោបាយ ផ្ដាច់ការទាំងរបៀបរបបធ្វើការងាររបស់ ប៉ុល ពត ឃោរឃៅហួសហេតុព្រៃផ្សៃ ទៅជារបបប្រជាធិបតេយ្យដែលជួរកងទ័ពប្រជាជនអាចទទួលបាន ។

អាស្រ័យហេតុនេះ ការវិលត្រឡប់របស់ខ្ញុំមិនមែនដូចពួក ប៉ុល ពត, តាម៉ុក និង សុន សេន ហៅ ខៀវ ចោទប្រកាន់ថា ធ្វើតាមការញុះញង់របស់ពួកសម្ព័ន្ធភាពនឹងយួនកុម្មុយនិស្តឲ្យចូលមកក្រឡុកក្នុងជួរ កងទ័ព ប្រជាជនវានោះទេ ។ ការពិតជាក់ស្ដែងគឺជាសំណូមពរដ៏ជ្រាលជ្រៅរបស់ជួរជាតិប្រជាជនទាមទារឲ្យខ្ញុំវិលត្រឡប់មកដឹកនាំគេក្នុងសភាពដ៏លំបាកមហាសែនលំបាកនេះ ។

ជាទីបញ្ចប់ ខ្លួនខ្ញុំផ្ទាល់ព្រមជាមួយជួរកងទ័ពប្រជាជនដែលបានអញ្ជើញខ្ញុំឲ្យមកដឹកនាំនេះ និងរួមជាមួយជាតិទាំងមូល ឈានទៅរកការផ្សះផ្សាជាតិមួយដ៏ពិតប្រាកដ ដែលខុសពីគំនិតរវើរវាយគ្មានមូលដ្ឋានច្បាស់លាស់ គិតតែបង្ហូរឈាម ធ្វើសង្គ្រាមរហូតដល់ភ្លើងឆេះកល្បរបស់ ប៉ុល ពត, តាម៉ុក, សុន សេន ហៅ ខៀវ ។

ធ្វើនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ ១ ៩ ៩ ៦ **អៀង សារី**

## ប្រវត្តិសង្ខេបរបស់ អៀង សារី

អៀង សារី មានឈ្មោះដើម គីម ត្រាង ឈ្មោះបដិវត្ត ស៊ូ ហាវ, សមមិត្តវ៉ាន់ និងឈ្មោះហៅក្រៅមួយទៀតគឺបងពេញ ជនជាតិខ្មែរកម្ពុជាក្រោម ។ អៀង សារី កើតឆ្នាំ១៩៣០ នៅខេត្តត្រាវិញ ប្រទេសវៀតណាម ។ ប្រពន្ធឈ្មោះ អៀង ធីរិទ្ធ មានកូន៤នាក់ (ស្រីបីនាក់និងប្រុសម្នាក់) ។

ឆ្នាំ១៩៦០ អៀង សារី ទៅបង្រៀននៅសាលាកម្ពុជបុត្រ ក្រុងភ្នំពេញ ផ្នែកប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ ហ៊ូ យន់ ជានាយកសាលា ។ ខែឧសភា ឆ្នាំ១៩៦៣ អៀង សារី បានរត់ចូលព្រៃនៅតាមព្រំដែនខេត្តកំពង់ចាម ។ នៅពេលដែលរត់ចូលព្រៃ អៀង សារី បានបង្កើតកងទ័ពនៅភូមិភាគឦសាន ។ ឆ្នាំ១៩៧០ អៀង សារី បានទៅហាណូយដើម្បីទាក់ទងវៀតណាម ។ ឆ្នាំ១៩៧២ អៀង សារី បានក្លាយទៅជាអគ្គមេបញ្ជាការកងទ័ពនៅភូមិភាគឦសាន ។ រវាងឆ្នាំ១៩៧១-៧២នេះ អៀង សារី និងប្រពន្ធឈ្មោះ អៀង ធីរិទ្ធ បានបង្កើតរដ្ឋអំណាចនយោបាយមួយទៅលើខ្មែរនៅវៀត-ណាម ។ ឆ្នាំ១៩៧៣ អៀង សារី បានធ្វើការនៅក្នុងមន្ទីរសម្ងាត់របស់បក្សនៅជាយក្រុងហាណូយ ។ នៅខែមករា ឆ្នាំ១៩៧៥ អៀង សារី បានចូលជាសមាជិកនៃបក្សប្រជាជនបដិវត្តកម្ពុជា ។ ខែកញ្ញា ឆ្នាំ១៩៧៥ អៀង សារី ស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ។ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ អៀង សារី គឺជាអ្នកទទួលខុសត្រូវ «ការងារបរទេសទាំងបក្សនិងរដ្ឋ» ។ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៧៦ អៀង សារី ត្រូវបាន(គណៈមជ្ឈិម) តែងតាំងជាឧបនាយកមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស ។

ក្រោយពីឡើងកាន់អំណាច ប៉ុល ពត និង អៀង សារី និងមេដឹកនាំមួយចំនួនទៀតបានបង្កើតឲ្យមានចលនាសម្លាប់មនុស្សអស់រាប់លាននាក់ ។ ***សង្ខេបដោយ លី សុផល***

# ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម

***(តពីលេខមុន)***

មន្ទីរសេដ្ឋកិច្ចភាគតាំងនៅភូមិតាំងខ្មៅ ប្របមាត់ស្ទឹង នៅប៉ែកពាយ័ព្យវត្តតាំងខ្មៅ ។ លោក សៀង ប៉ោសែ ទទួលខុសត្រូវលើសេដ្ឋកិច្ចភាគ លើរថយន្តប្រើប្រាស់ខ្លះៗ មានឡានឡង់រ៉ូវែរ ឡានកាំមីញ៉ុង ជាដើម ។ នៅជាប់នឹងមន្ទីរសេដ្ឋកិច្ចភាគប៉ែកខាងកើតនិងខាងត្បូង មានសង់រោងជាច្រើនសម្រាប់ទទួល "ភ្ញៀវចំណូលថ្មី" ដែលទើបរត់ចេញពីភ្នំពេញ ហើយដែលមាននិន្នាការត្រឹមនយោបាយក្របខ័ណ្ឌរណសិរ្ស (សីហនុនិយម) ។ "ភ្ញៀវចំណូលថ្មី" ត្រូវបានអង្គការ "បន្ទំសតិអារម្មណ៍" មួយកន្លែងសិន មិនសូវមានសេរីភាពចេញដើររហេតរហូតទេ ហើយក៏គ្មានទទួលភារកិច្ចអ្វីធំដុំពីអង្គការដែរ ក្រៅពីការកាប់គាស់ដី ដាំដំណាំ ឬចិញ្ចឹមមាន់-ទា បន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់ជីវភាពផ្ទាល់ខ្លួន ។ សមាជិកនៅក្នុងមន្ទីរដទៃទៀត និយមចំអកហៅទីកន្លែងនេះថាជា "ភូមិរណសិរ្ស" ។ លោក ម៉ែន នីថូ និង លោក សៀង ប៉ោសែ ជាអ្នកមើលការខុសត្រូវតាមដានមើលភ្ញៀវចំណូលថ្មី ។ នៅទីនេះ យើងបានជួបពិភាក្សាជាមួយលោកស័ក្តិបួននារីម្នាក់ឈ្មោះ សូមេរ៉ាម និងសហការីជាអនុសេនីយ៍ត្រីពីររូបទៀត នៅថ្ងៃ១២ វិច្ឆិកា ១៩៧២ ។

## ២) វិន័យរបស់អង្គការ

វិន័យរបស់អង្គការមានលក្ខណៈតឹងរ៉ឹងខ្លាំងណាស់ ។ គឺជាវិន័យរបស់ជនកុម្មុយនិស្ត ដែលជាវិន័យរឹងដូចដែក ។ គេបានអប់រំផ្សាំងយុវជននិងក្របខ័ណ្ឌរបស់គេឲ្យទៅជនសង្គមនិយម និងឲ្យទៅជាជនកុម្មុយនិស្តតាមកម្រិតតឹងរ៉ឹងខ្លាំងឡើងៗជាលំដាប់ ។ មានឯកសារជាច្រើនចងក្រងដោយ "គណៈមជ្ឈិម" សម្រាប់យកមកធ្វើជាគោលរៀនសូត្រ ។

ចំពោះសមាជិកមន្ទីរយុវជនដែលនៅស្រឡាញ់ស្តេច សីហនុនៅឡើយ គេពុំទាន់ហ៊ានបើកមុខបង្ហាញទិសដៅពិតប្រាកដរបស់គេទេ ។ គេយកតែត្រឹមគោលការណ៍ការតស៊ូក្នុងក្របខ័ណ្ឌរណសិរ្សមកបង្ហាត់បង្រៀន មកអប់រំ គឺគោលការណ៍បដិវត្តន៍ប្រជាជាតិ ។ គេបោកបញ្ឆោតថាៈ "យើងតស៊ូធ្វើបដិវត្តន៍នេះ ដើម្បីរំដោះប្រជាជាតិពីនឹមចក្រពត្តិអាមេរិកាំង" ។

បន្តិចម្តងៗ គេរំកិលចូលទៅក្នុងទ្រឹស្តីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ បំផុសការតស៊ូវណ្ណៈ កំហឹងវណ្ណៈ ទំនាស់ស្លាប់រស់នៅក្នុងវណ្ណៈ វណ្ណៈនៅក្នុងសង្គមកម្ពុជា ។ គេវាយប្រហារពួកសក្តិភូមិ ពួកប្រតិកិរិយា ពួកនាយទុនកុំប្រាដ័រ ឈ្មោះស្តេច សីហនុ គេមិនវាយប្រហារដោយចំៗទេ តែគេមិនដែលបំផុស ឬលើកតម្កើងម្តងណាទេ ។ នៅក្នុងជួរក្របខ័ណ្ឌខ្មែរក្រហមខ្លះ គេវាយប្រហារ "ធាតុសក្តិភូមិ" របស់ស្តេច សីហនុ ដោយចំហ ។ ក្របខ័ណ្ឌខ្មែរក្រហមណាហ៊ានលើកសរសើរស្តេច សីហនុ នឹងត្រូវគេចាត់ទុកជាអ្នកប្រឆាំងនឹងបដិវត្តន៍របស់គេ ។ គេនៅតែចាត់ទុកស្តេច សីហនុ ថាជានិមិត្តរូបនៃរបបសក្តិភូមិដដែល ថ្វីបើស្តេច សីហនុ ទៅនៅប៉េកាំងក៏ដោយ ។

ជាមួយប្រជាជន មហាជន គោលវិន័យរបស់អង្គការខ្មែរក្រហមដែលសំខាន់ជាងគេ គឺកុំធ្វើឲ្យប៉ះពាល់ដល់ "មាគ៌ាមហាជន" ។ ខ្មែរក្រហមម្នាក់ៗត្រូវប្រកាន់អាកប្បកិរិយាទន់ភ្លន់សុភាពរាបសាជាដាច់ខាត ជាមួយប្រជាជន គេត្រូវកម្ទេចនិន្នាការទៅរក "អាជ្ញានិយម" ទៅរក "នាម៉ឺននិយម" ។ គេបានរំពុកជារឿយៗនូវពាក្យរបស់ ម៉ៅ សេទុង ថែងថាៈ "ប្រជាជនជាត្រីគេជាទឹក" ។ ជនបដិវត្ត (បដិវត្តសង្គមនិយម) មួយរូបៗត្រូវទុកដាក់ជាកូនចៅប្រជាជន បម្រើប្រជាជនឲ្យអស់ពីចិត្តពីថ្លើម ហើយត្រូវធ្វើខ្លួនឯងឲ្យដូចជាប្រជាជន ដើម្បីរៀនសូត្រពីមហាជន ព្រោះ "មហាជនជាប្រភពនៃចំណេះវិជ្ជា ដែលមិនចេះរីងស្ងួត" ។ គេ

លើកជាពាក្យស្លោកថា «រៀនសូត្រពីមហាជន ដើម្បីមហាជន» តែគេបានប្រកាន់ជំហរមួយទៀតដែរថា «មិនត្រូវដើរតាមកន្ទុយមហាជនពេកទេ» ។ ក្នុងការរស់នៅ ដេក ដើរ ស៊ីចុក ស្លៀកពាក់ គេប្រុងប្រយ័ត្នមិនឲ្យភោរភាវប្លែកពីប្រជាជនទេ ។ អាកប្បកិរិយានិងសម្តីទៅរកប្រជាកសិករ ត្រូវទន់ភ្លន់សុភាពរាបសាជាដរាប ។ ហេតុយ៉ាងនេះហើយបានជាខ្មែរក្រហម គេបង្ខំឲ្យស្លៀកពាក់ខ្មៅបង់កក្រមា ។ ម្ហូបអាហារប្រចាំថ្ងៃក៏មិនត្រូវសម្បូរណ៌ហូរហៀរឆ្ងាញ់ពិសាលើសប្រជាជនដែរ ។ គេខស្បាហ៍រំពុកដល់សភាពក្រខ្សត់របស់ប្រជាជនដែលបានគាំទ្របដិវត្តរបស់គេ ។ ម្យ៉ាងទៀត ការបង្ខិតបង្ខំមិនឲ្យ «ញាក់ទៅរកឆ្ងាញ់» នេះ ចូលជាយុទ្ធវិធីរបស់គេមួយ ដើម្បីទម្លាប់គ្នាគេឲ្យចេះទ្រាំទ្រនូវការលំបាកសព្វបែបយ៉ាងផង និងអប់រំខ្លួនប្រាណនិងសតិអារម្មណ៍របស់គេឲ្យទៅជា «កម្មាជីព» ផង ។ ដូច្នេះហើយបានជានៅតាមមន្ទីរនីមួយៗគេកម្រមានភ័ព្វវាសនាបានបរិភោគម្ហូបអាហារពីរមុខណាស់ ។

«អង្គការ» ខ្មែរក្រហមហាមប្រាមយ៉ាងតឹងរ៉ឹងមិនឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាជន ។ ការខូចខិល រំលោភលើកូនក្រមុំប្រជាជន នឹងត្រូវទទួលទោសជាទម្ងន់ ។ តាមការសង្កេតជាហូរហែមកថា វិន័យទាំងអម្បាលម៉ានត្រូវបានគ្នាគេគោរព អនុវត្តបានខ្ជាប់ខ្ជួននិងស័ក្តិសិទ្ធិមែន ។

ចំណុចមួយទៀតដែលជា «សកម្មភាពចិត្តសាស្ត្រ» យ៉ាងស័ក្តិសិទ្ធិរបស់ខ្មែរក្រហមទៅលើប្រជាពលរដ្ឋកសិករ គឺការជួយទុក្ខធុរៈប្រជាកសិករ ។ បើមានកសិករឈឺថ្កាត់នៅក្នុងភូមិ ជាពិសេសកសិករក្រ ពួកខ្មែរក្រហមគេខស្បាហ៍នាំគ្នាទៅចាក់ឬចែកថ្នាំឲ្យដល់ផ្ទះតែម្តង ទោះជាយប់ព្រលប់មានភ្លៀងផ្គររន្ទះក្តី ។ នៅរដូវភ្ជួររាស់ ដកស្ទូង ច្រូតកាត់ ឬបោកបែន មន្ទីរនីមួយៗត្រូវចាត់សមាជិកឲ្យទៅជួយធ្វើសឹងតែរាល់ពេល ។ ការចុះទៅ «ជាប់នឹងប្រជាជន» ដើម្បី «បម្រើប្រជាជន» ប្រាស្រ័យទាក់ទងជិតស្និទ្ធនឹងប្រជាជនគឺជាការអនុវត្តន៍នូវទ្រឹស្តីមួយក្នុងការអប់រំពួកក្របខ័ណ្ឌខ្មែរក្រហម ។

សកម្មភាពចិត្តសាស្ត្របៀបនេះ មានប្រសិទ្ធភាពនិងស៊ីជម្រៅទៅលើប្រជាជនពិតប្រាកដមែន ជាជាងការណែនាំបង្រៀនទ្រឹស្តី ។ ប្រជាជនកសិករនៅតាមភូមិមូលដ្ឋាន ដែលមិនយល់អ្វីសោះពីរឿងបដិវត្តសង្គមនិយម ក៏ចាប់ស្រឡាញ់និងគាំទ្រអង្គការភ្លាមៗតាមរយៈមនោសញ្ចេតនាស្និទ្ធស្នាល ។

◆ នៅក្នុងមន្ទីរ-នៅគ្រប់មន្ទីរទាំងអស់ ខ្មែរក្រហមរស់នៅជាសមូហភាព គោរពវិន័យរបស់សមូហភាព (វិន័យអង្គការ) គោរពពេលវេលាធ្វើការដែលសមូហភាពបានកំណត់អនុវត្តផែនការប្រចាំសប្តាហ៍ប្រចាំខែដែលសមូហភាពបានលើកឡើង ។

សមាជិកទាំងអស់នៅក្នុងមន្ទីរត្រូវធ្វើពលិកម្មដូចគ្នា ទាំងសមាជិកធម្មតា ទាំងប្រធាន ។ កិច្ចការពលកម្មនេះត្រូវបានគេចាត់ទុកជាចាំបាច់ទីមួយសម្រាប់ «កសាង» ខ្លួនឲ្យទៅជាកម្មាជីពជាកម្មករមានផ្គត់ចង្វាក់ទៅរកពលកម្ម អាចទ្រាំទ្រនឹងការលំបាកផ្សេងៗដែលបដិវត្តន៍របស់គេអាចពើបប្រទះ ។ កិច្ចការពលកម្មអាចដុសលាងសតិអារម្មណ៍មួយថ្មីគឺ សតិអារម្មណ៍បដិវត្តន៍ សតិអារម្មណ៍ជាកម្មាជីព សតិអារម្មណ៍ សង្គមនិយម ។ ពួកខ្មែរក្រហមខស្បាហ៍ទូន្មានគ្នាគេថា «បដិវត្តន៍របស់គេ នៅមានការបត់បែនលំបាកវេទនាតទៅទៀត» ។ សមាជិកម្នាក់ៗមិនត្រូវជិះជាន់ពលកម្មរបស់គេទេ ពួកគេទាំងអស់ (លើកលែងវរជនខ្មែរក្រហមសំខាន់ៗខ្លះដែរ) ត្រូវដាំបន្លែ ដាំដំឡូង រែកទឹក ពុះអុស ធ្វើអង្ករដោយខ្លួនឯង តាមវេនរៀងៗខ្លួន ។ ក្រៅពីកិច្ចការសម្រាប់ជីវភាពមន្ទីរ សមាជិកម្នាក់ៗមានភារកិច្ចចំពោះមុខដូចជាការងារនៅរោងពុម្ពជាដើម ។ អង្គការហាមប្រាមមិនឲ្យប្រើពាក្យ «អាមីង» រវាងគ្នានិងគ្នា ។ គេយកពាក្យ «មិត្ត» មកប្រើសឹងតែទូទៅ ។ ពាក្យ បង មីង មា អ៊ំ តា យាយ ក៏នៅមានប្រើដែរ តែជាទូទៅគេប្រើពាក្យមិត្តច្រើនជាង ។ គេខស្បាហ៍ទូន្មានឲ្យពង្រឹង «មនោសញ្ចេតនានយោបាយ» រវាងគ្នានិងគ្នាជាង «មនោសញ្ចេតនា» ជាបុគ្គល ។

អង្គការធ្លាប់ណែនាំឲ្យខិតខំជម្រុះ «ធាតុបុគ្គល» លក្ខណៈបុគ្គលនិយម ដែលគេចោទថាជា «ធាតុប្រតិកិរិយា» ឲ្យបានជាអតិបរមាឲ្យប្រកាន់ខ្ជាប់នូវ «ស្មារតីសួនរួម» នូវជំហរ «សមូហភាព» ឲ្យគិតផលប្រយោជន៍សួនរួមធំជាងប្រយោជន៍សួនតួ ។ បើសមាជិកណាឆាប់ញាក់ញោច ឆាប់ខឹងឆេវឆាវ គេចោទថានៅមាន «ធាតុបុគ្គលក្រាស់» ។ ជាមួយធាតុបុគ្គលនេះ គេច្រើនភ្ជាប់ «ធាតុសេរី

និយម» ជាមួយផង ។ ធាតុទាំងអស់នេះត្រូវគេចាត់ទុកជាធាតុប្រឆាំងនឹងបដិវត្តន៍ ជាធាតុរបស់វណ្ណៈជិះជាន់ ធាតុរបស់ពួកប្រតិកិរិយា ។ នៅក្នុងប្រជុំជីវភាពម្តងៗ គេតែងទិតៀនគ្នាទៅវិញទៅមកពីរឿង «សេរីនិយម» ក្នុងការ «ហូប ដេក ដើរ និយាយ» បានសេចក្តីថា មានមិត្តខ្លះបរិភោគបាយខុសពីការកំណត់របស់គេ ឬទំរន់ក្រក្រោកពីដំណេក ឬនិយាយហួរហែពេក មិនចេះរក្សាការសម្ងាត់ ។ល ។ ការតាមដានមើលគ្នាទៅវិញទៅមក ជាករណីយកិច្ចនៃសមាជិកម្នាក់ៗ ហើយការជម្រុះធាតុដូចពោលខាងលើនេះ ក៏



ជាប្រយោជន៍អប់រំសមាជិករបស់គេឲ្យជា «ជនសង្គមនិយម» ។ នេះជាជំហាន «ផ្សាំង» មនុស្សឲ្យទៅជា«ម៉ាស៊ីន» មួយ ផុយពីដំណើរវិវត្តន៍ធម្មជាតិ ។

លក្ខណៈពាលាអាវ៉ាសែត្រូវបានអង្គការណែនាំឲ្យបំបាត់មានរឿង ស្រី ស្រា ល្បែងជាដើម ។ ចំពោះស្រីនិងល្បែងឃើញថា អង្គការខ្មែរក្រហមដោះស្រាយបានពិតប្រាកដមែន ជាមួយនឹងអំពើលួចឆក់ប្លន់ផ្សេងៗ ។ ចំណែកគ្រឿងស្រវឹងនៅមានសេសសល់ខ្លះៗ តែអង្គការខ្មែរក្រហមបានដោះស្រាយបំបាត់


កងទ័ពបដិវត្តខ្មែរក្រហម

លក្ខណៈស្រវឹងអាវ៉ាសែបានមួយកម្រិតយ៉ាងធំ ។

នៅក្នុងសង្គមរបស់ពួកខ្មែរក្រហម គេបានហាមប្រាមមិនឲ្យបុរសមានប្រពន្ធពីរជាដាច់ខាត ។

កសិករនៅក្នុងភូមិក៏ដូចសមាជិកនៅក្នុងមន្ទីរនីមួយៗដែរ ត្រូវមានការកិច្ចតាមដានមើលសកម្មភាពគ្នាទៅវិញទៅមក នៅក្នុងពួកឬនៅក្នុងក្រុមរបស់ខ្លួន ដើម្បីអប់រំគ្នាទៅវិញទៅមក ដែលពួកកុម្មុយនិស្តនិយមហៅថា "កសាង" ។ ក្នុងមួយសប្តាហ៍ គេមានធ្វើការប្រជុំពួកឬក្រុមម្តង គេហៅថា ប្រជុំជីវភាព ។ ក្នុងពេលប្រជុំ ពួកគេធ្វើការទិតៀននិងស្វ័យទិតៀនគ្នាទៅវិញទៅមក គឺគេលើកពីការខុះខាត ការឆ្គាំឆ្គង ពីគុណសម្បត្តិនិងគុណវិបត្តិរបស់ខ្លួនឯងនិងមិត្តរួមពួកមកលាតត្រដាង ។ គឺការធ្វើស្វ័យទិតៀននិងទិតៀននេះហើយ ដែលបង្ខំឲ្យពួកខ្មែរក្រហម ឬអ្នកស្រុកតាមដានគ្នាទៅវិញទៅមក ។ ការធ្វើស្វ័យទិតៀននិងទិតៀននេះហើយ ជាឧបករណ៍សំខាន់លេខមួយរបស់លទ្ធិម៉ាក្សនិស្តឡេនីនិស្ត ។ គោលជំហរដែលសមាជិកម្នាក់ៗត្រូវត្រួតពិនិត្យទៅលើខ្លួនឯងនិងទៅលើមិត្តខ្លួនមាន៖

◆គោលជំហរពលកម្ម ◆គោលជំហរនយោបាយ ◆គោលជំហរសាមគ្គីភាព ◆គោលជំហរសតិអារម្មណ៍ ◆គោលជំហរចាត់តាំង

ក្នុងឱកាសប្រជុំក្រុម គេត្រួតពិនិត្យគោលជំហររួមរបស់ក្រុមទាំងមូល មិនសំដៅទៅលើបុគ្គលណាម្នាក់ទេ ។ ក្រោយការពិនិត្យជំហរផ្សេងៗរបស់ក្រុម គេចាប់រៀបចំធ្វើផែនការរួមសម្រាប់អាទិត្យក្រោយ ។

ក្នុងការទិតៀនស្វ័យទិតៀននេះ អង្គការខ្មែរក្រហមបានណែនាំទូន្មានមិនឲ្យយកការទិតៀនស្វ័យទិតៀននេះធ្វើជាអាវុធសម្រាប់សងសឹកគ្នា វាយប្រហារគ្នាទេ ។ គេទូន្មានឲ្យយកការទិតៀនស្វ័យទិតៀននេះធ្វើជាមធ្យោបាយអប់រំកែគ្នាទៅវិញទៅមក ធ្វើជា "ថ្នាំកម្ចាត់រោគ" ផ្សេងៗ មានរោគ "បុគ្គលនិយម-សេរីនិយម-នាម៉ឺននិយម-អាជ្ញានិយម-ការិយាល័យនិយម" ជាដើម ។ អ្នកធ្វើការទិតៀនគេនិងអ្នកដែលត្រូវគេទិតៀន ត្រូវឲ្យមាន "ខួរក្បាលត្រជាក់ជានិច្ច" កុំញាក់ញោចខឹងឆេវឆាវ ។ ការធ្វើស្វ័យទិតៀននិងទិតៀនត្រូវឈរលើមាគ៌ាអង្គការ និងមាគ៌ាមហាជនជានិច្ច ។

វិន័យមួយទៀតរបស់ខ្មែរក្រហម (ពួកក្របខ័ណ្ឌ) គឺការលាក់ការណ៍សម្ងាត់ ។ សមាជិកមន្ទីរត្រូវលាក់អាថ៌កំបាំងរបស់ខ្លួន របស់មន្ទីរ និងរបស់អង្គការ ។ ហេតុដូច្នេះហើយបានជាម្នាក់ៗត្រូវមានឈ្មោះថ្មីមួយ ត្រូវលាក់ឈ្មោះដើមរបស់ខ្លួនកុំឲ្យនរណាដឹង លើកលែងតែអង្គការថ្នាក់លើគេត្រូវការសួរព័ត៌មានពីខ្លួនឯងជាផ្លូវការ ។ ប្រសិនបើមានអ្នកដទៃណា ទោះជាអ្នកនៅក្នុងជួរដូចគ្នា ឬបងប្អូនកសិករណា ចង់ដឹងពីទីតាំងរបស់មន្ទីរ ពីឈ្មោះដើម "វណ្ណភាព" ដើម ស្រុកកំណើតរបស់ខ្លួន គេមិនត្រូវប្រាប់ឲ្យនរណាដឹងទេ ។ វិន័យនេះត្រូវបានគេរំឭករាល់សប្តាហ៍និងតាមដានដូចសកម្មភាពផ្សេងៗទៀតដែរ ។

ក្នុងរឿងឋានានុក្រម គេក៏បានអនុវត្តដោយហ្មត់ចត់ គឺអង្គការថ្នាក់ក្រោមគោរពអង្គការថ្នាក់លើ គណៈភូមិស្តាប់បញ្ជាគណៈឃុំ គណៈឃុំស្តាប់បង្គាប់គណៈស្រុក ស្រុកគោរពគណៈតំបន់ តំបន់គោរពភាគ ភាគត្រូវស្តាប់បញ្ជាគណៈមជ្ឈិម (គណៈកម្មការកណ្តាលនៃបក្សកុម្មុយនិស្តកម្ពុជា) ។

សមាជិកម្នាក់ៗត្រូវប្រគល់ខ្លួនឲ្យអង្គការ "កសាង" ដោយគ្មាន "តម្លៃ" ត្រូវទុកចិត្តទាំងស្រុងទៅលើ "អង្គការ" ព្រោះអង្គការមានភ្នែកដូច "ម្នាស់" មិនចេះខុសឆ្គង ។ នេះជាលក្ខណ្ឌផ្តាច់ការរបស់បក្សទៅលើបុគ្គល បញ្ជាក់នូវអំណាចគ្មានព្រំដែនរបស់បក្សទៅលើអ្វីៗទាំងអស់ ។ គឺជាជំហរឆ្ពោះទៅរកលទ្ធិ "ផ្តាច់ការរបស់វណ្ណៈអធន" សមាជិកម្នាក់ៗមានការទុកចិត្តទាំងស្រុងទៅលើអង្គការ ត្រូវការពារកិត្តិយសអង្គការមិនត្រូវវាយប្រហារអង្គការពីក្រោយខ្នងឡើយ ។ ប្រសិនបើអនុវត្តតាមមាគ៌ារបស់អង្គការហើយ តែបែរជាបានលទ្ធផលអាក្រក់ផ្ទុយទៅវិញ គេមិនត្រូវចោទប្រកាន់អង្គការថា "ដាក់ទិស" ខុសទេគេត្រូវដាក់កំហុសទៅលើបុគ្គលទៅវិញ គឺបុគ្គលទេដែលមានការឆ្គាំឆ្គងមានការខុះខាត ។ ផលវិបាកមួយចៀសមិនផុតគឺ តែងតែលេចក្របខ័ណ្ឌខ្មែរក្រហមណាម្នាក់បានប្រព្រឹត្តរំលោភលើវិន័យ ឬក្តោបអំណាចលើខ្លួនឯង ហើយយកឈ្មោះអង្គការមកធ្វើជាឡប់ខ្លែ ។ ដែលហៅថា អង្គការ គឺបក្សកុម្មុយនិស្តកម្ពុជានិងសាខាតូចធំ

របស់បក្សនេះ មានតាំងពីគណៈកម្មការ ភូមិ ឃុំ ស្រុក តំបន់ ភាគ រហូតដល់ថ្នាក់មជ្ឈិម ។

រវាងមន្ទីរមួយនិងមន្ទីរមួយ គេហាមប្រាមមិនឲ្យចេញចូលរហេតរហូតទេ ពុំនោះទេ សមាជិកនោះនឹងត្រូវគេលើកយកមកទិតៀន "កសាង" ពីបទ "សេរីនិយម" ពីបទបំពានលើលាក់ការណ៍សម្ងាត់ ។ ហេតុដូច្នោះហើយបានជាសមាជិកនៃមន្ទីរនេះ មួយៗ ពុំសូវមានការទាក់ទងគ្នា ឬរយោបល់គ្នាទៅវិញទៅមក ។ គេរៀបចំយ៉ាងនេះ ក៏ដើម្បីខ្ទប់កម្លាំងអាថ៌កំបាំងបម្រុងក្បត់អង្គការរបស់គេដែរ ។ ក្នុងការរស់នៅតាមមន្ទីរនីមួយៗ គេខស្បាហ៍រំពុកឲ្យប្រកាន់ "ជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន" គឺមន្ទីរនីមួយៗត្រូវរកមធ្យោបាយដើម្បីរស់ដោយខ្លួនឯង ។ អង្គការគ្រាន់តែផ្តល់ប្រាក់ជីវភាពឲ្យក្នុង១ខែ១៣៥រៀល សម្រាប់សមាជិកម្នាក់ៗ ។ មន្ទីរនីមួយៗត្រូវលៃរកម្ហូបចំណី (ច្រើនតែក្តាមខ្យង) បន្លែខ្លួនឯងត្រូវ "សម្រុកបង្កបង្កើនផល" តាមកម្លាំងផ្ទាល់ខ្លួនត្រូវចិញ្ចឹមមាន់ទា ជ្រូក នៅតាមមន្ទីររៀងៗខ្លួនតាមលទ្ធផលដែលអាចធ្វើបាន ។

**៣) កិច្ចការពលកម្ម**

កិច្ចការពលកម្មនេះត្រូវបានអង្គការចាត់ទុកជាករណីយកិច្ចទីមួយរបស់សមាជិកម្នាក់ៗ ។ ជនកុម្មុយនិស្តត្រូវតែ "លត់ដំ" ខ្លួននៅក្នុងការងារពលកម្មជាចាំបាច់ ។ ការងារពលកម្មសម្រាប់ពួកក្របខ័ណ្ឌបញ្ញវន្ត មានលំនាំដូចគ្នានិងការងាររបស់អ្នកស្រុកគឺៈ

◆ នៅក្នុងមន្ទីរ សមាជិកម្នាក់ៗទោះប្រុសក្តី ស្រីក្តី ជាបញ្ញាជនក្តី ជាកូនកសិករសុទ្ធសាធក្តី ត្រូវរែកទឹក រកអុស ដាំស្ល បោសសម្អាតទីធ្លាមន្ទីរ ជីកក្តាមតាមវាលស្រែ រែកទឹកស្រោចបន្លែ កិនស្រូវ ដាន់អង្ករ ឲ្យបាយមាន់ទាជ្រូក ដូចគ្នាទាំងអស់ ។ កិច្ចការទាំងអស់នេះ គេចែកវេនគ្នាធ្វើដោយទៀងទាត់ គ្មានអារម្មណ៍ចង្អៀតចង្អល់អ្វីទេ ។ ការមើលបំណាំគ្នា ឬប្រកែកជទាស់មិនព្រមធ្វើ មិនសូវមានទេ ។ ម្នាក់ៗត្រូវសម្តែងទឹកចិត្តអំណត់រៀងៗខ្លួនក្នុងពេលបំពេញកិច្ចការពលកម្មអ្វីមួយ ។ សមាជិកណាម្នាក់ដែលខ្ជិលច្រអូសទំរន់ក្នុងការងារទាំងអស់នេះ នឹងត្រូវសមាជិកដទៃទៀតធ្វើការទិតៀននៅក្នុងពេលប្រជុំពួកឬប្រជុំក្រុម ។

◆ ការងារបង្កបង្កើនផល មន្ទីរនីមួយៗត្រូវបានអង្គការថ្នាក់លើណែនាំឲ្យចេះដោះស្រាយបញ្ហាជីវភាពដោយខ្លួនឯង កុំសូវពឹងផ្អែកលើប្រជាកសិករពេក ព្រោះប្រជាជនគ្នាមានការខ្វះខាតច្រើន ។ មន្ទីរនីមួយៗគាស់រានធ្វើចម្ការច្បារដំណាំដោយខ្លួនឯង មានដាំស្ពៃ ប៉េងប៉ោះ ដំ ត្រកួន ឃ្លោក ត្រឡាច ត្រប់ ម្ទេស ដំឡូង ពោត សណ្តែក ជាដើម ។ មានក្រុមខ្មែរក្រហមខ្លះទៀតដូចជា មន្ទីរសិល្បៈភូមិភាគពិសេសជាដើម យុវជនក្មេងៗនាំគ្នាឡើងចងទឹកត្នោតយកទឹករម្ងាស់ធ្វើស្ករសម្រាប់ប្រើប្រាស់នៅក្នុងមន្ទីររបស់ខ្លួន ។

ក្នុងរឿងចិញ្ចឹមសត្វ មាន់ ទា ជ្រូកវិញ ក៏មន្ទីរទាំងអស់ប្រឹងប្រែងពង្រីកណាស់ដែរ ។

ថ្វីបើមាន មាន់ ទា ជ្រូកនៅតាមមន្ទីរក៏ដោយ ម្ហូបអាហារក៏នៅតែអត្តខាត់ខ្សត់ខ្សោយដដែល ព្រោះម្យ៉ាង អង្គការណែនាំឲ្យ "ចេះសន្សំសំចៃ" ចេះអត់ទ្រាំនឹងការអត់ឃ្លាន ឲ្យបំបាត់ "អារម្មណ៍" ចង់ឆ្ងាញ់ ម្យ៉ាងទៀត ភូមិភាគដែលយើងរស់នៅជាភូមិភាគក្រខ្សត់ខាងត្រីសាច់ខ្លាំងណាស់ សូម្បីតែកង្កែបក៏ពិបាករកទៀតផង ។ ពងទាពីរឬបីត្រូវយកទៅស្ងោរជាមួយបន្លែស្ពៃ សម្រាប់សមាជិក១២នាក់ ។ មានពេលខ្លះ គេស្ងោរតែបន្លែស្ពៃទទេ គ្មានត្រីសាច់អ្វីទេ ។ ក្នុងមួយឆ្នាំមានខ្មែរក្រហមខ្លះបានបរិភោគត្រីស្រស់តែបីបួនដងប៉ុណ្ណោះទេ ហើយពុំបានគ្រប់គ្រាន់ផងទៀត ។

◆ ការងារបម្រើប្រជាជន ខ្មែរក្រហមម្នាក់ៗត្រូវជ្រួតជ្រាបនឹង "ទស្សនៈមហាជន" ត្រូវជាប់នឹងមហាជន ជាប់នឹងប្រជាជន ។ ការជួយធុរៈប្រជាជន ជាពិសេសប្រជាជនមូលដ្ឋាន ជាការយកចិត្តទុកដាក់ទីមួយរបស់អង្គការថ្នាក់លើ ។ ពេលណាប្រជាជនលើកទំនប់ជីកស្រះ ធ្វើថ្នល់ ឬសង់ផ្ទះ ពួកខ្មែរក្រហមដែលនៅជិតភូមិនោះតែងចាត់វេនគ្នាទៅជួយធ្វើ ហើយធ្វើដោយយកចិត្តទុកដាក់ទៀតផង ។ ពេលដកស្ទូង ច្រូតកាត់ បោកបែន គេក៏ផ្លាស់វេនគ្នាទៅជួយដោយទៀតទាត់ ។ ចំពោះកសិករណាក្រខ្សត់ជាងគេ អង្គការក៏បានជួយធុរៈច្រើនជាងគេផងដែរ ។ ***(នៅមានត)***

**អ៊ិត សារិន**

# បញ្ជីឈ្មោះជនរងគ្រោះជនបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

**(តពីលេខមុន)**

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ២៣៥ | ង្វៀង យ៉ាំងបត | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១៨-១១-៧៨ | ២-១២-៧៨ |
| ២៣៦ | ង៉ូ យ៉ាំងទ្រី | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១៨-១១-៧៨ | ១១-១២-៧៨ |
| ២៣៧ | ត្រឹង យ៉ាំងឡឹង | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១៨-១១-៧៨ | ២-១២-៧៨ |
| ២៣៨ | ង្វៀង យ៉ាំងហារ | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១៨-១១-៧៨ | ២-១២-៧៨ |
| ២៣៩ | ឡេ យ៉ាំងចូវ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៩-១១-៧៨ | ? |
| ២៤០ | ឡេ ធីមីភៀង(ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៩-១១-៧៨ | ? |
| ២៤១ | ផាង យ៉ាំងនេន | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៤-១១-៧៨ | ២-១២-៧៨ |
| ២៤២ | ទ្រឿង អាន់កៀត | យួន | ចារកិច្ចយួន | មណ្ឌលគិរី | ២៦-១១-៧៨ | ? |
| ២៤៣ | ង្វៀង វ៉ាន់ភូ | យួន | ចារកិច្ចយួន | មណ្ឌលគិរី | ២៦-១១-៧៨ | ? |
| ២៤៤ | ង្វៀង យ៉ាំងធូ | យួន | ចារកិច្ចយួន | មណ្ឌលគិរី | ២៦-១១-៧៨ | ២-១២-៧៨ |
| ២៤៥ | ង្វៀង លី | យួន | ចារកិច្ចយួន | មណ្ឌលគិរី | ២៦-១១-៧៨ | ? |
| ២៤៦ | ង្វៀង ហ៊ូដុង | យួន | ចារកិច្ចយួន | មណ្ឌលគិរី | ២៦-១១-៧៨ | ២-១២-៧៨ |
| ២៤៧ | ត្រឹង យ៉ាំងលៀ | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១០-១២-៧៨ | ១១-១២-៧៨ |
| ២៤៨ | ផាម យ៉ាំងម៉ាន | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១០-១២-៧៨ | ១១-១២-៧៨ |
| ២៤៩ | ប៊ុយ វ៉ាន់ធិន | យួន | ដាយវ៉ុយធីវគី | ត្បូសាន | ២៤-៨-៧៨ | ១១-១២-៧៨ |
| ២៥០ | យឿង សីនហុង | យួន | ដុងវ៉ុយធីវគី | ក្រចេះ | ១៣-១០-៧៨ | ១១-១២-៧៨ |
| ២៥១ | ត្រឹង យ៉ាំងហាច់ | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ២៨-១០-៧៨ | ១១-១២-៧៨ |
| ២៥២ | ង្វៀន វ៉ាន់ហើប | យួន | ពលទោផ្កាយ១ | និរតី | ១៩-១១-៧៨ | ១១-១២-៧៨ |
| ២៥៣ | ឡេ គក់យុង | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៧-៧៨ | ២៣-១០-៧៨ |
| ២៥៤ | ត្រឹង សាំងញឹក | យួន | បិញញីធីវធី | ស្វាយរៀង | ២៥-៩-៧៨ | ២៣-១០-៧៨ |
| ២៥៥ | យឿង យ៉ាំងយា | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ២៣-១០-៧៨ |
| ២៥៦ | ផាម យ៉ាំងកែម | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៧-៩-៧៨ | ២៣-១០-៧៨ |
| ២៥៧ | ង្វៀង ហុងវី | យួន | ស័ក្តិ១ ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២៣-១០-៧៨ |
| ២៥៨ | វ៉ី ថេហ៊ុង | យួន | ស័ក្តិ១ ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២៣-១០-៧៨ |
| ២៥៩ | ង្វៀង វ៉ាន់វិញ | យួន | ស័ក្តិ១ ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២៣-១០-៧៨ |
| ២៦០ | ទ្រឿង ហ៊ូថាញ់ | យួន | ស័ក្តិ១ ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២៣-១០-៧៨ |
| ២៦១ | ង្វៀង វ៉ាងអាន់ | យួន | ដុងវ៉ុយធីវគី | ក្រចេះ | ១៣-១០-៧៨ | ២៣-១០-៧៨ |

(នៅមានត)

# ប្រវត្តិរូប តាម៉ុក

តាម៉ុក មានឈ្មោះដើម អ៊ុង ជឿន។ តាម៉ុក មានឈ្មោះហៅក្រៅជាច្រើនទៀតដូចជា តា១៥, ឈិត ជឿន, ឯក ជឿន, អាចារ្យ ជឿន និង ផ្គួន កង។ តាម៉ុក កើតនៅឆ្នាំខាល ត្រូវនឹងឆ្នាំ១៩២៦ នៅភូមិប្រគាប ឃុំត្រពាំងធំ (ត្បូង) ស្រុកត្រាំកក់ ខេត្តតាកែវ តំបន់៣៣ ភូមិភាគនិរតី។ តាម៉ុក បានរៀបការជាមួយបងប្អូនជីដូនមួយរបស់ខ្លួនឈ្មោះ អ៊ុក ខឹម ។

តាម៉ុក មានបងប្អូនចំនួន៧នាក់ ប្រុស៣ ស្រី៤ (តាម៉ុកជាកូនបងបង្អស់) ។

ប្អូនទី១ឈ្មោះ អ៊ុង ចុក ហៅ ចុង ភេទប្រុស ជំនាន់ខ្មែរក្រហមជាចៅហ្វាយស្រុកព្រៃកប្បាស លេខាបក្សកុម្មុយនិស្តកម្ពុជាប្រចាំស្រុកព្រៃកប្បាស (ខេត្តតាកែវ) និងជាលេខាតំបន់៣៣ ។

ប្អូនទី២ឈ្មោះ អ៊ុង ពូន អាយុ៦៨ឆ្នាំ ភេទស្រី មានប្តីឈ្មោះ និត (ស្លាប់) អតីតចៅហ្វាយស្រុកនរាយណ៍។ សព្វថ្ងៃ អ៊ុង ពូន ប្រកបមុខរបរធ្វើស្រែចម្ការនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ខាងត្បូងស្រុកត្រាំកក់ ខេត្តតាកែវ ។

ប្អូនទី៣ឈ្មោះ អ៊ុង ចំ ភេទប្រុស (ស្លាប់) អតីតគណៈឃុំពកត្របែក ស្រុកត្រាំកក់ ។

ប្អូនទី៤ឈ្មោះ អ៊ុង គួប ភេទស្រី ។

ប្អូនទី៥ឈ្មោះ អ៊ុង គៀន ភេទស្រី ។

ប្អូនទី៦ឈ្មោះ អ៊ុង គេន ភេទស្រី ។

***ខាងក្រោមគឺជាមុខងារនិងសកម្មភាពមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៥ៈ***

តាម៉ុក រស់នៅជាមួយជីដូនតាំងពីតូច ។

អាយុក្រោម១៨ឆ្នាំ តាម៉ុក រៀននៅសាលារៀនត្រពាំងធំ (ស្រុកកំណើត) ។

អាយុជាង១៩ឆ្នាំ តាម៉ុក ចូលរៀននៅសាលាវត្ត និងបួសនៅវត្តមហាមន្ត្រី រហូតទទួលបានសញ្ញាប័ត្រព្រះត្រៃបិដក ។

អាយុជាង៣០ឆ្នាំ តាម៉ុក សឹកពីសង្ឃ ហើយរៀបការប្រពន្ធនៅស្រុកកំណើតជាមួយគ្នានៅឯភូមិប្រគាប (ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ) ។

ក្រោយរៀបការបានកូន២នាក់ តាម៉ុក ក៏រត់ទៅព្រៃដើម្បីតស៊ូ (រត់ទៅស្រុកលិចគឺខេត្តកំពត) ហើយក្រោយមកគាត់យកប្រពន្ធទៅទុកនៅស្រុកលាជ ខេត្តពោធិ៍សាត់ ។

ឆ្នាំ១៩៤៩ តាម៉ុក ជាប្រធានឥស្សរៈរបស់ស្រុកមួយក្នុងខេត្តតាកែវ ។

ឆ្នាំ១៩៦៣ តាម៉ុក ជាសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា ។

តាម៉ុក ជាសមាជិកគណៈកម្មាធិការមជ្ឈិម “សមាជិកគណៈកម្មាធិការមជ្ឈិមនៃគណបក្ស ប៉ុល ពត” ។

ឆ្នាំ១៩៦៨-៦៩ តាម៉ុក ត្រូវបានបក្សចាត់តាំងឲ្យធ្វើជាលេខាភូមិភាគនិរតី។ ក្នុងឆ្នាំដដែលនោះ តាម៉ុក មានការប៉ះទង្គិចសតិអារម្មណ៍ជាមួយ ហ៊ូ នឹម ។

ដើមទសវត្សរ៍ឆ្នាំ១៩៧០ តាម៉ុក លេខាភូមិភាគនិរតី។ (ទោះបីជាប្រភពមួយចំនួនបង្ហាញថា ជូ ជេត ជាលេខា ហើយ តាម៉ុក ជាអនុលេខាក៏ដោយ) ។

ខែមិថុនា ឆ្នាំ១៩៧១ តាម៉ុក ជាសមាជិកនៃសមាជរបស់បក្សកុម្មុយនិស្តកម្ពុជា ។ សមាជមានរយៈពេល២សប្តាហ៍ នៅឯមន្ទីររបស់ ប៉ុល ពត នៅភូមិភាគឧត្តរ ។

ឆ្នាំ១៩៧២ កូនស្រីរបស់ តាម៉ុក ត្រូវបានចាត់តាំងឲ្យធ្វើជាអនុលេខាតំបន់។ ក្នុងឆ្នាំដដែលនេះ តាម៉ុក បើកអង្គប្រជុំមួយនៅក្នុងខេត្តកំពង់ឆ្នាំង ដែលចូលរួមដោយព្រះសង្ឃប្រមាណបីពាន់អង្គ ។ ការប្រជុំនេះ គឺសុំឲ្យព្រះសង្ឃចូលធ្វើកងទ័ព ។

ឆ្នាំ១៩៧២-១៩៧៣ តាម៉ុក មេដឹកនាំចលនាខ្មែរក្រហមនៅក្នុងស្រុក ។

ឆ្នាំ១៩៧៣ តាម៉ុក ទទួលបន្ទុកផ្នែកកងទ័ពក្នុងភូមិភាគនិរតី ។ តាម៉ុក ចាប់ផ្តើមសម្លាប់អ្នកក្បត់នៅខេត្តកំពង់ស្ពឺ ក្រោយពីបង្ខំឲ្យធ្វើការជាទម្ងន់ និងចាប់ផ្តើមសម្លាប់កម្មាភិបាលដែលគាំទ្រ (អ្នកមកពី) ហាណូយនៅភូមិភាគនិរតី ។

ឆ្នាំ១៩៧៤ កែ ពក បានដឹកនាំទ័ពរួមជាមួយ តាម៉ុក វាយចូលកាន់កាប់ខេត្តនិងកំពង់ឆ្នាំង ។

តាម៉ុក ជាមេបញ្ជាការកងទ័ពរបស់គណៈមជ្ឈិម ។

ខែកញ្ញា ឆ្នាំ១៩៧៥ តាម៉ុក ស្ថិតនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ។

ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ តាម៉ុក ត្រូវបានគណៈមជ្ឈិមបក្សតែងតាំងជាអនុប្រធានទី២ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្នុងឆ្នាំ១៩៧៧ តាម៉ុក ធ្វើជាអគ្គមេបញ្ជាការកងទ័ព ។ អាវុធជាច្រើនដើម ហើយគ្រប់ប្រភេទត្រូវបានបែងចែកទៅឲ្យ តាម៉ុក នៅភូមិភាគនិរតី ។

ចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ តាម៉ុក មានការទាក់ទងយ៉ាងស្និទ្ធស្នាលជាមួយ វន វេត ចំនួន៦លើក នៅក្រសួងសេដ្ឋកិច្ច ដើម្បីស្នើសម្ភារៈ ។

ខែសីហា ឆ្នាំ១៩៧៨ តាម៉ុក បានចូលរួមប្រជុំមជ្ឈិមជាមួយ វន វេត ដែរ ។ «នៅពេលប្រជុំគណៈមជ្ឈិម ខែសីហា ឆ្នាំ១៩៧៨ហើយ តាវន និយាយថា តាម៉ុក មានកម្លាំងច្រើនដែលពង្រាយគ្នាពេញប្រទេស» ។

ឆ្នាំ១៩៧៨ តាម៉ុក ជាអគ្គលេខាបក្សកុម្មុយនិស្តកម្ពុជាប្រចាំភូមិភាគនិរតី ។ តាម៉ុក ត្រូវបានចោទប្រកាន់ថា បានសម្លាប់ប្រជាជននៅក្នុងភូមិទាំងមូលដែលគាំទ្រពួកខ្មាំង ហើយក្រុមរបស់គាត់បានសម្លាប់ប្រជាជនចំនួន៣ម៉ឺននាក់គ្រាន់តែនៅក្នុងស្រុកអង្គរជ័យ ខេត្តកំពតមួយប៉ុណ្ណោះ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ តាម៉ុក ត្រូវបានចាត់តាំងជាអនុលេខាបក្សកុម្មុយនិស្តកម្ពុជា ។

ឆ្នាំ១៩៧៩ តាម៉ុក នៅតែមានតួនាទីនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងជាមេបញ្ជាការកងពលនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ឆ្នាំ១៩៩៩-បច្ចុប្បន្ន តាម៉ុក ជាប់ក្នុងមន្ទីរឃុំឃាំងនៃគុកយោធា (តាម៉ុក ត្រូវបានចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩) ។ **ចងក្រងដោយ ផេង ពង្សរ៉ាស៊ី, យិន នាន និង ឆេង វ៉េង។ សង្ខេបដោយ ម៉ាន់ថាន់ ពៅដារ៉ា**



# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៦០៤ | ជា ថៃសេង | អធិការវប្បធម៌ | តំបន់២៥ | ២២-២-៧៦ | ២៧-៥-៧៦ |
| ៦០៥ | យូ ឃិនរ៉េត | កម្មករ | អគ្គិសនីចាក់អង្រែ | ២៣-៣-៧៦ | ២៨-៥-៧៦ |
| ៦០៦ | សេង វ៉េង | កម្មករ | អគ្គិសនីចាក់អង្រែ | ២៧-៣-៧៦ | ២៨-៥-៧៦ |
| ៦០៧ | ស្រី ស្រ៊ិន | កម្មករ | អគ្គិសនីផ្សារតូច | ២៧-៣-៧៦ | ២៨-៥-៧៦ |
| ៦០៨ | ហោ ឆូរេន | កម្មករ | អគ្គិសនីផ្សារតូច | ២៧-៣-៧៦ | ២៨-៥-៧៦ |
| ៦០៩ | ឃឹម សាអ៊ិត | កម្មករ | អគ្គិសនីផ្សារតូច | ២៧-៣-៧៦ | ២៨-៥-៧៦ |
| ៦១០ | អៀម សុវ៉ាន់ណារី | កម្មករ | អគ្គិសនីផ្សារតូច | ២៧-៣-៧៦ | ២៨-៥-៧៦ |
| ៦១១ | ម៉ី វណ្ណា | កម្មករ | អគ្គិសនីផ្សារតូច | ២៧-៣-៧៦ | ២៨-៥-៧៦ |
| ៦១២ | ឈាង គឹមសួរ | វិស្វករ | តំបន់២២ | ១៣-២-៧៦ | ២៨-៥-៧៦ |
| ៦១៣ | នុត នេត | ប្រជាជន | ដីឥដ្ឋកៀនស្វាយ | ១-១០-៧៥ | ២៨-៥-៧៦ |
| ៦១៤ | ពត ចាន់វុធី | កូនសិស្ស | តំបន់២៥ | ? | ២៨-៥-៧៦ |
| ៦១៥ | សុង ហាក់ ហៅ សាក់ | ទាហាន | កំពង់ធំ | ១៩-២-៧៦ | ១-៦-៧៦ |
| ៦១៦ | ម៉ី ផន | កម្មករ | អគ្គិសនីផ្សារតូច | ១៣-៤-៧៦ | ១-៦-៧៦ |
| ៦១៧ | ប៉ែន សារឿន ហៅ ស៊ូ | សាស្ត្រាចារ្យ | កោះធំ | ២២-២-៧៦ | ១-៦-៧៦ |
| ៦១៨ | កេត ចាតន្ធ ហៅ កន | កម្មករ | តម្បាញ ត-៥ | ២២-៤-៧៦ | ១-៦-៧៦ |
| ៦១៩ | អ៊ុន ចំរើន | ប្រជាជន | តំបន់២៥ | ៨-៣-៧៦ | ៣-៦-៧៦ |
| ៦២០ | ឃិន សារ៉ាត | ទាហាន | តំបន់១៥ | ២៨-២-៧៦ | ៤-៦-៧៦ |
| ៦២១ | អំ ឈុំ | ស័ក្តិ៤កន្លះ | តំបន់១៥ | ២៨-២-៧៦ | ៤-៦-៧៦ |
| ៦២២ | ភិន ថុន ហៅ សុកសុន | ស័ក្តិ១ | តំបន់២៥ | ១-៣-៧៦ | ៤-៦-៧៦ |
| ៦២៣ | សេក ស៊ីម៉េត ហៅ សេក សឿន | ស័ក្តិ១ | តំបន់២៥ | ១-៣-៧៦ | ៤-៦-៧៦ |
| ៦២៤ | កែវ ពៅ | ពលទោ | ពោធិសាត់ | ២-១២-៧៥ | ៤-៦-៧៦ |
| ៦២៥ | ប៊ុច រ៉ា | ពលទោ | កំពង់ឆ្នាំង | ៤-២-៧៦ | ៤-៦-៧៦ |
| ៦២៦ | នុត ចាន់ថន | ស័ក្តិ១ | តំបន់២៥ | ១៨-១-៧៦ | ៤-៦-៧៦ |
| ៦២៧ | ឈឹម ដោគរី | ប៉េអឹម | ពោធិសាត់ | ១៩-១២-៧៥ | ៤-៦-៧៦ |
| ៦២៨ | ដួង សាខន | គិញ | ស្រែអំបិល | ២១-៤-៧៦ | ៤-៦-៧៦ |
| ៦២៩ | យុន យ៉ាន់ | ទាហាន | កំពង់សោម | ៧-៥-៧៦ | ៤-៦-៧៦ |

(នៅមានត)

# ភ្នែកងងឹតតែចិត្តនៅចាំ

## ជីវិតរបស់ជនរងគ្រោះដែលមានវ័យកាន់តែចំណាស់

អ្នកច្បាប់ហាក់ដូចជាមានការព្រួយបារម្ភអំពីជរាភាពរបស់មេដឹកនាំខ្មែរក្រហម ខ្លាចក្រែងអស់ជីវិតមុនពេលមានសវនាការជម្រះទោសនៅចំពោះមុខតុលាការ ។ នួន ជា, អៀង សារី, ខៀវ សំផន និងអតីតមេដឹកនាំខ្មែរក្រហមមួយចំនួនទៀត កំពុងតែរស់នៅដោយសុខសាន្ត គ្មាននរណាហ៊ានប៉ះពាល់ឡើយ ក្នុងខណៈដែលជនរងគ្រោះដែលបានរួចផុតពីការស្លាប់នៅក្រោមស្នាដៃរបស់មេដឹកនាំទាំងនេះកំពុងរស់នៅយ៉ាងលំបាកគោកយ៉ាកខ្វះមុខខ្វះក្រោយ ។ ហេតុអ្វីបានជាគ្មាននរណាព្រួយបារម្ភអំពីជរាភាពរបស់ជនរងគ្រោះ?

សាក្សីដែលនៅរស់ហើយចងចាំ និងធ្លាប់ទទួលរងនូវការប្រព្រឹត្តិរបស់របបកម្ពុជាប្រជាធិបតេយ្យ ពិតជាមានសារសំខាន់ណាស់ ។ សារសំខាន់ទីមួយ គឺជនរងគ្រោះទាំងអស់នោះអាចផ្ទេរបទពិសោធន៍ដ៏ជូរចត់ទាំងនេះទៅឲ្យកូនចៅជំនាន់ក្រោយស្វែងយល់ និងជួយទប់ស្កាត់មិនឲ្យអំពើបែបនេះកើតឡើងមកលើប្រជាជនកម្ពុជា និងមនុស្សជាតិទូទៅ ។ សារសំខាន់ទីពីរ គឺគាត់អាចក្លាយជាកសិណសាក្សីឡើងស្រាយបំភ្លឺអង្គហេតុដែលគាត់ធ្លាប់ឆ្លងកាត់ចំពោះមុខតុលាការ ។ ទាំងកសិណសាក្សី និងសាក្សីជារូបវ័ន្តសុទ្ធតែមានសារសំខាន់ប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែ ការដែលគួរឲ្យព្រួយបារម្ភនោះគឺ សាក្សីទាំងនេះមិនអាចមានជីវិតស្ថិតនៅគង់វង្សរហូតទេ ។ម្យ៉ាងទៀត ភ័ស្តុតាងមួយចំនួនកាន់តែពុកផុយ ។ យ៉ាងណាមិញ សាក្សីដ៏ចំណាស់ម្នាក់ដែលធ្លាប់ធ្វើការជាមួយមេដឹកនាំខ្មែរក្រហមមួយចំនួនកំពុងតែរស់នៅយ៉ាងស្ងាត់ស្ងៀមនៅ



លោកយាយ ចាន់ យឹម និងកូនស្រី

ភូមិដ្ឋានដាច់ស្រយាលវង់ចាំយុត្តិធម៌ ។

ក្រុមទស្សនាវដ្តីស្វែងរកការពិតបានធ្វើដំណើរឆ្ពោះទៅខេត្តកំពង់ចាមដោយឆ្លងកាត់ចម្ការកៅស៊ូដ៏ធំមួយ ឆ្ពោះទៅភូមិថ្នល់បែកកើត ក្នុងស្រុកចម្ការលើ ដើម្បីជួបសម្ភាស និងសួរសុខទុក្ខលោកយាយម្នាក់ដែលជាជនរងគ្រោះមានវ័យចំណាស់ និងធ្លាប់ចាប់សរសៃឲ្យមេដឹកនាំខ្មែរក្រហមម្នាក់នៅក្នុងរបបខ្មែរក្រហម ។ រថយន្តរបស់យើងបានធ្វើដំណើរបត់ចុះបត់ឡើងតាមផ្លូវដ៏លំបាក ។ ប្រហែលជាម៉ោង១១ព្រឹក រថយន្តបាននាំយើងទៅដល់ផ្ទះមួយខ្នងសង់អំពីឈើ កម្ពស់ផុតពីដីជាងមួយម៉ែត្រ ជញ្ជាំងក្តាបាំងប្រជួសគ្នាមានប្រហោងដោយអន្លើ ។ ប្រសិនបើយើងសម្លឹងមើលទិដ្ឋភាពខាងក្រៅឃើញថាផ្ទះនេះមានសភាពទ្រុឌទ្រោម ស្ងប់ស្ងាត់ដូចគ្មានមនុស្សរស់នៅ ។ ប៉ុន្តែ នៅពេលបានឡើងដល់លើផ្ទះអ្វីដែលយើងបានឃើញនិងជួបប្រទះជាដំបូង គឺដូនចាស់ម្នាក់និងឆ្មាមួយក្បាលដែលកំពុងអង្គុយនៅជិតចានអាហារ ។ ដូនចាស់នោះមានរូបរាងកាយស្គមស្គាំង ស្បែកជណ្តប់ឆ្អឹង ភ្នែកទាំងគូពិការ (ក្នុងអំឡុងឆ្នាំ១៩៨៥) ខ្នងកោងមិនអាចងើបឈរនិងដើរបានទេ ។

ដូនចាស់មានឈ្មោះថា ចាន់ យឹម ហៅលោកយាយ យឹម គឺជាអ្នកដែលយើងចង់ជួប ។ ក្រោយពីបានសួរសុខទុក្ខ និងប្រាប់អំពីដំណើរដើមទងមកសុំសម្ភាសគាត់ លោកយាយបានប្រាប់ថាគាត់ទើបតែពិសាបាយរួចល្មម ។ លោកយាយនិយាយបណ្តើររំកិលគូថយ៉ាងយឺតៗបណ្តើរ ទៅរកកន្ទេលរបស់គាត់ទាំងសភាពយាប់យ៉ឺន ដោយប្រើដៃទាំងពីរធ្វើជាលំនឹង ។ លោកយាយបានផ្តេកខ្លួនទៅលើកន្ទេលនីឡុងនោះ ហើយចាប់ផ្តើមអធិប្បាយរឿងរ៉ាវរបស់គាត់តាមការសាកសួររបស់យើង ។

ទម្រាំតែអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាយល់ព្រមបន្តការចរចាសាជាថ្មីក្នុងការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមវិញ លោកយាយ យឹម មានអាយុ៨៣ឆ្នាំទៅហើយ ។ ឪពុករបស់លោកយាយឈ្មោះ ចាន់ ជាអតីតជំទប់ឃុំ នៅស្រុកមោងឫស្សីខេត្តបាត់ដំបង ម្តាយឈ្មោះ សៀម ។ លោកយាយជាកូនទី២ក្នុងចំណោមបងប្អូនប្រាំបួននាក់ ។ មកដល់បច្ចុប្បន្ននេះ ដោយសារសុខភាពដុនដាបពេក ទើបលោកយាយមិនអាចចាំបានថាបងប្អូនទាំងអស់របស់គាត់ស្លាប់ឬរស់ ។

ក្នុងវ័យ១៩ឆ្នាំ លោកយាយបានរៀបការជាមួយបុរសម្នាក់ ហើយបានកូនប្រុសពីរនាក់និងកូនស្រីម្នាក់ ។ សំណាងអាក្រក់កូនប្រុសទាំងពីររបស់លោកយាយបានត្រូវ កែ ពក យកទៅសម្លាប់ចោល ។ ចំណែកកូនស្រីម្នាក់ទៀតស្លាប់ក្រោយរបបខ្មែរក្រហម ។ ក្រោយមកលោកយាយក៏បានរៀបការជាមួយលោកតា សួស វើន (ជាកម្មករដើរធ្វើការគ្រប់ទីកន្លែង ។ ស្លាប់នៅឆ្នាំ១៩៨៤) បានកូនស្រីមួយឈ្មោះ សួស សុខា ។ នៅក្នុងរបបខ្មែរក្រហមលោកតា សួស វើន គឺជាអ្នកផលិតថ្នាំពេទ្យ ហើយអង្គការបដិវត្តបានបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរពេទ្យបក្ស ។ សព្វថ្ងៃលោកយាយរស់នៅជាមួយ សួស សុខា ក្នុងស្ថានភាពយ៉ាប់យ៉ឺនបំផុត ។ លោកយាយបានបន្លឺសំឡេងខ្សាវៗថា ចាប់តាំងពីពេលខ្លួនគាត់ពិការភ្នែកមកមិនដែលបានធ្វើដំណើរទៅមកណាទេ ។ លោកយាយនៅតែលើផ្ទះអស់រយៈពេលជាងដប់ឆ្នាំមកហើយ អាចរំកិលទៅណេះទៅណោះបានតែនៅលើផ្ទះតែប៉ុណ្ណោះ ។ លោកយាយបានត្អូញត្អែរយ៉ាងកម្សត់ថា "ម្តាយពិបាកណាស់សព្វថ្ងៃនេះ ម្តាយបន់ឲ្យតែស្លាប់ទេ វេទនាណាស់"... "ម្តាយវង្វេងហើយ" ។ លោកយាយបានអំពាវនាវឲ្យសប្បុរសជនជួយសង្គ្រោះគាត់ផង ទម្រាំដល់ពេលគាត់អនិច្ចកម្ម ។

នៅមុនឆ្នាំ១៩៧៥ ដោយសារតែជីវភាពយ៉ាប់យ៉ឺនពេក បងប្រុសជីដូនមួយរបស់លោកយាយ ឈ្មោះ ប៉ែន ចាន់ បានយកលោកយាយមករស់នៅឃុំរំលង ខេត្តកំពង់ចាម ប្រកបរបរធ្វើចម្ការ ។ ក្រោយមក ប៉ែន ចាន់ ត្រូវបានសម្លាប់ លោកយាយត្រូវរស់នៅឯកោ ។

លុះដល់ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមឡើងកាន់អំណាច កែ ពក ប្រធានភូមិភាគឧត្តរ បានបំបែកលោកយាយចេញពីគ្រួសារឲ្យមកបម្រើការក្នុងមន្ទីររបស់ខ្លួន ដោយឲ្យធ្វើជាប្រធានពេទ្យជាឆ្មបនិងអ្នកចាប់សរសៃ ។ កាលណោះលោកយាយមានអាយុ៥៧ឆ្នាំ ។ លោកយាយគឺជាអ្នកចាប់សរសៃដ៏ប៉ិនប្រសប់ ។ មិនតែប៉ុណ្ណោះ លោកយាយថែមទាំងចេះវិជ្ជាឆ្មបនិងព្យាបាលជំងឺស្ត្រីគ្រប់ប្រភេទទៀតផង ។ ជារៀងរាល់ថ្ងៃ លោកយាយត្រូវចាប់សរសៃឲ្យ កែ ពក និងកងទ័ពទាំងអស់នៅមន្ទីររបស់ កែ

ពក ។ លោកយាយមានប្រសាសន៍ថា គាត់ចេះចាប់សរសៃនិងចេះធ្វើឆ្មបតាំងពីអាយុ១៥ឆ្នាំម្ល៉េះ ។ លោកយាយបានប្រាប់អំពីមូលហេតុដែលគាត់ចេះវិជ្ជានេះថា ថ្ងៃមួយ នៅពេលគាត់កំពុងសម្រាកនៅក្រោមដើមពុទ្រា មានមនុស្សចាស់ធំចម្លែកម្នាក់បានបង្ហាញខ្លួននៅចំពោះមុខគាត់ ហើយហុចទៀនធូបមកឲ្យគាត់ ។ លោកយាយមានអារម្មណ៍ថា មនុស្សនោះបានចេញពីដើមពុទ្រា ។ មនុស្សនោះក៏បាននិយាយមកកាន់គាត់ថា «បើចេះហើយធ្វើទៅគ្រាន់រក្សាខ្លួនរក្សាប្រាណ ដល់ចាស់បន្តិច គេយកយាយទៅហើយ» លោកយាយក៏បានចេះវិជ្ជាឆ្មបនិងចាប់សរសៃតាំងពីពេលនោះមក ។ នៅមន្ទីររបស់ កែ ពក លោកយាយត្រូវបានប្រើឲ្យចាប់សរសៃតាំងពីម៉ោង៧រសៀលរហូតដល់ម៉ោង១០យប់ ។ ជួនកាល នៅពេលលោកយាយកំពុងតែសម្រាន្តលក់ ប្រពន្ធរបស់ កែ ពក បានដាស់គាត់ឲ្យភ្ញាក់ឡើងដើម្បីចាប់សរសៃទាំងកណ្តាលអធ្រាត្រ ប្រសិនបើមាននរណាម្នាក់ចុករោយ ។

នៅក្នុងឆ្នាំ១៩៧៥ដដែល កូនប្រុសទាំងពីររបស់លោកយាយ ត្រូវ កែ ពក យកទៅសម្លាប់ដោយកុហកថា យកទៅធ្វើការនៅការិយាល័យមួយ ។ ប៉ុន្តែលោកយាយបានដឹងច្បាស់ថាការស្លាប់របស់កូនប្រុសទាំងពីរគឺដោយសារតែគេចោទប្រកាន់ថាគាត់ជាប់និន្នាការរដ្ឋការចាស់ ។ លោកយាយក៏បានសួរ កែ ពក អំពីករណីចាប់កូនប្រុសទាំងពីររបស់គាត់ដែរ «ថាតើបានយកបុរសកម្សត់ពីរនាក់ទៅនៅឯណា?» កែ ពក បានហាមថា «យាយឯងកុំសួរអី គេមិនប្រាប់យាយឯងទេ កូនយាយឯងគេយកទៅកាន់ប៉ិយរ៉ូហើយ» ។ ចំណែក សុខា ដែលជាកូនស្រីពៅអាចគេចផុតពីស្លាប់ ដោយសារជាប់ទៅធ្វើការតាមកងចល័ត ។

តាមប្រសាសន៍របស់លោកយាយបានឲ្យដឹងទៀតថា នៅក្នុងអំឡុងពេលបម្រើការឲ្យ កែ ពក លោកយាយក៏ធ្លាប់បានហូបបាយជាមួយក្រុមគ្រួសាររបស់ កែ ពក ដែរ ។ ប្រពន្ធរបស់ កែ ពក តែងតែទុកម្ហូបចំណីឲ្យគាត់ ។ លោកយាយប្រាប់ថា «ទាល់តែហូបជាមួយគ្នា ទើបគេថាខ្ញុំឯកភាព បើមិនហូបជាមួយគ្នា គេថាខ្ញុំមិនឯកភាព» ។ ក្នុងចំណោមឆ្មបទាំងអស់ មានតែលោកយាយប៉ុណ្ណោះ ដែល កែ ពក អនុញ្ញាតឲ្យហូបបាយជាមួយ ។

អស់រយៈពេល៣ឆ្នាំ៨ខែ រស់ក្រោមការគ្រប់គ្រងរបស់ កែ ពក លោកយាយតែងតែមានអារម្មណ៍ភ័យបារម្ភ ខ្លាច កែ ពក បញ្ជាឲ្យកូនចៅយកគាត់ធ្វើទារុណកម្មនឹងដែកបាឡងនិងសម្លាប់ចោល ព្រោះថា រាល់ពេលដែល កែ ពក ប្រើឲ្យធ្វើអ្វីម្តងៗ កែ ពក តែងតែព្រមាននិងគំរាមប្រមាថជីវិតគាត់ជានិច្ច ដូចជាក្នុងពេលនិយាយនៅក្នុងសមាជពីរបីដង លោកយាយត្រូវ កែ ពក បង្គាប់ឲ្យនិយាយតែអ្វីដែល កែ ពក ចង់ឲ្យនិយាយប៉ុណ្ណោះ ។ លោកយាយត្រូវ កែ ពក បានគំរាមថា «បើ(និយាយ) មិនត្រូវពិតជាចូលបាវមិនខាន» ។ មានម្តងនោះ ប្រពន្ធរបស់ កែ ពក ឈ្មោះ សឿន បានធ្លាក់ពីលើជណ្តើរទាំងកំពុងមានផ្ទៃពោះ៨ខែ ។ កែ ពក បានគំរាមនឹងសម្លាប់យាយចោល ប្រសិនបើសង្គ្រោះប្រពន្ធនិងកូនគាត់មិនបាន ។ អ្វីដែលធ្វើឲ្យលោកយាយរឹតតែភ័យគឺ គាត់បានបង្កើតកូនពៅរបស់ កែ ពក បានមួយសប្តាហ៍ កូននោះក៏ស្លាប់ (ស្លាប់មិនដឹងមូលហេតុ) ។ លោកយាយបានត្រូវ កែ ពក ស្តីបន្ទោសយ៉ាងច្រើន ប៉ុន្តែមិនបានដាក់ទោសទេ ។ លោកយាយបានមានប្រសាសន៍ថា ជីវិតគាត់នៅពេលនោះប្រៀបដូចជាទឹកនៅក្នុងអំបែងអីចឹង ពេលណាកំពប់គឺទៅហើយមិននៅទេ ។ លោកយាយបានឲ្យដឹងថា ក្នុងចំណោមឆ្មប១០០នាក់ មានតែឆ្មប៨នាក់ប៉ុណ្ណោះ ដែលបានរួចផុតពីសេចក្តីស្លាប់ ។

រាល់ពេលដែល កែ ពក ធ្វើដំណើរទៅខេត្តឆ្ងាយៗ ដូចជាខេត្តកំពង់ចាម ក្រចេះ ឬកំពង់ឆ្នាំង កែ ពក តែងតែនាំលោកយាយទៅតាមជានិច្ច ដើម្បីចាប់សរសៃ ។ ប្រហែលឆ្នាំ១៩៧៧ លោកយាយបានត្រូវ កែ ពក ដឹកទៅប៉េកាំងស្នាក់នៅចំនួន៩ថ្ងៃ ដើម្បីចាប់សរសៃឲ្យប្រពន្ធៗរបស់ថ្នាក់ដឹកនាំចិន ។ លោកយាយប្រាប់ថា គាត់បានចាប់សរសៃឲ្យប្រពន្ធថ្នាក់ដឹកនាំចិនចំនួន១៥នាក់ ។

ឆ្នាំ១៩៧៩ លោកយាយបានរត់ទៅជាមួយក្រុមគ្រួសាររបស់ កែ ពក ។ ប៉ុន្តែ លោកយាយក៏បានរត់ត្រឡប់មកមន្ទីរវិញ ។ កែ ពក បានប្រើកូនចៅពីរនាក់ឲ្យជិះម៉ូតូតាមមកយកលោកយាយត្រឡប់ទៅវិញ ។ លោកយាយនិងក្រុមគ្រួសាររបស់ កែ ពក បានរត់ទៅពួននៅក្នុងល្អាងភ្នំចំនួនបីថ្ងៃ ។ លោកយាយក៏បានសម្រេចចិត្តសុំ កែ ពក ត្រឡប់មកក្រោយតែម្នាក់ឯង ដើម្បីមកជួបជុំប្តីនិងកូន ។

ប្រាំឆ្នាំក្រោយពីរបបខ្មែរក្រហមរលំរលាយក្អែកលោក

យាយរកកលងងឹត ។ លោកយាយឈឺភ្នែកពេញមួយឆ្នាំ ។ មកដល់ឆ្នាំ១៩៨៥ ភ្នែកទាំងគូរបស់លោកយាយក៏ងងឹតសូន្យឈឹង មើលអ្វីលែងឃើញទាំងអស់ ព្រមទាំងបែកគ្រាប់ភ្នែកខាងឆ្វេង ។ សព្វថ្ងៃនេះលោកយាយមានជំងឺបេះដូង ហើយព្យាបាលដោយថ្នាំគ្រាប់ទិញមកពីផ្សារនៅក្បែរផ្ទះលោកយាយ ។ ដូច្នេះបន្ទុកគ្រួសារត្រូវធ្លាក់ទៅលើ សួស សុខា ។ សុខា សម្រេចចិត្តថាមិនយកប្តីទេ សុខចិត្តនៅទំនេរដើម្បីមានពេលវេលាគ្រប់គ្រាន់មើលការខុសត្រូវរៀបចំផ្ទះសម្បែង ជាពិសេសថែទាំម្តាយចាស់ជរា ។ សុខា ឆ្លៀតពេលប្រកបរបរលក់ដូរនំចំណីនិងផ្លែឈើកំប៉ិកកំប៉ុកនៅក្នុងសាលារៀនបានប្រាក់កាសបន្តិចបន្តួចផ្សំបង្គ្រប់ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ។ សុខា បានចាំរឿងរ៉ាវខ្លះៗ ប្រហែលឆ្នាំ១៩៧៨ សុខា ធ្លាប់បានឃើញខ្មែរក្រហមបណ្តើរមនុស្សទាំងខ្សែៗយកទៅសម្លាប់ ។ សុខា បានគាំទ្រឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់តាមថ្នាក់ៗ ។ សុខា និយាយថា “អ្នកលើបញ្ជាបានជាអ្នកក្រោមធ្វើ ហើយអ្នកក្រោមមានពេលខ្លះ ធ្វើលើសបញ្ជាទៅទៀត” ។ ចំពោះលោកយាយវិញ បានមានប្រសាសន៍ថា អំពើរបស់ខ្មែរក្រហមធ្វើនេះមិនត្រឹមត្រូវទេ ដូចជាថា កែ ពក បានព្រមានគាត់ថា “បើអ្នកណាមករកអ៊ីប្តូឲ្យធ្វើអ៊ីកុំឲ្យយាយមាត់ចាំគេមានមតិវិញ” ហើយកាលណោះលោកយាយបានឆ្លើយវិញថា “ម៉េចក៏មិត្តនិយាយអីចឹង មិនដាក់ស្តែងជាមួយប្រជាជនទេដួយអ្នកក្រីក្រផង” ។



ប្រដាប់ប្រដាប្រើប្រាស់របស់លោកយាយ

ទោះបីជាដឹងថា កូនប្រុសទាំងពីររបស់លោកយាយត្រូវ កែ ពក សម្លាប់ក៏ដោយ ក៏អារម្មណ៍របស់លោកយាយមិនខឹងសម្បាចំពោះ កែ ពក ដែរ ។ នៅពេលដែលយើងប្រាប់ថា កែ ពក ស្លាប់ លោកយាយរន្ធត់ចិត្តយ៉ាងខ្លាំង ។ លោកយាយបានប្រាប់ថា គាត់គោរពភាពស្មោះត្រង់និងការសម្រេចចិត្តរបស់ កែ ពក ណាស់ ប៉ុន្តែគាត់ស្អប់ កែ ពក ត្រង់ថាជាមនុស្សសាហាវគ្មានទិសតំបន់។ កែ ពក ធ្លាប់ជេរប្រទេចផ្តាសាលោកយាយរហូតដល់ម្តាយទៀតផង ។ លោកយាយចង់ឲ្យមានតុលាការមួយជួយរកយុត្តិធម៌ឲ្យកូនប្រុសទាំងពីររបស់គាត់និងជនរងគ្រោះកម្ពុជាច្រើនលាននាក់ទៀតដែលបានស្លាប់ និងកំពុងរង់ចាំទទួលយកការពិតយ៉ាងអន្ទះសារ និងប្រកបដោយក្តីព្រួយបារម្ភពីវិយរបស់ខ្លួនដែលកាន់តែជរាទៅៗ ។ លោកយាយបានពោលបញ្ចប់សេចក្តីទាំងទឹកមុខក្រៀមក្រំថា “ម្តាយចង់ឃើញយុត្តិធម៌មុនពេលដែលម្តាយលាចាកលោកទៅដោយបិទភ្នែកជិត” ។



**លី សុផល និង ស្វ ប៊ុនស៊ូ**



# សៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់

(អត្ថបទសង្ខេប)

**ថ្ងៃពុធ ទី២៩ ខែមីនា ឆ្នាំ១៩៤៤**

*ឃីធី សម្លាញ់,*

*លោក បូលខេស្តេន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី បាននិយាយនៅតាមវិទ្យុផ្សាយភាសាហុល្លង់ពីក្រុងឡុងដ៍ថា បន្ទាប់ពីសង្គ្រាមចប់ហើយ នឹងមានការប្រមូលសៀវភៅកំណត់ហេតុនិងសំបុត្រទាំងអស់ដែលទាក់ទងទៅនឹងសង្គ្រាម ។ មនុស្សគ្រប់គ្នាក៏ចាប់អារម្មណ៍ភ្លាមដល់សៀវភៅកំណត់ហេតុរបស់ខ្ញុំ ។ ចូរឯងគិតទៅមើល ថាតើវាគួរឲ្យចាប់អារម្មណ៍យ៉ាងណា ដែលបោះពុម្ពសៀវភៅរឿងប្រលោមលោកស្តីអំពីអគារបន្ថែមសម្ងាត់ ។ គ្រាន់តែចំណងជើងនោះ វានឹងធ្វើឲ្យមនុស្សយើងគិតថាវាជារឿងស៊ើបអង្កេតទៅហើយ ។*

*ខ្ញុំនិយាយមែនណ៎! ដប់ឆ្នាំក្រោយសង្គ្រាម មនុស្សនឹងយល់ឃើញថាវាពិតជាគួរឲ្យសប្បាយមែនដែលបានដឹងថា យើងបានរស់នៅយ៉ាងដូចម្តេច យើងញ៉ាំអ្វី ហើយយើងនិយាយអ្វីក្នុងនាមជាជនជាតិជ្វីហ្វដែលកំពុងតែលាក់ខ្លួន ។ ទោះបីខ្ញុំនិយាយប្រាប់ឯងអំពីជីវិតរបស់យើងច្រើនហើយក៏ដោយ ក៏ឯងដឹងតិចតួចប៉ុណ្ណោះអំពីយើង ។ ស្ត្រីភ័យខ្លាចយ៉ាងណានៅពេលមានការវាយឆ្មក់តាមផ្លូវអាកាស ។ ឧទាហរណ៍ កាលពីថ្ងៃអាទិត្យមុន នៅពេលយន្តហោះអង់គ្លេសចំនួន៣៥០គ្រឿងទម្លាក់គ្រាប់ចំនួន៥៥០តោនទៅលើ អាយយេមូឌេន រហូតដល់ទៅធ្វើឲ្យផ្ទះសម្បែងរង្គើដូចស្មៅរេរាំនៅពេលត្រូវកម្លាំងខ្យល់បក់ ។ អូ៎! មានជំងឺរាតត្បាតច្រើនប៉ុនណាកំពុងរាលដាលនៅទីនេះ ។*

*ឯងមិនបានដឹងអ្វីទេអំពីបញ្ហានេះ ហើយវានឹងត្រូវការឲ្យខ្ញុំចំណាយពេលមួយថ្ងៃពេញដើម្បីពិពណ៌នាអំពីរឿងនេះឲ្យលម្អិតបំផុត ។ ប្រជាជនត្រូវឈរជាជួរដើម្បីទិញបន្លែនិងទំនិញគ្រប់ប្រភេទ ។ វេជ្ជបណ្ឌិតមិនអាចមកមើលអ្នកជំងឺរបស់ខ្លួនបានព្រោះរថយន្តនិងទោចក្រយានត្រូវបានលួចនៅពេលដែលពួកគេបែរខ្នង ។ ចោរគាស់ផ្ទះនិងចោរលួចមានច្រើនណាស់ រហូតដល់ឯងអាចចោទសួរខ្លួនឯងថា តើមានអ្វីចូលមកសណ្ឋិតនៅក្នុងខ្លួនរបស់ជនជាតិហុល្លង់ បានជាគេមានដៃវែងលួចរបស់គេបែបនេះ ។ ក្មេងតូចៗ អាយុប្រាំបីនិងដប់មួយឆ្នាំ វាយបំបែកបង្អួចផ្ទះប្រជាជន ហើយលួចអ្វីៗគ្រប់យ៉ាងដែលគេអាចលូកដៃយកបាន ។ ប្រជាជនមិនហ៊ានចាកចេញពីផ្ទះឲ្យបានប្រាំនាទីទេ ព្រោះគេនឹងត្រូវវិលត្រឡប់មកផ្ទះវិញ ហើយឃើញទ្រព្យសម្បត្តិរបស់ពួកគេបាត់អស់រលីង ។ ជារៀងរាល់ថ្ងៃ កាសែតបានចុះផ្សាយសេចក្តីជូនដំណឹងផ្តល់រង្វាន់សម្រាប់ការប្រគល់ឲ្យវិញនូវម៉ាស៊ីនវាយអង្គុលីលេខ កម្រាលព្រំប្រពៃណី នាឡិកាអគ្គិសនី និងក្រណាត់ ។ល ។ នាឡិកាអគ្គិសនីនៅតាមកាច់ជ្រុងផ្លូវត្រូវបានគេដកចេញ ទូរស័ព្ទសាធារណៈក៏ត្រូវបានគេដោះគ្រឿងចេញនៅសល់តែខ្សែ ។*

*សីលធម៌នៅក្នុងចំណោមប្រជាជនហុល្លង់អាចមិនល្អទេ ។ មនុស្សគ្រប់គ្នាស្រេកឃ្លានអាហារ ។ លើកលែងតែកាកកាហ្វេចេញ របបអាហារសម្រាប់រយៈពេលមួយសប្តាហ៍ មិនអាចគ្រប់បានពីរថ្ងៃទេ ។ ការឈ្លានពានបានចូលមកដល់យូរហើយ មនុស្សប្រុសត្រូវបានគេដឹកតាមកប៉ាល់ចេញទៅប្រទេសអាល្លឺម៉ង់ ។ កុមារមានជំងឺឬក៏ខ្វះខាតអាហារូបត្ថម្ភ ។ មនុស្សគ្រប់គ្នាស្លៀក*

សម្លៀកបំពាក់រហែក និងស្បែកជើងសឹករេច ។ ស្រោមជើងមួយគូមានតម្លៃ៧,៥០ហ្គីលដឺនៅទីផ្សារងងឹត ។ ក្រៅពីនេះ ជាងស្បែកជើងពីរបីនាក់នឹងជួសជុល ប្តុក៏បើគេធ្វើ អ្នកត្រូវតែរង់ចាំរហូតរយៈពេលបួនខែ ទើបអ្នកអាចយកស្បែកជើងបាន ដែលប្រហែលជាវាបាត់ទៅហើយនៅក្នុងពេលនោះ ។ មានរឿងល្អមួយលេចចេញពីរឿងនេះ ។ នៅពេលស្ថានភាពអាហារកាន់តែអាក្រក់ ហើយក្រឹត្យច្បាប់កាន់តែធ្ងន់ធ្ងរនោះ សកម្មភាពវិទ្ធង្សនាប្រឆាំងអាជ្ញាធរកំពុងតែកើនឡើង ។ គណៈកម្មការរបបអាហារ ប៉ូលិស និងមន្ត្រី បានទាំងជួយនិងរិះគន់ពលរដ្ឋរបស់ខ្លួន ហើយបញ្ជូនពួកគេចូលគុក ។ សំណាងល្អប្រជាជនហូល្លង់មួយចំនួនតូចប៉ុណ្ណោះដែលដើរផ្លូវខុស ។

**ថ្ងៃពុធ ទី៥ ខែមេសា ឆ្នាំ១៩៤៤**

ឃីធី សម្លាញ់,

អស់រយៈពេលយូរមកហើយរហូតមកទល់ពេលនេះ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាខ្ញុំនៅតែខំធ្វើកិច្ចការសាលា ។ សង្គ្រាមហាក់ដូចនៅពេលយូរទៀតមុននឹងចប់ ។ ពាក្យថា សង្គ្រាមផុតរលត់ហាក់ដូចជាមិនពិតសោះ ហើយប្រៀបដូចជារឿងព្រេងអ៊ីចឹង ។ បើដល់ខែកញ្ញាហើយសង្គ្រាមនៅតែមិនទាន់ចប់ទៀត ខ្ញុំនឹងមិនវិលត្រឡប់ទៅរៀនទេ ព្រោះខ្ញុំមិនចង់ខកពីរឆ្នាំឡើយ ។

ដិតធ័រ ចូលមកពេញគ្រប់ពេលវេលារបស់ខ្ញុំ ។ ក្នុងគំនិតនិងការយល់សប្តិរបស់ខ្ញុំ គ្មានអ្វីផ្សេងក្រៅពី ដិតធ័រ ទេ រហូតដល់យប់ថ្ងៃសៅរ៍ ពេលខ្ញុំវេទនាខ្លាំង ។ អ៊ូ! វាគួរឲ្យខ្លាចមែន ។ ខ្ញុំទប់ទឹកភ្នែកនៅពេលខ្ញុំនៅជាមួយ ដិតធ័រ, សើចយ៉ាងក្អាកក្អាយជាមួយគ្រួសារ វ៉ាន់ ដាអាន, នៅពេលយើងផឹកទឹកក្រូចឆ្មារ ហើយខ្ញុំសប្បាយរីករាយនិងរំភើបចិត្ត ប៉ុន្តែខ្ញុំដឹងថា ពេលខ្ញុំនៅម្នាក់ឯង ខ្ញុំនឹងយំឡើងហើមភ្នែក ។ ខ្ញុំអង្គុយនៅលើកម្រាលឥដ្ឋនៅក្នុងសម្លៀកបំពាក់គេងយប់ ចាប់ផ្តើមបួងសួងយ៉ាងអន្ទះអន្ទែង ។ បន្ទាប់មក ខ្ញុំអង្គុយត្របោមក្បាលជង្គង់នៅលើឥដ្ឋដាក់ក្បាលលើដៃហើយស្រែកយំ ។ សំឡេងខ្សឹកខ្សួលដ៏លាន់ឮបាននាំខ្ញុំឲ្យធ្លាក់នរកជាថ្មី ។ ខ្ញុំប្រឹងទប់ទឹកភ្នែក ព្រោះខ្ញុំមិនចង់ឲ្យនរណាម្នាក់ដែលនៅក្បែរៗនេះបានឮខ្ញុំយំទេ ។ ខ្ញុំព្យាយាមទាញខ្លួនខ្ញុំចូលគ្នា ហើយនិយាយម្តងហើយម្តងទៀត "ខ្ញុំត្រូវតែ ខ្ញុំត្រូវតែ ខ្ញុំត្រូវតែ..." ។ ដោយឈឺសាច់ដុំបណ្តាលមកពីការអង្គុយបែបចម្លែកនេះ ខ្ញុំក៏ផ្អែកខ្លួនខ្នងទល់នឹងគែមគ្រែ រហូតដល់ម៉ោងដប់និងសាមសិបនាទី ទើបឡើងដេកលើគ្រែ ។ វាចប់ហើយ!

ឥឡូវនេះវាពិតជាចប់អស់ហើយ ។ ទីបំផុតខ្ញុំដឹងថា ខ្ញុំត្រូវតែធ្វើកិច្ចការសាលាដែលគ្រូដាក់ឲ្យ ដើម្បីកុំឲ្យខ្លួនខ្ញុំល្ងង់ខ្លៅ ដើម្បីឲ្យមានជោគជ័យនៅក្នុងជីវិត និងដើម្បីក្លាយខ្លួនជាអ្នកកាសែត ព្រោះអ្វីទាំងនោះហើយដែលខ្ញុំចង់បាន! ខ្ញុំដឹងថាខ្ញុំអាចនិពន្ធបាន ។ រឿងរបស់ខ្ញុំមួយចំនួនតូចមានស្នាដៃល្អ ។ ការពិពណ៌នារបស់ខ្ញុំអំពីអគារបន្ថែមគួរឲ្យចង់សើចណាស់ ។ សៀវភៅកំណត់ហេតុរបស់ខ្ញុំភាគច្រើនមានលក្ខណៈរស់រវើកនិងក្លៀវក្លា ប៉ុន្តែ...យើងត្រូវរង់ចាំមើលសិន ថាតើខ្ញុំពិតជាមានទេពកោសល្យឬយ៉ាងណា ។

"សុបិនរបស់ អេវ៉ា" គឺជារឿងព្រេងនិទានល្អបំផុតរបស់ខ្ញុំ ហើយរឿងដ៏ចម្លែកនោះគឺថា ខ្ញុំមិនដឹងបន្តិចណាសោះថាវាមកពីណា ។ ភាគខ្លះនៃរឿង "ជីវិតរបស់ យេឌី" ក៏ល្អដែរ ប៉ុន្តែ សាច់រឿងទាំងមូលមិនមានអ្វីពិសេសទេ ។ ខ្ញុំគឺជាអ្នករិះគន់ល្អនិងតឹងតែងបំផុតចំពោះខ្លួនឯង ។ ខ្ញុំដឹងអ្វីដែលល្អនិងអ្វីដែលមិនល្អ ។ ដរាបណាឯងមិនសរសេរដោយខ្លួនឯងទេ ឯងមិនដឹងថាវាអស្ចារ្យដល់ថ្នាក់ណាទេ ។ ខ្ញុំធ្លាប់តែសោកសៅចំពោះការពិតដែលថាខ្ញុំមិនអាចគូររូបបាន ប៉ុន្តែឥឡូវនេះ ខ្ញុំសប្បាយយ៉ាងលើសលប់ដែលខ្ញុំអាចនិពន្ធបាន ។ បើខ្ញុំគ្មានទេពកោសល្យសរសេរសៀវភៅ ឬក៏អត្ថបទកាសែតទេ ខ្ញុំអាចសរសេរសម្រាប់ខ្លួនឯងបាន ។ ប៉ុន្តែ ខ្ញុំចង់សម្រេចច្រើនជាងនេះ ។ ខ្ញុំមិនអាចនឹកគិតថាត្រូវរស់នៅដូចជាម៉ាក់ លោកស្រី វ៉ាន់ ដាអាន និងស្ត្រីឯទៀតៗ ដែលនៅវិលវល់តែនឹងការងាររបស់ខ្លួន ហើយក្រោយមកក៏បំភ្លេចវាចោលនោះទេ ។ ខ្ញុំត្រូវការលះបង់ខ្លួនសម្រាប់អ្វីផ្សេងទៀតក្រៅពីស្វាមីនិងកូន! ខ្ញុំមិនចង់រស់នៅឥតប្រយោជន៍ដូចមនុស្សភាគច្រើនទេ ។ ខ្ញុំចង់ធ្វើជាមនុស្សមានប្រយោជន៍ ដែលនាំការសប្បាយរីករាយដល់មនុស្សទាំងអស់ ទោះបីខ្ញុំមិនធ្លាប់បានជួបអ្នកទាំងនោះក្តី ។ ខ្ញុំចង់នៅរស់តទៅទៀត ទោះបីជាជីវិតរបស់ខ្ញុំបានស្លាប់ទៅហើយក្តី! ហេតុដូច្នេះហើយ បានជាខ្ញុំដឹងគុណដល់ព្រះជាម្ចាស់ដែលប្រទានមកឲ្យខ្ញុំនូវអំណោយដែលខ្ញុំអាចប្រើប្រាស់ដើម្បីអភិវឌ្ឍខ្លួនឯង ហើយថ្លែងចេញមកនូវអ្វីទាំងអស់ដែលនៅក្នុងខ្លួនខ្ញុំ! ។

*នៅពេលខ្ញុំសរសេរ ខ្ញុំអាចជម្រុះចោលរាល់ការគិតរបស់ខ្ញុំ ។ ទុក្ខសោកសង្រេងរបស់ខ្ញុំរលាយបាត់ ហើយស្មារតីរបស់ខ្ញុំរស់រវើកឡើងវិញ! ប៉ុន្តែ តើខ្ញុំនឹងអាចសរសេរអ្វីមួយដែលអស្ចារ្យបានទេ? តើខ្ញុំនឹងក្លាយជាអ្នកកាសែតឬក៏អ្នកនិពន្ធម្នាក់បានទេ? នោះគឺជាបញ្ហាដ៏ធំ ។*

*សង្ឃឹមដូច្នេះចុះ ។ អូ៎! ខ្ញុំសង្ឃឹមដូច្នេះខ្លាំងណាស់ ព្រោះការសរសេរអាចឲ្យខ្ញុំកត់ត្រាអ្វីគ្រប់យ៉ាង គំនិតទាំងអស់របស់ខ្ញុំ គតិបណ្ឌិតរបស់ខ្ញុំ និងក្តីស្រមៃរបស់ខ្ញុំ ។*

*ខ្ញុំមិនបានសរសេររឿង "ជីវិតរបស់ យេឌី" អស់រយៈពេលជាយូរហើយ ។ នៅក្នុងគំនិតខ្ញុំ ខ្ញុំបានរៀបចំផែនការអ្វីដែលនឹងកើតឡើងនៅពេលក្រោយ ប៉ុន្តែ សាច់រឿងហាក់ដូចជាមិនសូវស៊ីគ្នាណាស់ណាទេ ។ ខ្ញុំប្រហែលជាមិនបញ្ចប់ទេ ។ នៅទីបំផុត វានឹងត្រូវបោះចោលទៅក្នុងធុងសំរាម ឬក៏ទៅក្នុងឡ ។ នោះជាគំនិតមួយគួរឲ្យខ្លាច ប៉ុន្តែក្រោយមក ខ្ញុំនិយាយតែម្នាក់ឯងថា "នៅអាយុដប់បួនឆ្នាំ ហើយមានបទពិសោធន៍តិចតួចដូចនេះ អ្នកមិនអាចសរសេរអំពីទស្សនវិជ្ជាទេ" ។*

*ដូច្នេះ ទៅមុខទៀត ដោយមានគំនិតថ្មីៗទៀត វានឹងមានការរីកចម្រើន ព្រោះខ្ញុំប្តេជ្ញាចិត្តសរសេរហើយ! ។*

**ថ្ងៃពុធ ទី៣ ខែឧសភា ឆ្នាំ១៩៤៤**

*ឃីធី សម្លាញ់,*

*ដំបូងគឺដំណឹងផ្សេងៗប្រចាំសប្តាហ៍! ដំណឹងនយោបាយលែងនិយាយ គ្មាននិយាយអ្វីទាំងអស់ ហើយខ្ញុំក៏គ្មានអ្វីដើម្បីរាយការណ៍ដែរ ។ ខ្ញុំកំពុងចាប់ផ្តើមជឿបណ្តើរៗថា ការចូលឈ្លានពាននឹងកើតមាន ។ ជាងនេះទៀត គេមិនអាចទុកឲ្យពួករុស្ស៊ីធ្វើការងារមិនល្អទាំងអស់ដោយផ្ទាល់ទេ ។ តាមពិតទៅ ពួករុស្ស៊ីមិនបានធ្វើអ្វីដែរនៅពេលនេះ ។*

*ពេលនេះ លោក ក្លេម៉ង់ មកការិយាល័យជារៀងរាល់ព្រឹក ។ គាត់បានទិញរ៉ឺស្ស័រថ្មីសម្រាប់ដាក់កៅអីវែងរបស់ដិតធ័រ ។ ដូច្នេះ ដិតធ័រ ត្រូវញាត់ដាក់រ៉ឺស្ស័រចូលក្នុងកៅអីវែងនោះឡើងវិញ ។ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ គាត់មិនមានអារម្មណ៍អ្វីទាល់តែសោះ ។ លោក ក្លេម៉ង់ ក៏បាននាំយកមកនូវម្សៅកម្ចាត់ចៃខ្លះសម្រាប់ឆ្មាដែរ ។*

*តើខ្ញុំបានប្រាប់ឯងហើយឬនៅ ថាឆ្មា បូច បានបាត់ខ្លួន? យើងមិនឃើញវាសោះចាប់តាំងពីថ្ងៃព្រហស្បតិ៍មុន ។ វាប្រហែលជាទៅដល់ឋានសួគ៌ឆ្មាបាត់ហើយ ខណៈដែលអ្នកចូលចិត្តសាច់សត្វបានយកវាទៅធ្វើម្ហូបដ៏ឆ្ងាញ់នោះ ។ ប្រហែលជាស្រ្តីមានលុយម្នាក់អាចទិញវាបាន ហើយកំពុងតែពាក់មួកធ្វើអំពីស្បែកនិងរោមរបស់វាផងក៏មិនដឹង ។ ដិតធ័រ ត្រូវធ្វើឲ្យព្រួយចិត្តនឹងរឿងនេះយ៉ាងខ្លាំង ។*

*តាំងពីពីរសប្តាហ៍មកនេះ យើងញ៉ាំអាហារថ្ងៃត្រង់នៅវេលាម៉ោងដប់មួយនិងសាមសិបនាទីនៅរាល់ថ្ងៃសៅរ៍ ។ នៅពេលព្រឹក យើងត្រូវតែញ៉ាំទឹកធញ្ញជាតិក្តៅមួយពែង ។ ចាប់ពីថ្ងៃស្អែក វានឹងដូចនេះជារៀងរាល់ថ្ងៃ ។ ប្រការនេះវាជួយសន្សំអាហារយើងបានមួយពេល ។ បន្លែក៏ពិបាករកណាស់ដែរ ។ នៅរសៀលនេះ យើងញ៉ាំសាលាដរលួយដែលយកទៅស្ងោរ ។ មានតែសាលាដធម្មតា ស្ពៃអេពីណានិងសាលាដស្ងោរប៉ុណ្ណោះ គ្មានអ្វីក្រៅពីហ្នឹងទេ ។ បន្ថែមពីលើនោះមានដំឡូងរលួយទៀត ហើយឯងមានអាហារដែលសមស្របសម្រាប់ស្តេចមួយអង្គ! ។*

*តាំងពីជាងពីរខែមកហើយដែលខ្ញុំបាត់រដូវ ទីបំផុត វាបានចាប់ផ្តើមមានកាលពីថ្ងៃអាទិត្យមុន ។ ទោះបីមានការឈឺចាប់និងរំខាន ក៏ខ្ញុំសប្បាយដែរដែលវាមិនបោះបង់ខ្ញុំចោល ។*

*ដូចឯងអាចស្រមៃដោយគ្មានពិភាល់អ៊ីចឹង យើងតែងតែនិយាយជាញឹកញាប់នៅទីនេះប្រកបដោយការអស់សង្ឃឹមៈ "តើសង្រ្គាមមានប្រយោជន៍អ្វី? ហេតុអ្វី អូ៎! ហេតុអ្វីបានជាមនុស្សមិនអាចរស់នៅជាមួយគ្នាដោយសុខសន្តិភាព? ហេតុអ្វីក៏មានការបំផ្លាញទាំងនេះ?" ។*

*សំណួរនេះអាចយល់បាន ប៉ុន្តែរហូតមកដល់ពេលនេះ គ្មាននរណារកឃើញចម្លើយដែលគួរឲ្យពេញចិត្តទេ ។ ហេតុអ្វីអង់គ្លេសផលិតយន្តហោះនិងគ្រាប់បែកកាន់តែធំឡើងៗ និងកាន់តែល្អឡើង ហើយក្នុងពេលដំណាលគ្នានេះបែរជាទម្លាក់គ្រាប់បែកកម្ទេចទ្រព្យសម្បត្តិទៅវិញ? ហេតុអ្វីលុយរាប់លានត្រូវចំណាយទៅលើសង្គ្រាមជារៀងរាល់ថ្ងៃ ខណៈដែលសូម្បីតែលុយមួយសេនក៏រកមិនបានផង សម្រាប់វិទ្យាសាស្ត្រវេជ្ជសាស្ត្រសម្រាប់សិល្បករ ឬអ្នកក្រីក្រនោះ? ហេតុអ្វីមនុស្សយើងត្រូវ*

*អត់ឃ្លាននៅពេលដែលអាហារច្រើនគរគោកកំពុងតែស្អុយរលួយចោលនៅទីកន្លែងផ្សេងទៀតនៃពិភពលោក ។ អ្ហូ! មនុស្សលោកអីក៏ឆ្កួតខ្លាំងម៉្លេះ?*

*ខ្ញុំមិនជឿថា សង្គ្រាមគ្រាន់តែជាការងាររបស់អ្នកនយោបាយ ឬអ្នកមូលធននិយមទេ ។ អ្ហូ!ទេ មនុស្សគ្រប់រូបសុទ្ធតែមានកំហុសមួយចំណែកដែរ ។ បើពុំនោះទេ ប្រជាជននិងប្រជាជាតិក្រោកឡើងបះបោរយូរមកហើយ! ក្នុងខ្លួនមនុស្សមានតែសេចក្តីត្រូវការបំផ្លិចបំផ្លាញមួយ សេចក្តីត្រូវការវាយសម្លាប់មួយ និងសប្បាយភ្លើតភ្លើនប្រើអំពើហិង្សាប៉ុណ្ណោះ ។ ដរាបណាមនុស្សជាតិទាំងមូលគ្មានការលើកលែង មិនធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងធំមួយទេ ដរាបនោះសង្គ្រាមនឹងត្រូវបន្តធ្វើ ហើយអ្វីៗទាំងអស់ដែលត្រូវបានកសាងឡើងយ៉ាងយកចិត្តទុកដាក់ ដាំដុះនិងរីកលូតលាស់នោះ នឹងត្រូវផ្តាច់ផ្តិលនិងបំផ្លាញខ្ទេចខ្ទី ហើយទីបំផុតត្រូវបង្កើតវិញដដែល! ។*

*ជាញឹកញាប់ខ្ញុំពិបាកចិត្ត ប៉ុន្តែមិនអស់សង្ឃឹមទេ ។ ខ្ញុំសម្លឹងមើលឃើញជីវិតរបស់យើងនៅក្នុងកន្លែងលាក់ខ្លួន ថាជាការផ្សងព្រេងប្រកបដោយគ្រោះថ្នាក់ដែលពោរពេញទៅដោយភាពងប់ងុលនិងគួរឲ្យចាប់អារម្មណ៍ ។ ក្នុងសៀវភៅកំណត់ហេតុរបស់ខ្ញុំ ខ្ញុំចាត់ទុករាល់កង្វះនីមួយៗ គឺជាប្រភពនៃគ្រឿងសប្បាយរបស់ខ្ញុំ ។ ខ្ញុំបានសម្រេចចិត្តរស់នៅតាមជីវិតផ្សេងពីក្មេងស្រីដទៃ ហើយមិនធ្វើជាមេផ្ទះសាមញ្ញធម្មតានៅពេលក្រោយមកទៀតទេ ។ អ្វីដែលខ្ញុំកំពុងជួបប្រទះនៅទីនេះ គឺការចាប់ផ្តើមដ៏ល្អមួយឆ្ពោះទៅរកជីវិតគួរឲ្យចាប់អារម្មណ៍ ។ នោះគឺជាហេតុផលតែមួយគត់ដែលខ្ញុំត្រូវសើចចំពោះរឿងក្រមាច់កំប្លែងនៅក្នុងពេលវេលាដ៏គ្រោះថ្នាក់បំផុតនេះ ។*

*ខ្ញុំនៅក្មេងហើយមានលក្ខណៈសម្បត្តិលាក់លៀមជាច្រើន ។ ខ្ញុំនៅក្មេងហើយខ្លាំង និងរស់នៅឆ្លងកាត់ការផ្សងព្រេងដ៏ធំមួយ ។ ខ្ញុំស្ថិតនៅកណ្តាលស្ថានភាពបែបនេះតែម្តង ហើយខ្ញុំមិនអាចចំណាយពេលពេញមួយថ្ងៃរអ៊ូរទាំបានទេ ពីព្រោះវាមិនអាចមានការសើចសប្បាយណាមួយឡើយ! ខ្ញុំមានសំណាងដែលមានអ្វីជាច្រើនៈ សុភមង្គល លក្ខណៈសម្បត្តិរីករាយពីធម្មជាតិ និងកម្លាំងចិត្ត ។ ជារៀងរាល់ថ្ងៃ ខ្ញុំមានអារម្មណ៍ថាខ្លួនឯងចាស់ទុំ ។ ខ្ញុំមានអារម្មណ៍ថា ការរំដោះខិតចូលមកដល់ ខ្ញុំមានអារម្មណ៍ពីសម្រស់ធម្មជាតិនិងគុណធម៌ល្អរបស់មនុស្សនៅជុំវិញខ្លួនខ្ញុំ ។ ជារៀងរាល់ថ្ងៃខ្ញុំគិតថា នេះគឺជាការផ្សងព្រេងគួរឲ្យចាប់អារម្មណ៍និងសប្បាយអ្វីម៉្លេះទេ! ដោយមានអារម្មណ៍បែបនេះទៅហើយ ហេតុអ្វីក៏ខ្ញុំត្រូវអស់សង្ឃឹម?*

**ថ្ងៃច័ន្ទ ទី២២ ខែឧសភា ឆ្នាំ១៩៤៤**

*ឃីធី សម្លាញ់,*

*កាលពីថ្ងៃទី២០ ខែឧសភា ប៉ាបានភ្លាល់ចាញ់ ហើយត្រូវឲ្យទឹកដោះគោជូរប្រាំក្រឡទៅលោកស្រី វ៉ាន់ ដាអាន ។ ការចូលឈ្លានពានមិនទាន់ចាប់ផ្តើមនៅឡើយ ។ ខ្ញុំអាចនិយាយមិនខុសឡើយថា ទីក្រុងអាមស្ទឺដាមទាំងមូល ប្រទេសហូល្លង់ទាំងមូលតាមពិតទៅនោះ តំបន់សមុទ្រខាងលិចទាំងមូលនៃទ្វីបអឺរ៉ុប រហូតដល់ប្រទេសអេស្ប៉ាញ កំពុងតែនាំគ្នានិយាយអំពីការឈ្លានពានទាំងថ្ងៃទាំងយប់ ជជែកវែកញែក ភ្នាល់គ្នានិង...សេចក្តីសង្ឃឹម ។*

*អារម្មណ៍តានតឹងបានឡើងដល់កម្រិតខ្លាំងបំផុត ។ មនុស្សគ្រប់គ្នាដែលយើងគិតថាជាប្រជាជនហូល្លង់ដ៏ល្អនោះ មិនមានជំនឿចំពោះពួកអង់គ្លេសទាល់តែសោះ ។ គេគ្រប់គ្នាមិនគិតថាការសម្តែងរបស់អង់គ្លេសជាចំណាត់ការស្ទាហាប់នោះទេ ។ អ្ហូទេ! ប្រជាជនត្រូវការសកម្មភាពពិតៗ គឺសកម្មភាពក្លាហាននិងអស្ចារ្យ ។*

*លែងមាននរណាម្នាក់មើលឃើញហួសពីចុងច្រមុះរបស់ខ្លួនទៀតហើយ ។ គ្មាននរណាម្នាក់ផ្តល់គំនិតចំពោះការពិតដែលថាពួកអង់គ្លេសកំពុងតែប្រយុទ្ធដើម្បីប្រទេសនិងប្រជាជនរបស់ពួកគេផ្ទាល់នោះឡើយ ។ មនុស្សគ្រប់គ្នាគិតថា វាជាភារកិច្ចរបស់អង់គ្លេស ដែលត្រូវសង្គ្រោះហូល្លង់ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ តើពួកអង់គ្លេសមានកាតព្វកិច្ចអ្វីទៅចំពោះពួកយើង? តើជនជាតិហូល្លង់ធ្វើអ្វីខ្លះដើម្បីឲ្យស័ក្តិសមនឹងទទួលជំនួយសប្បុរសដែលពួកគេកំពុងតែសង្ឃឹមយ៉ាងច្បាស់ក្រឡែតនោះ? អ្ហូទេ! ប្រជាជនហូល្លង់យល់ច្រឡំធំណាស់ ។ បើទុកជាមានការសម្តែងគំរាមរបស់ពួកអង់គ្លេសក៏ដោយ ក៏ពួកគេពិតជាគ្មានអ្វីត្រូវបន្ទោសពីរឿងសង្គ្រាមច្រើនជាងប្រទេសដទៃទៀតទាំងតូចទាំងធំ ដែលបច្ចុប្បន្នត្រូវកាន់កាប់ដោយអាល្លឺម៉ង់ឡើយ ។ ពួកអង់គ្លេសនឹងមិនបង្ហាញឲ្យឃើញការសុំទោសរបស់ពួកគេទេ ។*

ជាការពិតហើយ ពួកគេបានសម្ងំស្ងៀមក្នុងរយៈពេលជាច្រើនឆ្នាំ ពេលដែលពួកអាល្លឺម៉ង់កំពុងតែបំពាក់អាវុធទំនើបៗឲ្យកងទ័ពរបស់ខ្លួន ប៉ុន្តែប្រទេសទាំងអស់ផ្សេងទៀត ជាពិសេសប្រទេសដែលនៅជាប់ព្រំដែនអាល្លឺម៉ង់ ក៏កំពុងលង់លក់ដែរ ។ អង់គ្លេសនិងប្រទេសផ្សេងទៀតនៅក្នុងពិភពលោកដឹងថា ការធ្វើមិនដឹងមិនឮនោះមិនបានការអ្វីទេ ហើយឥឡូវនេះប្រទេសនីមួយៗ ពិសេសអង់គ្លេស បានកំពុងបង់ការចំណាយយ៉ាងខ្ពស់ចំពោះនយោបាយមិនប្រឈមមុខនឹងស្ថានការណ៍លំបាកធ្ងន់ធ្ងរ ។

គ្មានប្រទេសណាមួយត្រៀមលះបង់មនុស្សរបស់ខ្លួនទទេៗនោះទេ ហើយជាពិសេសលះបង់ដើម្បីផលប្រយោជន៍អ្នកដទៃ ។ ហើយប្រទេសអង់គ្លេសក៏មិនអាចគេចផុតពីករណីនេះដែរ ។ ការចូលឈ្លានពាន ការរំដោះ និងសេរីភាព នឹងកើតមាននៅថ្ងៃណាមួយ ប៉ុន្តែប្រទេសអង់គ្លេសដែលមិនមែនជាទឹកដីត្រូវកាន់កាប់នឹងឆក់ឱកាសនេះ ។

យើងមានការសោកស្តាយនិងស្រងាកចិត្តខ្លាំងណាស់ នៅពេលដឹងថា មនុស្សជាច្រើនបានផ្លាស់ប្តូរឥរិយាបថរបស់ពួកគេចំពោះយើងដែលជាជនជាតិជ្វីហ្វ ។ យើងទទួលដំណឹងថា លទ្ធិប្រឆាំងប្រជាជាតិជ្វីហ្វ បានកើតមាននៅក្នុងមជ្ឈដ្ឋានផ្សេងៗដែលកាលពីមុនមិនធ្លាប់ត្រូវបានគេគិតគូរដល់ ។ ការពិតបែបនេះ មានឥទ្ធិពលមកលើពួកយើងខ្លាំងសែនខ្លាំង ។ ហេតុផលនៃការស្អប់ខ្ពើមនេះគឺអាចយល់បាន សូម្បីតែក្នុងចំណោមមនុស្សទូទៅក៏ដោយ ប៉ុន្តែរឿងនោះមិនត្រឹមត្រូវទេ ។ ពួកគ្រិស្តសាសនិកបានបន្ទោសពួកជ្វីហ្វថា បានរាយការណ៍ការសម្ងាត់របស់ពួកគេប្រាប់ពួកអាល្លឺម៉ង់ បកអាក្រាតអ្នកជួយជនខ្លួន ហើយបណ្តាលឲ្យគេឯងជួបប្រទះជោគវាសនានិងការសេងសឹកដ៏គួរឲ្យរន្ធត់ ដែលមនុស្សជាច្រើនបានទទួលរងរួចហើយ ។ រឿងទាំងអស់នេះគឺជារឿងពិត ។ ប៉ុន្តែទាក់ទងនឹងអ្វីៗទាំងអស់ ពួកគ្រិស្តសាសនិកគួរតែសម្លឹងមើលបញ្ហាមួយទាំងសងខាង ។ តើពួកគ្រិស្តសាសនិកនឹងធ្វើខុសពីនេះទេ ប្រសិនបើពួកគេស្ថិតនៅក្នុងស្ថានភាពដូចជាពួកយើង? មិនថាជាជ្វីហ្វឬគ្រិស្តសាសនិកទេ តើមាននរណាអាចនៅស្ងាត់ស្ងៀមបានចំពោះមុខការគាបសង្កត់របស់អាល្លឺម៉ង់នោះ? មនុស្សគ្រប់គ្នាដឹងថាវាពិតជាមិនអាចទៅរួចទេ ដូច្នេះចុះហេតុអ្វីបានជាពួកគេស្នើឲ្យជនជាតិជ្វីហ្វធ្វើអ្វីដែលពួកគេមិនអាចធ្វើទៅរួចអីចឹង?

នៅក្នុងមជ្ឈដ្ឋានសម្ងាត់ គេខ្សឹបខ្សៀវក្នុងចំណោមពួកអ្នកតស៊ូថា ពួកជ្វីហ្វអាល្លឺម៉ង់ដែលធ្វើអន្តោប្រវេសន៍មកនៅហូឡង់មុនពេលសង្គ្រាម ហើយឥឡូវត្រូវបានគេបញ្ជូនទៅប្រទេសប៉ូឡូញនោះ នឹងពុំត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់មកទីនេះទេ ។ ពួកគេត្រូវបានផ្តល់សិទ្ធិឲ្យជ្រកកោននៅប្រទេសហូឡង់ ប៉ុន្តែ នៅពេលដែល អ៊ីត្លែរ ស្លាប់ទៅ ពួកគេគួរតែវិលត្រឡប់ទៅនៅអាល្លឺម៉ង់វិញ ។

នៅពេលឯងឮដូច្នេះ ឯងមុខជាចាប់ផ្តើមមានចម្ងល់ថាហេតុអ្វីយើងធ្វើសង្គ្រាមដ៏លំបាកនិងយូរអង្វែងបែបនេះ ។ គេតែងប្រាប់យើងថា យើងកំពុងតែប្រយុទ្ធដើម្បីសេរីភាព ការពិតនិងយុត្តិធម៌! សង្គ្រាមនៅមិនទាន់ចប់ទេ ហើយគេឃើញមានជាស្រេចនូវការប្រឆាំងគ្នាយ៉ាងខ្លាំង ពួកជ្វីហ្វត្រូវបានគេចាត់ទុកជាមនុស្សមិនសំខាន់ ។ អូ! វាក្រៀមក្រំនោះ ក្រៀមក្រំណាស់ទៅហើយ ។ “អ្វីដែលគ្រិស្តសាសនិកម្នាក់ធ្វើ គឺការទទួលខុសត្រូវផ្ទាល់របស់គេ អ្វីដែលជនជាតិជ្វីហ្វម្នាក់ធ្វើវាឆ្លុះបញ្ចាំងពីជនជាតិជ្វីហ្វទាំងអស់” ។

និយាយតាមត្រង់ ខ្ញុំអត់យល់ទេថាតើពួកហូឡង់ដែលជាប្រជាជាតិមួយស្មោះត្រង់និងល្អ ទៅជាមានគំនិតមួយបែបនេះមកលើយើង ។ ពួកគេធ្វើដូច្នេះមកលើពួកយើងដែលជាមនុស្សត្រូវគេគាបសង្កត់ សំណាងអាក្រក់ និងគួរឲ្យអាណិតបំផុតក្នុងលោកយើងនេះ ។

ខ្ញុំមានក្តីសង្ឃឹមតែរឿងមួយគត់គឺថា និន្នាការប្រឆាំងជ្វីហ្វនឹងអាចកន្លងផុតទៅ ទីបំផុតប្រជាជនហូឡង់នឹងបង្ហាញពណ៌សម្បុរពិតរបស់ពួកគេ មនោសញ្ចេតនារបស់គេនឹងមិនថមថយឡើយនៅថ្ងៃនេះ ឬថ្ងៃអនាគត ព្រោះអ្វីដែលកើតមាននេះគឺវាមិនយុត្តិធម៌! ។

ប្រសិនបើភាពស្អប់ខ្ពើមនេះលេចឡើងឲ្យឃើញពិតប្រាកដ ជនជាតិជ្វីហ្វមួយចំនួនតូចដែលនៅសេសសល់ក្នុងទឹកដីហូឡង់នឹងត្រូវចាកចេញទៅ! ពួកយើងនឹងត្រូវខ្ចប់បង្វេច ហើយបន្តធ្វើដំណើរចេញពីប្រទេសដ៏ស្រស់ស្អាតនេះ ដែលធ្លាប់បានទទួលយើងឲ្យរស់នៅ ហើយឥឡូវត្រឡប់ជាបែរខ្នងមិនរវល់នឹងយើង

ទៅវិញ ។

ខ្ញុំស្រលាញ់ប្រទេសហូល្លង់ ។ មានម្តងនោះ ខ្ញុំសង្ឃឹមថា វានឹងក្លាយជាទឹកដីកំណើតរបស់ខ្ញុំ ព្រោះខ្ញុំបានបាត់បង់សញ្ជាតិដើមរបស់ខ្ញុំទៅហើយ ។ ហើយខ្ញុំនៅតែសង្ឃឹមបែបនោះទៀត!

**ថ្ងៃអង្គារ ទី៦ ខែមិថុនា ឆ្នាំ១៩៤៤**

*ឃីធី សម្លាញ់,*

វិទ្យុ ប៊ីប៊ីស៊ី បានប្រកាសនៅវេលាម៉ោងដប់ពីរថា "នេះជា ឌី ដេយ គឺជាថ្ងៃបើកប្រតិបត្តិការសឹក" ។ ការចូលឈ្លានពានបានចាប់ផ្តើម!

ព្រឹកនេះ នៅវេលាម៉ោងប្រាំបី ពួកអង់គ្លេសបានរាយការណ៍អំពីការទម្លាក់គ្រាប់យ៉ាងខ្លាំងក្លាទៅលើ កាឡេ, ប៊ូឡូញ, ឡឺ ហាវ និង ឈែរប៊ឺហ្គ ព្រមទាំង ប៉ា ដឺ កាឡេ (ដូចសព្វដង) ។ ជាងនេះទៅទៀត ដើម្បីជាវិធានការបង្ការសម្រាប់អ្នកទាំងឡាយនៅក្នុងទឹកដីដែលត្រូវកាន់កាប់ មនុស្សគ្រប់គ្នាដែលរស់នៅក្នុងតំបន់មួយចម្ងាយជាងសាមសិបពីរគីឡូម៉ែត្រពីឆ្នេរសមុទ្រនោះត្រូវបានព្រមានឲ្យត្រៀមខ្លួនសម្រាប់ការទម្លាក់គ្រាប់បែក ។ ពួកអង់គ្លេសនឹងទម្លាក់ខិត្តប័ណ្ណនៅកន្លែងដែលអាចធ្វើបាន មួយម៉ោងមុនពេលទម្លាក់គ្រាប់បែក ។

បើយោងទៅតាមដំណឹងដែលអាល្លឺម៉ង់ផ្សាយ ពួកកងទ័ពឆ័ត្រយោងអង់គ្លេសបានលោតចុះមកដីនៅតំបន់សមុទ្របារាំង ។ បើយោងទៅតាមវិទ្យុប៊ីប៊ីស៊ីថា "នាវាដឹកទាហានឡើងគោករបស់អង់គ្លេសបានប្រយុទ្ធទល់នឹងអង្គភាពទាហានជើងទឹកអាល្លឺម៉ង់" ។

ការសន្និដ្ឋានរបស់ពួកអ្នករស់នៅអគារបន្ថែម ក្នុងពេលបរិភោគអាហារពេលព្រឹកវេលាម៉ោងប្រាំបួន គឺថានេះជាការសាកល្បងឡើងគោកមួយ ដូចការឡើងគោកមួយកាលពីពីរឆ្នាំកន្លងទៅនៅ ឌីយេប ដែរ ។

វិទ្យុផ្សាយសំឡេង ប៊ីប៊ីស៊ី ជាភាសាអាល្លឺម៉ង់ ហូល្លង់ បារាំង និងភាសាផ្សេងទៀត ដែលផ្សាយនៅវេលាម៉ោងដប់ បាននិយាយថា ការឡើងគោកបានចាប់ផ្តើម! ដូច្នេះ នេះគឺជាការឡើងគោកប្រាកដមែន ។ វិទ្យុផ្សាយសំឡេងប៊ីប៊ីស៊ី នៅវេលាម៉ោងដប់មួយ បានជូនដំណឹងអំពីសុន្ទរកថារបស់អគ្គបញ្ជាការកងទ័ពអាមេរិក គឺឧត្តមសេនីយ៍ ដ្វៃ អាយស៊ិន ហូវ៉ែរ ។

នេះជាសេចក្តីជូនដំណឹងជាភាសាអង់គ្លេស ចាក់ផ្សាយតាមវិទ្យុផ្សាយសំឡេង ប៊ីប៊ីស៊ី របស់អង់គ្លេស ឧត្តមសេនីយ៍ អាយស៊ិន ហូវ៉ែរ បានថ្លែងទៅកាន់ប្រជាជនបារាំងថា "នេះគឺជាថ្ងៃបើកប្រតិបត្តិការសឹក ។ ការប្រយុទ្ធដ៏តឹងតែងកំពុងកើតមាននៅពេលនេះ ប៉ុន្តែ បន្ទាប់ពីនេះ គឺជ័យជម្នះ ។ ឆ្នាំ១៩៤៤ គឺជាឆ្នាំជោគជ័យទាំងស្រុង ។ សូមឲ្យអ្នកទាំងអស់គ្នាជួបសំណាងល្អ" ។

វិទ្យុផ្សាយសំឡេង ប៊ីប៊ីស៊ី វេលាម៉ោងមួយៈ យន្តហោះ ១១០០០គ្រឿងបានរៀបចំចេញដំណើរ និងកំពុងហោះទៅមកមិនឈប់ ដើម្បីទម្លាក់កងទ័ពនិងគ្រាប់បែកនៅពីក្រោយជួរទ័ពខ្មាំង ។ នាវា៤០០០គ្រឿង បូកនឹងនាវាតូចៗជាច្រើនគ្រឿងកំពុងតែបុកប្រាំងដាក់ទាហានឡើងគោកជាបន្តបន្ទាប់ នៅតំបន់ចន្លោះ ឈែរប៊ឺហ្គ និង ឡឺ ហាវ ។ កងទ័ពអង់គ្លេសនិងអាមេរិកបានចូលរួមជាស្រេចនៅក្នុងការប្រយុទ្ធដ៏ខ្លាំងក្លានេះ ។ មានសុន្ទរកថារបស់ ហ្គឺប្រេនឌី នាយករដ្ឋមន្ត្រីបែលហ្ស៊ិក ស្តេចហាអាកុន នៃប្រទេសន័រវែស លោក ដឺ ហ្គោល នៃប្រទេសបារាំង ស្តេចអង់គ្លេស និងចុងក្រោយគឺនាយករដ្ឋមន្ត្រី ឆឺចឈីល ។

អ្នកនៅក្នុងអគារបន្ថែមទាំងអស់មានសេចក្តីរំភើបយ៉ាងខ្លាំង! ទីបំផុត ការរំដោះដែលយើងរង់ចាំជាយូរមកហើយបានមកដល់ហើយមែនឬ? ការរំដោះមួយដែលយើងធ្លាប់និយាយច្រើនណាស់អំពីវា ។ វានៅតែជារឿងដ៏ល្អបំផុត និងសែនដូចរឿងព្រេងបំផុត បានក្លាយជាការពិតមែនឬ? តើឆ្នាំនេះ (ឆ្នាំ ១៩៤៤) នឹងនាំជោគជ័យមកឲ្យយើងគ្រប់គ្នាឬ? យើងមិនទាន់ដឹងនៅឡើយទេ ។ ប៉ុន្តែទីណាមានក្តីសង្ឃឹម ទីនោះនឹងមានជីវិត ។ វាបានធ្វើឲ្យយើងពោរពេញទៅដោយសេចក្តីក្លាហាន ហើយរឹងប៉ឹងជាថ្មីឡើងវិញ ។ យើងត្រូវតែក្លាហានដើម្បីស៊ូទ្រាំនឹងការភ័យខ្លាច ការលំបាក និងក្តីឈឺចាប់រាប់មិនអស់ ដែលមិនទាន់លេចចេញនៅឡើយ ។ ឥឡូវនេះ សំខាន់គឺយើងត្រូវរក្សាការស្ងប់ស្ងៀមខាំមាត់សង្កត់ចិត្ត! ប្រទេសបារាំង រុស្ស៊ី អ៊ីតាលី និងអាល្លឺម៉ង់ អាចស្រែកត្អូញត្អែរពីសេចក្តីគ្មានរំពឹង ប៉ុន្តែយើងមិនទាន់មានសិទ្ធិត្រូវធ្វើដូច្នោះទេ!

អ៊ូ ឃីធី! រឿងល្អបំផុតគឺការបុកប្រាំងឡើងគោក ដែលខ្ញុំមានអារម្មណ៍ថាមិត្តភក្តិកំពុងតែខិតមកជិតខ្ញុំហើយ ។ ពួកអាល្លឺម៉ង់

គួរឲ្យខ្លាចទាំងនោះ បានគាបសង្កត់និងគំរាមកំហែងយើងយូរណាស់មកហើយ ដែលធ្វើឲ្យការគិតដល់មិត្តភក្តិនានា និងការដោះលែងឲ្យផុតពីទុក្ខទោស មានន័យគ្រប់យ៉ាងចំពោះយើង! ឥឡូវនេះ មិនគ្រាន់តែជនជាតិជ្វីហ្វទេ សូម្បីតែហុល្លង់ និងតំបន់អឺរ៉ុបទាំងអស់សុទ្ធតែត្រូវកាន់កាប់ ។ ម៉ាហ្គុត និយាយថា ខ្ញុំប្រហែលជាអាចទៅរៀននៅឯសាលាបានក្នុងខែកញ្ញា ឬខែតុលា ។

**សេចក្តីបន្ថែមៈ** ខ្ញុំនឹងបន្តប្រាប់ឯងទៀត អំពីពត៌មានថ្មីៗបំផុត!

នៅព្រឹកនេះនិងនៅយប់មិញ រូបទីងមោងធ្វើពីចំបើងនិងកៅស៊ូ ត្រូវបានគេទម្លាក់ពីលើយន្តហោះ ពីក្រោយជួរទ័ពអាល្លឺម៉ង់ ហើយបានផ្ទុះឡើងនៅពេលវាធ្លាក់មកប៉ះនឹងដី ។ អ្នកលោតឆ័ត្រយោងភាគច្រើន បានលោតចុះពីយន្តហោះដោយមានលាបមុខខ្មៅអ៊ូញ ដូច្នេះនៅទីងងឹត គ្មាននរណាមើលឃើញពួកគេឡើយ ។ គ្រាប់បែកទម្ងន់៥៥០០តោន ត្រូវបានទម្លាក់ស្រោចពីលើតំបន់ឆ្នេរសមុទ្របារាំងនៅក្នុងពេលយប់ ។ ក្រោយមក នៅវេលាម៉ោងប្រាំមួយព្រឹក នាវាដឹកទ័ពបុកប្រាំងឡើងគោកដំបូងគេ បានមកចូលចត ។ នៅថ្ងៃនេះមានយន្តហោះ២០០០០គ្រឿង កំពុងតែប្រតិបត្តិការ ។ កងកាំភ្លើងធំអាល្លឺម៉ង់នៅឆ្នេរសមុទ្រត្រូវបានបំផ្លាញមុនពេលនាវាតូចៗចូលបុកប្រាំង ។ គេក៏បានបង្កើតទីតាំងឈរជើងដ៏រឹងមាំតូចមួយ ។ អ្វីៗដំណើរការទៅយ៉ាងល្អ ទោះបីជាអាកាសធាតុមិនអំណោយផលក៏ដោយ ។ កងទ័ព និងប្រជាជនគឺ «ឆន្ទៈតែមួយនិងក្តីសង្ឃឹមតែមួយ» ។

## ថ្ងៃអង្គារ ទី២៧ ខែមិថុនា ឆ្នាំ១៩៤៤

*ឃីធី សម្លាញ់,*

អារម្មណ៍បានផ្លាស់ប្តូរយ៉ាងគំហុក អ្វីៗដំណើរការទៅយ៉ាងសែនល្អ ។ ឈែរប៊ឺហ្គ, វីថេបស្គ៍ និង ស្លូប៊ីន បានត្រូវដណ្តើមកាន់កាប់នៅថ្ងៃនេះ ។ គេប្រាកដជាបានចាប់មនុស្សនិងដណ្តើមបានសម្ភារយ៉ាងច្រើន ។ ឧត្តមសេនីយ៍អាល្លឺម៉ង់ប្រាំនាក់ត្រូវបានសម្លាប់នៅជិត ឈែរប៊ឺហ្គ ហើយពីរនាក់ទៀតត្រូវបានចាប់ជាឈ្លើយសឹក ។ ឥឡូវនេះពួកគេមានកំពង់ផែមួយ ពួកអង់គ្លេសអាចដឹកជញ្ជូនអ្វីៗទាំងអស់ដែលពួកគេត្រូវការ ទៅដាក់លើដីគោក ។ ឧបទ្វីប កូតង់ទីន ទាំងមូលត្រូវបានដណ្តើមកាន់កាប់តែបីសប្តាហ៍ប៉ុណ្ណោះបន្ទាប់ពីការឈ្លានពាន! ជោគជ័យអ្វីម្ល៉េះទេ!

នៅក្នុងរយៈពេលបីសប្តាហ៍ ចាប់តាំងពីថ្ងៃបើកប្រតិបត្តិការសឹក មិនមានថ្ងៃណាអត់មានព្យុះភ្លៀងទេ មិនថានៅទីនេះឬនៅបារាំងឡើយ ។ ប៉ុន្តែសំណាងអាក្រក់បែបនេះមិនបានរារាំងអង់គ្លេសនិងអាមេរិកមិនឲ្យបង្ហាញអានុភាពរបស់ពួកគេទេ ។ ធ្វើដូចម្តេចទៅ? ពិតហើយ ពួកអាល្លឺម៉ង់បានប្រើប្រាស់អាវុធចម្លែករបស់ពួកគេ ប៉ុន្តែគ្រឿងផ្ទុះតូចតាចបែបនេះស្ទើរតែគ្មានឥទ្ធិពលអ្វីទាំងអស់ ក្រៅតែពីការខូចខាតតិចតួចនៅអង់គ្លេស ហើយស្រែកប្រកូកប្រកាសតាមចំណងជើងកាសែត ក្រូត ប៉ុណ្ណោះ ។ ទោះយ៉ាងណាក៏ដោយ នៅពេលពួកគេដឹងនៅ «ក្រូតឡែន» ថា ពួកបុលសេវិកពិតជាកំពុងតែចូលកាន់តែជិត ពួកគេនឹងភ័យញ័រជើង ។

ស្ត្រីអាល្លឺម៉ង់ទាំងអស់ដែលមិនធ្វើការនៅក្នុងកងទ័ព ត្រូវបានគេជម្លៀសទៅជាមួយកូនៗរបស់ពួកគេ ពីតំបន់ឆ្នេរសមុទ្រទៅខេត្ត ហ្គ្រូនីងហ្គេន, ហ្វ្រីសឡែន និងហ្គែលឌ័រឡែន ។ មូស្សឺត បានប្រកាសថា ប្រសិនបើការឈ្លានពានមកដល់ទឹកដីហុល្លង់ គាត់នឹងចុះឈ្មោះចូលកងទ័ព ។ តើមនុស្សអាក្រក់កន្ទាត់នោះមានផែនការប្រយុទ្ធឬ? គាត់គួរតែធ្វើយ៉ាងនោះនៅប្រទេសរុស្ស៊ីមុននេះយូរមកហើយ ។ ប្រទេសហ្វាំងឡង់បានបដិសេធសំណើសន្តិភាពមួយគ្រាមកហើយ ហើយឥឡូវនេះ ការចរចាបានបរាជ័យម្តងទៀត ។ មនុស្សខូរបង្កង!ពួកគេនឹងស្តាយក្រោយ!

តាមយោបល់ឯង តើយើងនឹងទៅជាយ៉ាងណានៅថ្ងៃ២៧ ខែកក្កដា?

## ថ្ងៃសុក្រ ទី២១ ខែកក្កដា ឆ្នាំ១៩៤៤

*ឃីធី សម្លាញ់,*

ទីបំផុត ខ្ញុំបានចាប់ផ្តើមមានសុទិដ្ឋិនិយម ។ ទីបញ្ចប់ នៅពេលនេះអ្វីៗប្រែជាល្អ ។ វាពិតជាល្អមែន! ដំណឹងដ៏អស្ចារ្យ! មានការប៉ុនប៉ងធ្វើឃាតមួយទៅលើជីវិតរបស់ អ៊ីត្លែរ ហើយម្តងនេះមិនមែនជាស្នាដៃរបស់ពួកកុម្មុយនិស្តជ្វីហ្វ ឬពួកមូលធនអង់គ្លេសទេ ប៉ុន្តែជាស្នាដៃរបស់ឧត្តមសេនីយ៍អាល្លឺម៉ង់ម្នាក់ដែលជាមនុស្សមានឋានៈជាកុងត៍វ័យក្មេង ស្ថិតនៅក្នុងត្រកូលអភិជន ។ អ៊ីត្លែរ អាចនៅរស់រានមានជីវិតដោយសារតែព្រះជាម្ចាស់មិនទាន់ដាច់ព្រះទ័យយកជីវិតគាត់ ។ ជាអកុសល គាត់បានគេចខ្លួនរួចដោយមានស្នាមរបួសដាច់រលាត់និងរលាកបន្តិចបន្តួច ។ មន្ត្រី

និងឧត្តមសេនីយ៍មួយចំនួននៅជុំវិញគាត់ ត្រូវបានសម្លាប់និងធ្វើឲ្យរបួស ។ មេគំនិតនៃការប៉ុនប៉ងធ្វើឃាតនេះ ត្រូវបានបាញ់សម្លាប់ ។

នេះគឺជាភ័ស្តុតាងអស្ចារ្យបំផុតដែលយើងមានរហូតមកទល់ពេលនេះ ដើម្បីបញ្ជាក់ថាឧត្តមសេនីយ៍និងមន្ត្រីជាច្រើនបានធុញទ្រាន់នឹងសង្គ្រាមហើយ ហើយចង់ឃើញ អ៊ីខ្មែរ ធ្លាក់ចូលរណ្តៅដីសែនជ្រៅឥតព្រំដែន ។ ដូច្នេះ ពួកគេអាចបង្កើតរបបផ្តាច់ការយោធាមួយ កសាងសន្តិភាពជាមួយសម្ព័ន្ធមិត្ត បំពាក់អាវុធល្អៗសម្រាប់ខ្លួនឯង ហើយពីរបីទសវត្សរ៍ក្រោយមក បំពាក់ភ្លុកភ្លើងសង្គ្រាមថ្មីមួយទៀត ។ ការសន្តោសប្រណីរបស់ព្រះជាម្ចាស់ប្រហែលជាមានបំណងរង់ចាំឲ្យដល់ពេលត្រូវកម្ចាត់ អ៊ីខ្មែរ ព្រោះវាងាយស្រួលជាង និងបង់ថ្លៃតិចជាង សម្រាប់សម្ព័ន្ធមិត្តទុកឲ្យពួកអាល្លឺម៉ង់ដ៏គួរឲ្យស្អប់ខ្ពើមសម្លាប់គ្នាឯង ។ វាជាការងាររកាន់តែតិចតួចសម្រាប់ពួករុស្ស៊ីនិងអង់គ្លេស ហើយវាអនុញ្ញាតឲ្យពួកគេចាប់ផ្តើមស្ថាបនាទីក្រុងនានារបស់ពួកគេឡើងវិញកាន់តែឆាប់រហ័សបំផុត ។ ប៉ុន្តែយើងមិនទាន់ដល់ដំណាក់កាលនោះនៅឡើយទេ ហើយខ្ញុំមិនចូលចិត្តរង់ចាំព្រឹត្តិការណ៍ប្រកបដោយកិត្តិគុណនេះដែរ ។ ជាងនេះទៅទៀត ឯងប្រហែលជាកត់សម្គាល់ឃើញហើយថា ខ្ញុំកំពុងតែនិយាយការពិតទាំងស្រុងដោយគ្មានអ្វីផ្សេងទេ ។ សម្រាប់ម្តងនេះ ខ្ញុំមិនមែននិយាយពីរឿងឧត្តមគតិខ្ពង់ខ្ពស់ឡើយ ។

ជាងនេះទៅទៀត អ៊ីខ្មែរ ចិត្តល្អរហូតដល់ប្រកាសប្រាប់មនុស្សស្មោះត្រង់និងលះបង់ចំពោះគាត់ថា មកត្រឹមពេលនេះបុគ្គលិកយោធាទាំងអស់គឺស្ថិតក្រោមបញ្ជារបស់ប៉ូលិសសម្ងាត់នៃរបបណាហ្ស៊ីរបស់គណបក្សណាហ្ស៊ីអាល្លឺម៉ង់ ដូច្នេះ ទាហានណាដែលដឹងថាថ្នាក់លើម្នាក់របស់គេបានទាក់ទងនៅក្នុងការប៉ុនប៉ងធ្វើឃាតដ៏កំសាកមកលើជីវិតរបស់អ្នកដឹកនាំ អ៊ីខ្មែរ ទាហាននោះមានសិទ្ធិអាចនឹងបាញ់សម្លាប់ជននោះនៅនឹងកន្លែង! ។

ផ្តល់សិទ្ធិសម្បើមម៉្លេះ! ។ ចន្ទី ដ៏តូចល្អិត បានឈឺជើងបន្ទាប់ពីដើរក្នុងចម្ងាយផ្លូវយ៉ាងវែងឆ្ងាយ ហើយមេបញ្ជាការរបស់គាត់បានជេរប្រទេចគាត់ ។ ចន្ទី ទាញកាំភ្លើងវែងរបស់គាត់ ហើយស្រែកថា «លោកមេបញ្ជាការលួចធ្វើឃាត អ៊ីខ្មែរ! យកអានេះទៅ!» ស្នូរកាំភ្លើងមួយគ្រាប់បានផ្ទុះឡើង ហើយមេបញ្ជាការដែលមើលងាយមនុស្ស ដែលហ៊ានស្តីបន្ទោសកូនទាហាននោះបានក្លាយជាមនុស្សមានជីវិតអមតៈ (ឬក៏ខ្មោចអតមៈទើបត្រូវ?) ។ ទីបំផុត គ្រប់ពេលដែលមន្ត្រីយោធាមួយរូបចេញបញ្ជាទៅកូនទាហាន ឬក៏ជួបកូនទាហាន មន្ត្រីនោះនឹងលេចនោមដាក់ខោ ព្រោះកូនទាហានមានអំណាចជាងមេ ។

តើឯងអាចធ្វើតាមនោះ ឬក៏ខ្ញុំត្រូវរំលងពីប្រធានបទមួយទៅប្រធានបទមួយជាថ្មីទៀត? ខ្ញុំមិនអាចចៀសវាងវាបានទេ ។ ទស្សនវិស័យនៃការវិលត្រឡប់ទៅសាលារៀនវិញ នៅខែតុលាកំពុងតែធ្វើឲ្យខ្ញុំសប្បាយចិត្តខ្លាំងរហូតដល់មិនអាចជាមនុស្សសមហេតុផលបានឡើយ ។ អូ! សម្លាញ់ ខ្ញុំមានធ្លាប់ប្រាប់ឯងហើយឬនៅថាខ្ញុំមិនចង់រង់ចាំព្រឹត្តិការណ៍? សូមអភ័យទោសឲ្យខ្ញុំផងឃីធី ពួកគេមិនហៅខ្ញុំថាជាមនុស្សប្រមូលផ្តុំដោយសកម្មភាពផ្ទុយយ៉ាងគ្មានហេតុផលនោះទេ! ។

អាន់ ម. ហ្វ្រែង របស់ ឃីធី

**(ចប់ដោយសង្ខេប)**

**ស៊ើ សាយ្យាណា**

# សេចក្តីជូនដំណឹង

ប្រសិនបើមិត្តអ្នកអានចាប់អារម្មណ៍ក្នុងការអានសៀវភៅនេះទាំងស្រុង សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានដូចខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

**Email: dccam@bigpond.com.kh**

**Home page: www.dccam.org**

ឬអាចរកបាននៅតាមបណ្តាតូបលក់សៀវភៅ និងហាងលក់សៀវភៅ *Monument Book Store* ។

សូមអរគុណ ។

# ជនជាតិចិននៅកម្ពុជា

## សេចក្តីផ្តើម

ដោយផ្អែកតាមប្រវត្តិសាស្ត្រ អ្នកដឹកនាំប្រទេសកម្ពុជា និងប្រជាជនខ្មែរ ពិតជាបានទទួលស្គាល់សហគមន៍ជនជាតិភាគតិចចិននៅក្នុងប្រទេសកម្ពុជា ។ មានជម្លោះតិចតួចប៉ុណ្ណោះកើតមានឡើង ប៉ុន្តែនៅក្រោមការគ្រប់គ្រងរបស់អាណានិគមបារាំង និងចាប់តាំងពីទទួលបានឯករាជ្យ ជនជាតិចិនបានពើបប្រទះនូវការរើសអើងគួរឲ្យកត់សម្គាល់ ។ សិទ្ធិរបស់ជនជាតិចិនមិនត្រូវបានទទួលស្គាល់ ហើយមានការហាមប្រាមមិនឲ្យប្រើភាសានិងវប្បធម៌របស់ខ្លួនទៀតផង ។ របាយការណ៍នេះពិនិត្យមើលយ៉ាងពិសេសទៅលើភ័ស្តុតាងនៃការរំលោភសិទ្ធិមនុស្សប្រឆាំងនឹងជនជាតិភាគតិចចិននៅកម្ពុជា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់ពីបានផ្តួលរំលំរបបសាធារណរដ្ឋខ្មែរនាឆ្នាំ១៩៧៥ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ (អង្គការ) បានអនុវត្តផែនការដែលមានលក្ខណៈប្រហាក់ប្រហែលនឹងផែនការរបស់ប្រទេសចិនកាន់លិទ្ធិម៉ៅនិយមក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ផែនការទាំងនោះធ្វើឡើងក្នុងគោលបំណងរៀបចំរចនាសម្ព័ន្ធសង្គមកម្ពុជាឡើងវិញ ។ ទោះបីជាកម្ពុជាប្រជាធិបតេយ្យងាកទៅរកប្រទេសចិនដើម្បីសុំការឧបត្ថម្ភគាំទ្រខាងហិរញ្ញវត្ថុនិងនយោបាយដល់គំនិតទាំងនេះយ៉ាងណាក៏ដោយ ក៏កម្ពុជាប្រជាធិបតេយ្យមិនញញើតនឹងចាត់ទុកជនជាតិចិនជាមុខសញ្ញាសត្រូវរបស់ខ្លួននោះឡើយ ។ ជនជាតិចិនដែលភាគច្រើនរស់នៅតាមទីក្រុង ត្រូវបានជម្លៀសទាំងបង្ខំឲ្យទៅរស់នៅតាមតំបន់ជនបទដាច់ស្រយាល ។ កម្ពុជាប្រជាធិបតេយ្យយល់ថា ទីក្រុងនានា ការប្រកបរបរជួញដូរ របៀបរបបរស់នៅជាលក្ខណៈទីក្រុង និងអ្នករស់នៅទីក្រុងតែម្តង គឺជាសញ្ញាបង្ហាញពីគំនាបសង្កត់បែបលោកខាងលិច ។ ជនជាតិចិននៅកម្ពុជាត្រូវបានកត់ចូលបញ្ជីស្បែកខ្មៅថាជាសត្រូវផ្ទៃក្នុងជាមួយនឹងអ្នកចេះដឹង ជាជនពុករលួយ មូលធន អតីតទាហាន និងជាជនក្បត់ជាតិ ។ ការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការតស៊ូវណ្ណៈបដិវត្តន៍ ។ ក្នុងចំណោមជនជាតិចិន៤សែននាក់រស់ដែលនៅលើទឹកដីកម្ពុជានៅក្នុងឆ្នាំ១៩៧៥ មានចំនួនប្រមាណពីរសែនពីរម៉ឺនប្រាំពាន់នាក់បានស្លាប់បាត់បង់ជីវិតក្រោមការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ។

ក៏ប៉ុន្តែគ្មានហេតុផលណាមួយដែលពន្យល់យ៉ាងពេញលេញអំពីការធ្វើទុក្ខបុកម្នេញនិងការសម្លាប់ជនជាតិចិនទេ ។ ជនជាតិចិនជាច្រើនមិនខុសអំពីរដ្ឋាភិបាលជាតិខ្លួនទេ គឺគាំទ្រដល់ជនកុម្មុយនិស្តកម្ពុជា ។ សញ្ញាណដែលបញ្ជាក់ថាពូជសាសន៍ឬជាតិពន្ធុមានបញ្ហា គឺចាប់ផ្តើមលេចជារូបរាងឡើងនៅក្នុងឆ្នាំ១៩៧៣ ។ នៅពេលនោះ ពួកខុទ្ទាមខ្មែរក្រហមបានផ្សព្វផ្សាយក្រឹត្យមួយដែលចែងថា ប្រទេសកម្ពុជាមានសញ្ជាតិនិងភាសាតែមួយប៉ុណ្ណោះ ពោលគឺជនជាតិខ្មែរនិងភាសាខ្មែរ ហើយចាប់ពីពេលនោះមកក៏លែងមានជាតិសាសន៍ដទៃទៀត ។ ប្រសិនបើការធ្វើទុក្ខបុកម្នេញរបស់កម្ពុជាប្រជាប្រជាធិបតេយ្យទៅលើក្រុមជនជាតិភាគតិចវៀតណាម ចាម ចិន និងខ្មែរលើ មានលក្ខណៈដូចគ្នា និងកើតមាននៅទូទាំងប្រទេសព្រមគ្នានោះ ទង្វើនេះអាចនឹងត្រូវបកស្រាយថាជាផ្នែកមួយនៃដំណើរការដាច់ខាតនិងឃោរឃៅ នៅក្នុងការកំណត់អត្តសញ្ញាណជាតិដូចដែលកើតមានឡើងនៅក្នុងរបបណាហ្ស៊ីនៃប្រទេសអាល្លឺម៉ង់ដែរ ហើយថ្មីៗនេះកើតមាននៅប្រទេសរ៉ាន់ដានិងប៊ូស្នៀ ។ ពិតហើយថា របបកម្ពុជាប្រជា-ធិបតេយ្យលម្អៀងទៅរកជនជាតិខ្មែរ ប៉ុន្តែថាតើការធ្វើទុក្ខបុកម្នេញរបស់ខ្លួនទៅលើជនជាតិភាគតិចនានាមានលក្ខណៈជាប្រព័ន្ធ និងផ្អែកតែទៅលើជាតិពន្ធុ ឬដោយការបកស្រាយទៅតាមជាតិសាសន៍នោះ មិនអាចយល់បានដោយងាយឡើយ ។ បទពិសោធន៍របស់ជនជាតិចិននៅក្រោមរបបកម្ពុជាប្រជាធិប-តេយ្យមានលក្ខណៈខុសគ្នាច្រើន រហូតដល់ធ្វើឲ្យពិបាកក្នុងការកំណត់បទពិសោធន៍ជារួមមួយទៀតផង ។ ជាតិពន្ធុ ស្ថានភាព

សង្គម និងភូមិសាស្ត្រ ទាំងអស់នេះសុទ្ធតែជះឥទ្ធិពលទៅលើសភាពជាក់ស្តែងរបស់អ្នកទាំងនោះ ។ ភាពខុសប្លែកគ្នាទាំងនេះមាននៅក្នុងដំណើររឿងរបស់អ្នកផ្តល់បទសម្ភាសន៍ ដែលអ្នកខ្លះមានអារម្មណ៍ថាខ្លួនក្លាយជាមុខសញ្ញាធ្វើទុក្ខបុកម្នេញដោយសារតែខ្លួនជាជនជាតិចិន ហើយអ្នកខ្លះទៀតមិនមានអារម្មណ៍បែបនេះឡើយ ។ គួរកត់សម្គាល់ថាមតិភាគច្រើនជឿថា គ្មាននយោបាយមជ្ឈិមប្រឆាំងនឹងអ្នកទាំងនេះទេ ប៉ុន្តែជឿថាការប្រព្រឹត្តិបែបនេះគឺវាអាស្រ័យទៅលើកត្តាមួយចំនួនដូចជា ការស្អប់ខ្ពើមពូជសាសន៍ ដែលមានលក្ខណៈជាបុគ្គល និងការសងសឹកផ្ទាល់ខ្លួន ដែលមានលក្ខណៈខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀត និងទៅតាមសម័យកាល ។



កម្មាភិបាលខ្មែរក្រហមនិងកម្មាភិបាលចិន

ប៉ុន្តែអ្នកសិក្សាជាន់ខ្ពស់ទាំងនេះពន្យល់ថា ការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចិនពីសំណាក់កម្ពុជាប្រជាធិបតេយ្យ គឺជាបញ្ហានយោបាយទូទៅឬបញ្ហាវណ្ណៈ ។ ការពន្យល់ទាំងនេះមិនសូវមានលក្ខណៈស៊ីគ្នាប៉ុន្មានទេ ។ អ្នកសិក្សាស្រាវជ្រាវឈ្មោះ អេលីហ្សាប៊ែត ប៊ែកយ័រ (ឆ្នាំ១៩៨៦) ទាញហេតុផលថា នយោបាយរបបកម្ពុជាប្រជាធិបតេយ្យស្ទើរឲ្យបំផ្លិចបំផ្លាញសាសនានិងវប្បធម៌ទាំងឡាយ មិនថាជារបស់ខ្មែរឬរបស់ជនជាតិណាទេ ។ ហេតុដូចនេះ ជនជាតិចិនស្លាប់មិនមែនដោយសារអ្នកទាំងនោះជាជនជាតិចិនទេ ប៉ុន្តែដោយសារជនជាតិចិនទាំងនោះមានការពាក់ព័ន្ធនៅក្នុងការអនុវត្តន៍វប្បធម៌ដែលត្រូវរបបកម្ពុជាប្រជាធិបតេយ្យហាមឃាត់ ។ ស្រដៀងគ្នានេះដែរ វីលៀម វីលមុត ដែលពិនិត្យយ៉ាងស៊ីជម្រៅទៅលើជនជាតិចិននៅក្នុងសង្គមកម្ពុជា មានអំណះអំណាងថា ពូជសាសន៍មិនអាចយកមកពន្យល់អំពីការរើសអើងប្រឆាំងនឹងជនជាតិចិនបានឡើយ ។ ការរកឃើញដ៏សំខាន់របស់គាត់ដោយសារកត្តាវណ្ណៈ ពិសេសដោយសារវាស៊ីគ្នាទៅនឹងការពិតដែលថា ជនជាតិចិនភាគច្រើនរស់នៅទីក្រុងឬទីរួមខេត្ត ។ យោងតាមប្រវត្តិវិទូជនជាតិអាមេរិកាំង ម៉ៃឃើល វីកឃ័រី បានឲ្យដឹងថា ការស្អប់ខ្ពើមដែលបង្កើតឡើងដោយកម្ពុជា គឺជាផលវិបាកដែលកើតចេញពីទំនាស់ទាក់ទងនឹងការបែងចែករវាងជនបទនិងទីក្រុង ។ ប្រជាជនរស់នៅតាមជនបទបែរប្រឆាំងនឹងប្រជាជនរស់នៅទីក្រុង ។ ហេតុដូចនេះ ជនជាតិចិនត្រូវទទួលរងការធ្វើទុកបុកម្នេញ ព្រោះគេជាអ្នករស់នៅទីក្រុងនិងទីប្រជុំជន ហើយជនជាតិចិនភាគច្រើនស្លាប់ដោយសារខ្លួនមិនស៊ាំទៅនឹងជីវិតរស់និងការងារនៅតាមជនបទ ។ ប្រវត្តិវិទូជាតិអាមេរិកកាំង ដេវីដ ឆេនដល័រ ជឿថា ការរំលោភបំពានទៅលើជនជាតិចាមគឺអាស្រ័យទៅលើនយោបាយជាជាងជាតិពន្ធុឬហេតុផលសាសនា ។ របបកម្ពុជាប្រជាធិបតេយ្យស្អប់អ្នកណាដែលប្រឆាំងនឹងខ្លួន ជាជាងស្អប់ក្រុមជនជាតិឬក្រុមសាសនា ។ អ្នកសិក្សាស្រាវជ្រាវជនជាតិបារាំងដែលមានលក្ខណៈចម្រូងចម្រាស់ គឺលោក សែកត្សុង បានបដិសេធថា ជាតិពន្ធុវាមិនគ្រប់គ្រាន់សម្រាប់យកមកធ្វើជាអំណះអំណាងបញ្ជាក់ពីការសម្លាប់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យទេ ។ លោកទាញហេតុផលថា ការកាប់សម្លាប់ក្រោមស្នាដៃរបបកម្ពុជាប្រជាធិបតេយ្យគឺមិនមែនបណ្តាលមកពីហេតុផលជាតិសាសន៍ទេ ផ្ទុយទៅវិញគឺបណ្តាលមកពីនយោបាយនិងគោលនយោបាយសេដ្ឋកិច្ចដែលគ្មានលក្ខណៈប្រាកដប្រជា ។ យោងតាម សែកត្សុង ជនជាតិចិននិងជនរងគ្រោះផ្សេងៗទៀតស្លាប់ដោយសារខ្លួនមានលក្ខណៈគ្រោះថ្នាក់ចំពោះនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ដោយសារការបង្អត់អាហារ ជំងឺផ្សេងៗ ឬធ្វើការបាក់កម្លាំង ។ ប្រវត្តិវិទូ ប៊ែន ឃៀរនិន ក៏ជឿដែរថា ជនជាតិភាគតិចនៅលើទឹកដីកម្ពុជាត្រូវបានសម្លាប់ដោយលក្ខខណ្ឌសង្គម ជាជាងលក្ខខណ្ឌពូជសាសន៍ ។

## *សហគមន៍ចិននៅកម្ពុជា*

*១) និយមន័យ*

*ការពិពណ៌នាអំពីជនជាតិចិននៅកម្ពុជាគឺជាការងារស្មុគស្មាញមួយ ។ មិនថាលក្ខណៈសរីរាង្គឬក៏ការប្រតិបត្តិទំនៀមទម្លាប់ចិន គឺសុទ្ធតែមិនអាចពិពណ៌នាឲ្យបានប្រសើរឡើយ ។ ការកំណត់ថាអ្នកណាជាជនជាតិចិននៅប្រទេសកម្ពុជា គឺរឹតតែពិបាកជាងនេះទៅទៀត ដោយសារទាំងខ្មែរនិងចិនសុទ្ធតែមានការប្រតិបត្តិលាយឡំគ្នាជាមួយសហគមន៍ដទៃៗទៀត ។ ជនជាតិចិនជាច្រើនបានថែរក្សាទំនាក់ទំនងប្រវត្តិសាស្ត្ររបស់ខ្លួនជាមួយប្រទេសចិនតាមរយៈការគោរពប្រតិបត្តិដល់ជីដូនជីតាដែលបានចែកឋានទៅ ប៉ុន្តែជនជាតិចិនក៏បានគោរពប្រតិបត្តិទៅតាមវប្បធម៌ខ្មែរ ដូចជា ការទៅវត្តធ្វើបុណ្យទាន និងប្រារព្ធពិធីបុណ្យទានផ្សេងៗទៅតាមប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ ។ ដូចគ្នានេះដែរ ជនជាតិខ្មែរក៏ប្រារព្ធពិធីបុណ្យចូលឆ្នាំចិន ពិធីសង្កត់ផ្នូរ និងពិធីសែនក្បាលទឹក ។ ដូច្នេះការបកស្រាយទៅលើការគោរពប្រតិបត្តិជាក់ស្តែងមួយចំនួនថាជាទម្លាប់ចិន (ឬខ្មែរ) គឺមិនត្រឹមត្រូវតាមបរិបទប្រទេសកម្ពុជាទេ ។ ប៉ុន្តែសំខាន់ត្រូវកត់សម្គាល់ថា ទោះជាមានការរួមចូលគ្នាខាងវប្បធម៌ដល់កម្រិតនេះក្តី ក៏ការបកស្រាយរបស់ចិននិងខ្មែរ ចំពោះអត្តសញ្ញាណជនជាតិចិន មានលក្ខណៈច្បាស់លាស់ គឺមានសហគមន៍តូចៗនិយាយភាសាដោយឡែកពីគ្នាមានចំនួន៥គឺ ចិនប៉ែកាំង ចិនហៃណាំ ចិនខិ ចិនហុកគៀន និង ចិនទៀជីវ ។ ទោះជាជនជាតិខ្មែរទទួលស្គាល់ភាពខុសគ្នាខាងភាសាក្តី ក៏ខ្លួននៅតែប្រើពាក្យ "ចិនឆៅ" សំដៅទៅលើជនអន្តោប្រវេសន៍ចិនទាំងអស់ដែលមករស់នៅលើទឹកដីកម្ពុជាដោយមិនគិតថាជនជាតិចិនទាំងនោះបានទទួលយកវប្បធម៌ខ្មែរឬក៏មិនទទួលនោះឡើយ ។ ដូច្នេះនៅក្រោមក្រសែភ្នែកជនជាតិខ្មែរ ជនជាតិចិនគឺនៅតែចិនជានិច្ច ។*

*ដោយពិចារណាទៅលើភាពស្មុគស្មាញទាំងនេះ និយមន័យរបស់ វីលៀម វីលមុត ចំពោះជនជាតិចិននៅកម្ពុជា ហាក់ដូចជាទាក់ទងច្រើនបំផុតទៅនឹងការសិក្សានេះ ។ នៅក្នុងរចនាសម្ព័ន្ធនយោបាយនៃសហគមន៍ចិននៅកម្ពុជា វីលមុត បានឲ្យនិយមន័យជនជាតិចិនថា ជាបុគ្គលទាំងឡាយណាដែលគាំទ្រឬចូលរួមនៅក្នុងសហគមន៍ចិន ។ មិនដូចជានិយមន័យដែលមានលក្ខណៈចង្អៀតនៅក្នុងជំរឿនឆ្នាំ១៩៦២ នៅប្រទេសកម្ពុជាដែលកំណត់ថាជនជាតិចិនជាបុគ្គលទាំងឡាយណាដែលនិយាយភាសាចិននិងមានសញ្ជាតិជាចិនទេ ពោលគឺនិយមន័យរបស់ វីលមុត ក៏បញ្ចូលផងដែរនូវបុគ្គលទាំងឡាយណាដែលមានអារម្មណ៍ថាខ្លួនជាចិន ។ និយមន័យនេះស័ក្តិសមទៅនឹងការសិក្សានេះ ព្រោះវារួមបញ្ចូលនូវឥទ្ធិពលដែលប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងការពិតដែលថាមិនមែនអ្នកដែលចាត់ទុកខ្លួនឯងជាជនជាតិចិនទាំងអស់សុទ្ធតែបានចូលរួមក្នុងសហគមន៍ចិនទេ ហើយបញ្ច្រាសមកវិញក៏មិនមែនសមាជិកទាំងអស់ក្នុងសហគមន៍សុទ្ធតែចាត់ទុកខ្លួនឯងជាជនជាតិចិនសុទ្ធសាធនោះដែរ ។ អ្នកទាំងនោះប្រហែលជាមានអារម្មណ៍ថាខ្លួនមានសញ្ជាតិពីរ គឺជាប់ខ្សែស្រឡាយតាំងពីដូនតាជាមួយប្រទេសចិន និងភក្តីភាពខាងនយោបាយចំពោះប្រទេសខ្មែរនិងព្រះមហាក្សត្រខ្មែរ ។*

*២) ប្រវត្តិសាស្ត្រ*

*ជនអន្តោប្រវេសន៍ចិនភាគច្រើនបំផុតបានធ្វើដំណើរមកប្រទេសកម្ពុជាដោយសារខ្លួនជួបការលំបាកនៅប្រទេសចិន ។ ឯកអគ្គរដ្ឋទូតពិសេសរបស់ចិនបានសរសេរនៅក្នុងសតវត្សរ៍ទី១៣ថា អ្នកបើកទូកក្តោងចិនខាងត្បូងបានភៀសខ្លួនមកប្រទេសកម្ពុជាដោយសង្ឃឹមថានឹងមានជីវភាពរស់នៅសុខស្រួលជាងមុន ។ អ្នកខ្លះទៀតមកប្រទេសកម្ពុជាដើម្បីស្វែងរកស្បៀងអាហារ រកប្រពន្ធ ផ្ទះសម្បែង គ្រឿងសង្ហារិម លទ្ធភាពធ្វើជំនួញ ក្នុងគោលបំណងគេចពីបន្ទុកពន្ធដារនិងគ្រោះទុរ្ភិក្ស ។ នៅក្នុងចំណោមជនភៀសខ្លួនទាំងនេះ ក៏មានជនភៀសខ្លួនដោយមូលហេតុនយោបាយដែរ ។ ជាទូទៅ មានកិច្ចសហប្រតិបត្តិការជាលក្ខណៈជាតិនិយមតិចតួចណាស់ក្នុងចំណោមជនជាតិចិននៅកម្ពុជា ។ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១៧ ទើបមានភ័ស្តុតាងខ្លះបញ្ជាក់ថា ជនជាតិចិនទាំងនោះមានសកម្មភាពជាសហគមន៍ចិនមួយ ។*

*តាំងពីដើមរៀងមក ជនជាតិចិននៅកម្ពុជាគឺជាអ្នកជំនួញ ។ ការដោះដូរផ្នែកសេដ្ឋកិច្ចរវាងខ្មែរនិងចិនបានចាប់ផ្តើមតាំងពីសតវត្សរ៍ទី៣មកម្ល៉េះ ហើយការយកសួយសារអាករដែលត្រូវបានកត់ត្រាជាលើកដំបូងគឺនៅឆ្នាំ២២៥ ។ ចាប់ពីសតវត្សរ៍*

ទី១៣ដល់១៩ អ្នកគ្រប់គ្រងប្រទេសកម្ពុជាបានទទួលស្គាល់តម្លៃវប្បធម៌និងសេដ្ឋកិច្ចរបស់អ្នកតាំងទីលំនៅដែលមិនមែនជាជនជាតិខ្មែរ ។ ម្ល៉ោះហើយ ជនបរទេសទាំងនោះក៏ទទួលបាននូវសិទ្ធិស្របច្បាប់ដូចជាប្រជាជនកម្ពុជាដែរ ។ នៅក្នុងជួររាជការក្រោយពីច្បាប់ភូមិបាលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ១៦៩៣ ជនជាតិចិន វៀតណាម ជ្វា ម៉ាឡេ និង ជប៉ុន ដែលរស់នៅលើទឹកដីខ្មែរ អាចក្លាយជាអភិបាលខេត្តបានជាថ្នូរនឹងសួយសារអាករជាប្រចាំ ។ ក្នុងនាមជាមន្ត្រីនៃរាជបល្ល័ង្ក ជនជាតិចិនបានចូលរួមនៅក្នុងសង្គមកម្ពុជា ប៉ុន្តែខ្លួននៅរក្សាអត្តសញ្ញាណវប្បធម៌របស់ខ្លួនដដែលដូចជាតាមរយៈការរក្សាម៉ូតសក់ សម្លៀកបំពាក់ ការគោរពបូជា សិល្បៈ និងការកម្សាន្តនានា ។ ជាញឹកញាប់ អ្នកទាំងនេះទទួលបាននូវការសរសើរចំពោះលក្ខណៈទាំងប៉ុន្មានខាងលើនេះ ។ នៅតាមមូលដ្ឋាន ជនជាតិចិនក៏បានចូលរួមមួយផ្នែកនៅក្នុងសង្គមខ្មែរដែរ ។ នៅពេលដែលអាជ្ញាធរអាណានិគមបារាំងហាមឃាត់ការធ្វើអន្តោប្រវេសន៍នៃស្ត្រីជនជាតិចិន បុរសជនជាតិចិនភាគច្រើនរៀបការជាមួយស្ត្រីខ្មែរ ។ ប្រពន្ធរបស់ជនជាតិចិនអាចដើរចូលផ្ទះអ្នកស្រុក អ្នកភូមិ ដើម្បីដោះដូរទំនិញនិងផលដំណាំនៅក្នុងរដូវប្រមូលផល ដែលប្រការនេះធ្វើឲ្យជនជាតិចិនកាន់តែងាយស្រួលក្នុងការពង្រីកជំនួញរបស់ខ្លួន ។ ហេតុដូចនេះ ការផ្លាស់ប្តូរក្រោយៗមកទៀតអនុញ្ញាតឲ្យមានការធ្វើអន្តោប្រវេសន៍ស្ត្រីជនជាតិចិន ដែលធ្វើឲ្យការរៀបអាពាហ៍ពិពាហ៍រវាងបុរសចិននិងស្ត្រីខ្មែរ កាន់តែមានចំនួនតិចទៅៗ និងធ្វើឲ្យមានការបំបែកសហគមន៍កាន់តែច្រើនឡើងៗ ។

ទោះជាមានកិច្ចព្រមព្រៀងជាផ្លូវការជាមួយរដ្ឋាភិបាលចិនក្តី ក៏អាកប្បកិរិយារបស់បារាំងចំពោះជនភៀសខ្លួនជនជាតិចិនមកកម្ពុជា នៅតែមានភាពផ្ទុយគ្នាយ៉ាងខ្លាំង ។ នៅឆ្នាំ១៨៦០ អនុសញ្ញាស្តីពីអាណាព្យាបាលបារាំងនៅកម្ពុជា បានអនុញ្ញាតឲ្យមានការធ្វើអន្តោប្រវេសន៍ច្រើនថែមទៀត ហើយកិច្ចព្រមព្រៀង “ឈីង” ជាមួយអង់គ្លេសនិងបារាំងបានទទួលស្គាល់សិទ្ធិជនជាតិចិនឲ្យចូលធ្វើការងាររាជការ និងការពារជនជាតិចិននៅក្នុងអាណានិគមរបស់ខ្លួន ។ បារាំងមានមន្ទិលសង្ស័យមកលើជនអន្តោប្រវេសន៍ជនជាតិចិន ។ បារាំងជឿថា ជនជាតិចិនគឺជាពាណិជ្ជករលោភលន់ដែលគ្រេកគ្រអាលសប្បាយនឹងការជក់អាភៀន លេងល្បែងស៊ីសង ជម្រិតលុយ និងបូមយកទ្រព្យសម្បត្តិប្រទេសម្ចាស់ផ្ទះ រួចហើយបញ្ជូនទ្រព្យសម្បត្តិទាំងនោះទៅឲ្យគ្រួសាររបស់ខ្លួនដែលរស់នៅប្រទេសចិន ។ បារាំងទទូចឲ្យមានការបង្រៀនគណិតវិទ្យានៅសាលាដើម្បីការពារកុំឲ្យជនជាតិចិនដែលមិនស្មោះត្រង់ដើរវែ្យលើជនជាតិខ្មែរបាន ។ ប៉ុន្តែផ្ទុយស្រឡះពីការព្រួយបារម្ភរបស់បារាំង ជនជាតិខ្មែរខ្លះហាក់ដូចជាគោរពចរិតធ្វើជំនួញរបស់ជនជាតិចិនទៅវិញ ។ អត្ថបទមួយចុះផ្សាយឆ្នាំ១៩៣១ នៅក្នុងកាសែត “នគរវត្ត” ដែលជាកាសែតជាតិរបស់ខ្មែរលើកដំបូងបង្អស់ បានសរសើរថា ជនជាតិចិនខស្សាហ៍ព្យាយាមនិងចេះសន្សំសំចៃ ។ អ្នកនិពន្ធបានជំរុញឲ្យជនជាតិខ្មែរធ្វើឲ្យបានល្អដូចជាជនជាតិចិនអ៊ីចឹងដែរ ។ អ្នកនិពន្ធអះអាងថា ប្រជាជនខ្មែរមានភាពឆ្លាតវៃមិនចាញ់ជនជាតិចិនទេ ប៉ុន្តែភាពខុសគ្នាសំខាន់នោះគឺឆន្ទៈរបស់ជនជាតិចិនចំពោះការងារ និងការរៀបចំចាត់ចែងសង្គមរបស់ជនជាតិចិន ។ អ្នកនិពន្ធស្នើថា ប្រជាជនខ្មែរគួរតែយកគំរូតាមអាកប្បកិរិយារបស់ជនជាតិចិន ។

បារាំងបានទទួលផលប្រយោជន៍ពីវត្តមានរបស់ជនជាតិចិននៅកម្ពុជា ប៉ុន្តែចេះតែបន្តមានបំណងរឹតត្បិតសកម្មភាពជំនួញរបស់ជនជាតិចិន ប៉ុន្តែមិនដែលបានសម្រេចឡើយ ។ ជនជាតិចិនគឺជាឈ្មួញកណ្តាលនៅក្នុងសេដ្ឋកិច្ចកម្ពុជា ។ ឯកសារអាណានិគមដំបូងបង្អស់បង្ហាញថា ជនជាតិចិនចូលរួមច្រើនជាងគេនៅក្នុងជំនួញខ្នាតតូច បើកហាងទំនិញ លក់គ្រឿងហូបចុក និងទិញកសិផលពីកសិករខ្មែរ ។ អភិបាលអាណានិគមនិងសហគ្រិនខ្លះ ក៏បាននាំចូលនូវកម្មករចិនដែលពុំមានជំនាញ ដើម្បីបង្កើតសហគមន៍កសិកម្មនិងចម្ការ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏បារាំងចង់ការពារជនជាតិខ្មែរកុំឲ្យទទួលនូវការវាយលុក ដោយសារជំនាញដ៏ចំណានរបស់ជនជាតិចិន តាមរយៈការរឹតត្បិតកម្មសិទ្ធិដីធ្លីនិងផ្តល់ការងារមួយចំនួនតូចប៉ុណ្ណោះដល់ជនជាតិចិន ។ បារាំងក៏បានព្យាយាមរឹតត្បិតការរៀបចំចាត់ចែង ពិសេសរវាងជនជាតិចិនខ្លះនិងរាជវាំងទាក់ទងនឹងភាពផ្តាច់មុខ និងឥទ្ធិពលរបស់ជនជាតិចិន ដោយបានដាក់ចេញនូវកំណែទម្រង់ផ្នែកហិរញ្ញវត្ថុ បិទបនល្បែង និងហាមឃាត់ការផលិតអាភៀន ។ ប៉ុន្តែជាទូទៅ កិច្ចខិតខំប្រឹងប្រែងរបស់

បារាំងមានឥទ្ធិពលតិចតួចណាស់ទៅលើការបែងចែកសេដ្ឋកិច្ច និងការងារផ្សេងៗ រវាងជនជាតិខ្មែរនិងជនជាតិចិន ។ លើសពីនេះទៀត អ្នករៀបចំផែនការទីក្រុងរបស់អាណានិគមបារាំង បានបែងចែកសេដ្ឋកិច្ចនិងជនជាតិ ដោយឲ្យប្រជាជនខ្មែរ ជនជាតិចិន វៀតណាម និងអឺរ៉ុប រស់នៅសង្កាត់ផ្សេងៗគ្នានៅក្នុងទីក្រុង ។

ទោះបីជាត្រូវប្រឈមមុខនឹងការមិនចូលចិត្តពីសំណាក់បារាំងក៏ដោយ ជាតិនិយមនៅក្នុងសហគមន៍ចិននៅកម្ពុជា ដំបូងឡើយ ហាក់ដូចជាផលវិបាកនៃវិវត្តន៍នយោបាយក្នុងប្រទេសចិន ។ ការតស៊ូរវាងរដ្ឋាភិបាល ឈីង និងក្រុមជាតិនិយម ក្កួកម៉េងតាំង ដែលដឹកនាំដោយ ស៊ុន យ៉ាត សេន មានសារសំខាន់ជាពិសេស ។ ការជំរុញលើកទឹកចិត្តរបស់ ស៊ុន យ៉ាត សេន ឲ្យមានសាលារៀនចិន ក្នុងគោលបំណងពង្រឹងវប្បធម៌ចិននោះ បានផ្តល់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៃសហគមន៍ និងការបែងចែកកាន់តែធំឡើងៗពីប្រជាជនខ្មែរ ដែលជាជនជាតិភាគច្រើន ។ ការដែលរដ្ឋាភិបាល ឈីង ទទួលស្គាល់ជនជាតិចិននៅបរទេសថាជាជនរួមជាតិរបស់ខ្លួនបានពង្រឹងនូវអត្តសញ្ញាណជាតិចិននៅឯបរទេស ។ អត្តសញ្ញាណចិនលែងត្រូវបានរឹតត្បិតដោយសារព្រំដែនភូមិសាស្ត្រទៀតហើយ ។ អ្នកទាំងនោះគឺជាជនជាតិចិន មិនគិតថាគេកើតនៅទីណាទេ ។ ប្រការនេះបានធ្វើឲ្យផ្លាស់ប្តូរទស្សនៈចិនចំពោះទឹកដីកំណើតនិងផ្លាស់ប្តូរទស្សនៈដែលចាត់ទុកខ្លួនឯងជនបរទេស ។ រដ្ឋាភិបាលចិនប្រមូលការហូរចូលឥតឈប់ឈរនូវមូលធនទៅក្នុងប្រទេសរបស់ខ្លួន ដែលបានមកពីជនជាតិចិននៅក្រៅប្រទេសផ្ញើមកឲ្យបងប្អូនសាច់ញាតិរបស់ខ្លួន ដែលរស់នៅប្រទេសចិនដីគោក ។ ប្រការនេះបាននាំឲ្យមានការរំពឹងថារដ្ឋាភិបាលចិននឹងខកចិត្តចំពោះស្ថានភាពរស់នៅរបស់ជនជាតិចិននៅក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់ពីទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ អ្នកជាតិនិយមខ្មែរមិនសូវអត់ឱនចំពោះសហគមន៍ចិននៅកម្ពុជាឡើយ ។ អ្នកជាតិនិយមខ្មែរបានដាក់ការរឹតត្បិតមួយចំនួនទៅលើវប្បធម៌ចិន ហើយសម្តេច សីហនុ បានប្រើច្បាប់លេខ៩១៣-NS (ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៥៤) ក្នុងគោលបំណងរឹតត្បិតជនជាតិចិន មិនឲ្យទទួលបាននូវសិទ្ធិជាពលរដ្ឋខ្មែរ សិទ្ធិធ្វើជំនួញ និងធ្វើការងារមួយចំនួន ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៥០ ការហាមប្រាមបន្ថែមទៀត ត្រូវបានធ្វើឡើងដើម្បីរារាំងជនបរទេសមិនឲ្យចូលក្នុងផ្នែកពាណិជ្ជកម្មមួយចំនួន ។ ជាទូទៅ គោលបំណងថ្មីក្នុងការរឹតត្បិតជនជាតិចិននៅក្នុងសកម្មភាពពាណិជ្ជកម្មនិងឥទ្ធិពលរបស់ខ្លួន ក៏ត្រូវបរាជ័យដែរ ។

កម្រិតនៃអរិភាពកើតចេញពីរដ្ឋបាលចំពោះជនជាតិចិននៅកម្ពុជា ចាប់ពីទទួលបានឯករាជ្យរហូតដល់ការដួលរលំនៃសម្តេច សីហនុ នៅឆ្នាំ១៩៧០ ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីការវិវឌ្ឍន៍ផ្នែកទំនាក់ទំនងការទូតរវាងប្រទេសចិននិងកម្ពុជា ។ ទំនាក់ទំនងការទូតរវាងចិននិងកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៦ ។ នៅក្នុងឱកាសនោះ ជូ អេង ឡាយ បានថ្លែងសុន្ទរកថាទៅកាន់សាធារណជន ដោយជំរុញជនជាតិចិនរស់នៅកម្ពុជាឲ្យគោរពច្បាប់និងសាសនាទំនៀមទម្លាប់ប្រពៃណីខ្មែរ ។ ទំនាក់ទំនងដែលមានលក្ខណៈស្និតល្មួតរវាងប្រទេសទាំងពីរបានចុះអន់ថយទៅៗ នៅពាក់កណ្តាលចុងទសវត្សរ៍ឆ្នាំ១៩៦០ ជាពេលដែលប្រទេសចិនកំពុងស្ថិតក្នុងចលនាបដិវត្តន៍វប្បធម៌ ។ ការទូតជាសាធារណៈចេះតែបន្តបិទបាំងនូវទំនាក់ទំនងមុខពីររវាងថ្នាក់ដឹកនាំចិននិងកម្ពុជា ។ ដោយមិនសប្បាយចិត្តចំពោះការមានតែទំនាក់ទំនងកម្រិតជាតិជាមួយកម្ពុជា រដ្ឋាភិបាលចិនបានស្វះស្វែងដេញឥទ្ធិពលទៅលើជនជាតិចិននៅក្នុងប្រទេសកម្ពុជា តាមរយៈការរៀបចំសមាគមផ្សេងៗ ជាពិសេសបើកសាលារៀន បើកសារព័ត៌មាន («កម្ពុជាថ្ងៃនេះ»១៩៦៣) ។ ជាប្រពៃណី សមាគម និងបណ្តាញតូចៗដទៃៗទៀតបានផ្តល់ឲ្យសមាជិករបស់ខ្លួននូវការគាំទ្ររបស់សមាគមនៅក្នុងគ្រាមានអាសន្ន ។ ប៉ុន្តែមកដល់ត្រឹមចុងទសវត្សរ៍ឆ្នាំ១៩៦០ សមាគមចិនត្រូវបានកាត់ផ្តាច់ពីប្រជាជនខ្មែរ ។ សិស្សានុសិស្សចិនខ្លះត្រូវបានបង្រៀនឲ្យគាំទ្រលទ្ធិម៉ៅនិយមនៅកម្ពុជា ហើយមួងម្កាល គឺឲ្យគាំទ្របក្សកុកម៉េងតាំងដែលប្រឆាំងលទ្ធិម៉ៅនិយម ។ បន្ទាប់មក សិស្សានុសិស្សចិនជាច្រើនបានចូលរួមជាមួយពួកខ្មែរក្រហមកុម្មុយនិស្ត ។ ស្ថានការណ៍ចេះតែអាក្រក់ទៅៗ ជាពិសេសទាក់ទងទៅនឹងកាសែតជាភាសាចិន ។ សម្តេច សីហនុ ចូលមកដោះស្រាយ ដោយមានការជ្រៀតជ្រែករបស់ចិន

ចូលក្នុងកិច្ចការកម្ពុជា និងក្នុងពេលដែលមានកុប្បកម្មពួកកុម្មុយ-និស្តដែលចេះតែកើនឡើងជាលំដាប់ ។ កាសែតទាំងនោះត្រូវបានបញ្ឈប់ឲ្យបិទ សមាគមមិត្តភាពខ្មែរ-ចិនត្រូវបានរំលាយចោលដូចជាសមាគមនិស្សិតខ្មែរទូទៅដែរ ។ កាសែតដែលនាំចូលមកពីសាធារណរដ្ឋប្រជាមានិតចិនត្រូវបានហាមប្រាម ហើយកាសែតមកពីហុងកុង តៃវ៉ាន់ និងសិង្ហបូរី ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ។ កាសែតអ្នកជាតិនិយមពន្យល់ថា ការសម្រេចចិត្តទាំងនេះគឺធ្វើឡើងក្នុងគោលបំណង «ធ្វើឲ្យមិត្តចិនរបស់យើងយល់ថាកម្ពុជាមិនអាចផ្តល់នូវអាជ្ញាប័ណ្ណនាំចូលដ៏សំខាន់អំពីបដិវត្តន៍វប្បធម៌ដែលកម្ពុជាមិនត្រូវការឡើយ» ។

នៅពេលសង្គ្រាមវៀតណាមរាលដាលកាន់តែខ្លាំងឡើងៗ ស្ថានភាពរបស់ជនជាតិចិននៅប្រទេសកម្ពុជាក៏កាន់តែអាក្រក់ទៅៗ ។ សេនាប្រមុខ លន់ ណុល ដែលជាអ្នកផ្តួលរំលំសម្តេចសីហនុ ក៏ចាត់ទុកអត្តសញ្ញាណជាតិថាត្រូវមានលក្ខណៈខ្មែរទាំងស្រុង ។ ការសម្លាប់រង្គាលដែលជាការដាក់ទណ្ឌកម្មរបស់រដ្ឋាភិបាលទៅលើជនជាតិវៀតណាមរាប់រយនាក់កាលពីពីរខែមុនពេល លន់ ណុល ឡើងកាន់អំណាច បានធ្វើឲ្យជនជាតិចិនរអើលខ្លួន ។ ជនជាតិចិនយល់ថា សេចក្តីណែនាំរបស់ លន់ ណុល ដល់មន្ត្រីរដ្ឋាភិបាល ឲ្យមានការរារាំងការពារមិនឲ្យប៉ះពាល់ជនជាតិចិនគឺគ្រាន់តែធ្វើឲ្យល្អមើលប៉ុណ្ណោះ ។ លន់ ណុល បានវាយប្រហារទៅលើជនជាតិចិនជាប់រហូត ហើយបញ្ឈប់ឲ្យបិទសាលាភាសាចិនជាច្រើនក្រោមលេសថាសាលាទាំងនោះគឺជាសាលាភាសាកុម្មុយ-និស្ត ។ នៅក្នុងយុទ្ធនាការដើម្បីរកអ្នកគាំទ្រកុម្មុយនិស្ត ជាញឹកញយកម្លាំងនគរបាលរបស់ លន់ ណុល បានចាប់ខ្លួនប្រជាជនដែលមានដើមកំណើតជនជាតិចិន ។ ប៉ែកឃ័រ បានពិពណ៌នាកាលពីឆ្នាំ១៩៨៦ថា «លន់ ណុល បានប្រើប្រាស់សារព័ត៌មានក្នុងស្រុក ដើម្បីធ្វើយុទ្ធនាការប្រឆាំងវណ្ណៈនាយទុនដ៏លោភលន់ដែលកំពុងឆ្លៀតទាញយកផលប្រយោជន៍ពីសភាពការណ៍ស្រុកទេសមានសង្គ្រាម ហើយដំឡើងថ្លៃទំនិញ...» ។ នៅក្រោមការគ្រប់គ្រងរបស់សាធារណរដ្ឋខ្មែរ និងនៅចំពេលមានសង្គ្រាមស៊ីវិល ជីវិតរស់នៅរបស់ជនជាតិចិនកាន់តែពិបាកនិងមានគ្រោះថ្នាក់ថែមទៀត ។ ***(នៅមានត)***

**ច័ន្ទ សម្បត្តិ**



# បាត់ខ្លួនជារៀងរហូត

ភូមិត្បូងក្រពើ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ៖ គ្រាន់តែសួររកកូនលោកយាយ នុត នៅពេលឡើងទៅដល់លើផ្ទះ លោកយាយងើបដើរទៅយកកាបូបតូចមួយដែលរុំដោយក្រឡ ក្រាស់ឃ្មឹក មកបង្ហាញយើង ។ ក្នុងវ័យចំណាស់លោកយាយបន្លឺសំឡេងញ័រខ្សាវៗថា «ខ្ញុំរក្សាវាទុកយូរហើយមិនឲ្យបាត់ទេ




ទោះបីជាឆ្លងកាត់ក្នុងរបប ប៉ុល ពត ក៏ដោយ» ។

លោកយាយ នុត មានកូនប្រុសម្នាក់ឈ្មោះ នុត អុន ។ កូនរបស់លោកយាយបានបាត់ខ្លួនរហូត ចាប់តាំងពីចូលបម្រើការងារនៅក្នុងរបប ប៉ុល ពត ។ របបនេះជាប់ចំណាត់ថ្នាក់នៅក្នុងទសវត្សរ៍ទី២០ ខាងអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរជាងគេបំផុត ។ តាមរយៈការស្រាវជ្រាវបានបង្ហាញថា របបនេះបានសម្លាប់ប្រជាជនកម្ពុជាប្រមាណពីរលាននាក់ នៅក្នុងអំឡុងពេលជាងបីឆ្នាំនៃការគ្រប់គ្រងប្រទេសកម្ពុជា ។ ក្នុងចំណោមជនរងគ្រោះរាប់លាននាក់ គឺមានកូនប្រុសរបស់លោកយាយ នុត ម្នាក់ដែរ ។

ថ្មីៗនេះ ក្តីសង្ឃឹមថានឹងមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានមើលឃើញជាបណ្តើរៗវិញ ។ អង្គការសហប្រជាជាតិបានយល់ព្រមវិលមកធ្វើការចរចាជាមួយរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីប្រកាសដកខ្លួននៅក្នុងខែកុម្ភៈ ឆ្នាំ ២០០២ ។ ចំណែកឯរដ្ឋាភិបាលកម្ពុជាបានស្វាគមន៍ចំពោះដំណើរវិលត្រឡប់មកចរចាវិញរបស់អង្គការសហប្រជាជាតិ និងត្រៀមខ្លួនជាស្រេចដើម្បីធ្វើកិច្ចការនេះ ក្នុងគោលបំណងដ៏ចម្បងមួយគឺស្វែងរកយុត្តិធម៌ និងការផ្សះផ្សាជាតិ ។

ជាមួយគ្នានឹងកិច្ចការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដ៏មានសភាពក្តៅគគុកក៏ដោយ លោក យាយ នុត នៅតែទន្ទឹងរង់ចាំដំណឹងពីកូនរបស់គាត់ដែរ ។ លោកយាយទទួលអារម្មណ៍រំភើបរហូតដល់ស្រក់ទឹកភ្នែក ក្នុងខណៈដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅដល់ផ្ទះ និងសួរនាំរកឈ្មោះកូនរបស់គាត់ ។ លោកយាយនិយាយមកកាន់ក្រុមយើងថា «ជាលើកទី១ហើយដែលមានក្រុមក្មួយៗមកសួររកកូនខ្ញុំ» ។

ទាំងដៃរាងញ័រៗបន្តិចផង លោកយាយបានបើកកាបូបតូចហើយហូតយករូបថតកូនរបស់គាត់ដែលថតតាំងពីនៅជាសិស្សសាលា មកឲ្យយើងមើល ។ លោកយាយក៏បានបង្ហាញស័ក្តិរបស់ប្តីគាត់ ក្នុងឋានន្តរស័ក្តិដោយបីជាន់ ក្នុងសង្គមរាស្ត្រនិយម ។ លោកយាយប្រាប់ថា «គាត់ស្លាប់ហើយ» ។ លោកយាយនៅសល់តែកូនស្រីម្នាក់ ប៉ុន្តែបានរៀបការនិងទៅរស់នៅដោយឡែក ។

នៅពេលខ្មែរក្រហមរត់ចេញពីទីក្រុងភ្នំពេញ ឈ្មោះ សូត្រ បាននិយាយប្រាប់យាយ នុត ថា កូនរបស់គាត់បានស្លាប់ទៅហើយ ដោយសារជំងឺគ្រុនចាញ់ ។ ក៏ប៉ុន្តែលោកយាយ នុត នៅតែមិនទាន់អស់ចិត្តនៅឡើយ ព្រោះមិនបានឃើញនឹងភ្នែកផ្ទាល់របស់គាត់ ។ លោកយាយផ្តាំក្រុមយើងម្តងហើយម្តងទៀតថា «ក្មួយ! បើបានដំណឹងកូនរបស់ខ្ញុំ ជួយផ្តល់ឲ្យខ្ញុំផង ។ យប់មិញខ្ញុំមិនដឹងជាយ៉ាងម៉េចក្នុងខ្លួនរសាប់រសល់ ។ ខ្ញុំថាមុខតែកូនខ្ញុំមកផ្ទះហើយមើលទៅ» ។

ទោះបីជាលោកយាយមិនបានទទួលដំណឹងថាកូនលោកយាយនៅទីណាក្តី ក៏លោកយាយថា «ខ្ញុំអរគុណក្មួយៗដែលបានមកសួរនាំរកកូនរបស់ខ្ញុំ» ។ នៅក្នុងភូមិដែលលោកយាយរស់នៅសព្វថ្ងៃ មិនត្រឹមតែមានកូនលោកយាយ នុត ម្នាក់ប៉ុណ្ណោះទេ ដែលបាត់ខ្លួនបន្ទាប់ពីចូលបម្រើក្នុងជួរបដិវត្តរបស់ខ្មែរក្រហម គឺនៅមានកូនចៅ បងប្អូនអ្នកភូមិជាច្រើនទៀតដែលបាត់ខ្លួន ។

**ឆ៉ាន់ថាន់ ពៅដារ៉ា**

# សិទ្ធិរបស់ជនរងគ្រោះ

“ចូរចងចាំថា នៅក្នុងសតវត្សរ៍នេះមានកុមារ ស្ត្រី និង បុរស រាប់លាននាក់ ក្លាយជាជនរងគ្រោះនៃអំពើឃោរឃៅមិននឹកស្មានដល់ ដែលធ្វើឲ្យតក់ស្លុតដល់មនសិការរបស់មនុស្សជាតិទាំងមូល” ។ (បុព្វកថានៃលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ) ។

ការផ្តល់មធ្យោបាយនានាដើម្បីសម្រេចបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដ៏សែនរន្ធត់ គឺជាគោលដៅចម្បងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ មិនតែប៉ុណ្ណោះ ស្ថានភាពទូទៅនិងស្ថានភាពអាក្រក់របស់ជនរងគ្រោះដោយសារជម្លោះជុំវិញពិភពលោក គឺជាប្រភពនៃការជំរុញដល់ទឹកចិត្តអ្នកតាក់តែងសេចក្តីព្រាងលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ។ ហេតុដូចនេះ សិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះនៃបទឧក្រិដ្ឋដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការជំនុំជម្រះក្តី គឺជាធាតុផ្សំដែលមិនអាចខ្វះបាននៃលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ។

លក្ខន្តិកៈច្បាប់នៅទីក្រុងរ៉ូមត្រូវបានព្រាងឡើង ដើម្បីជាប្រយោជន៍ដល់តម្រូវការជាក់ស្តែងនិងសិទ្ធិរបស់ជនរងគ្រោះទាំងក្នុងក្របខ័ណ្ឌជាសាក្សីសម្រាប់ដំណើរការជំនុំជម្រះនិងក្របខ័ណ្ឌបុគ្គលដែលឈរការពារសិទ្ធិរបស់ផងខ្លួន ។

## ព្រឹត្តិការណ៍ជុំវិញ

មុនទសវត្សរ៍ឆ្នាំ១៩៩០ មិនសូវមានការផ្តោតការយកចិត្តទុកដាក់ចំពោះទស្សនៈវិស័យរបស់ជនរងគ្រោះនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌ប៉ុន្មានទេ ។ ជារឿយៗ ការឈឺចាប់របស់ជនងគ្រោះត្រូវបានយកមកប្រើប្រាស់ជាការប្រឌិត ជានយោបាយឆ្លើយតបទៅនឹងការរំលោភច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ ជាជាងយកបុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភច្បាប់នោះមកកាត់សេចក្តី ឬដោះស្រាយតម្រូវការចាំបាច់របស់បុគ្គលដែលត្រូវបានគេរំលោភសិទ្ធិរបស់ខ្លួន ។ ការកាត់សេចក្តីចារីនៃបទល្មើសដែលរំលោភច្បាប់អន្តរជាតិ គឺកម្រមានណាស់ ហើយជាលទ្ធផល ធ្វើឲ្យជនរងគ្រោះខកចិត្តយ៉ាងខ្លាំង ។

ការបង្កើតឡើងនូវតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវី គឺជាចំណុចគន្លឹះនៃការវិវឌ្ឍន៍ស្ថានភាពរបស់ជនរងគ្រោះនៅក្នុងដំណើរការជម្រះក្តីព្រហ្មទណ្ឌជាអន្តរជាតិ ។ លក្ខន្តិកៈច្បាប់របស់តុលាកាទាំងនោះសំដៅជាពិសេសទៅលើតួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការវិនិច្ឆ័យទោស ទោះបីជាភាគច្រើនមានលទ្ធភាពការពារខ្លួនក៏ដោយ ។ តួនាទីនិងផលប្រយោជន៍របស់ជនរងគ្រោះក្រោមនីតិព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានធ្វើឲ្យចម្រើនទៅមុខតាមរយៈការអនុម័តិលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមដែលក្នុងនោះជនរងគ្រោះមិនត្រឹមតែត្រូវបានការពារទេ ប៉ុន្តែសិទ្ធិនិងផលប្រយោជន៍របស់ជនរងគ្រោះត្រូវបានទទួលស្គាល់ ហើយការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការជំនុំជម្រះក្តីត្រូវបានជំរុញ ។

## ដំណោះស្រាយកែតម្រូវសម្រាប់បុគ្គលប្រឆាំងនឹងចារី

ច្បាប់អន្តរជាតិត្រូវបានចាត់ទុកជាប្រពៃណីថាជា “ច្បាប់រវាងរដ្ឋនិងរដ្ឋ” ។ តាមរយៈការតម្រង់ឆ្ពោះទៅសញ្ញាណដ៏យូរលង់នេះ លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមតំណាងឲ្យលិខិតូបករណ៍អន្តរជាតិដែលផ្តល់ដល់ជនរងគ្រោះនូវការបំពេញ និងផ្តោតការយកចិត្តទុកដាក់ទៅលើដំណោះស្រាយកែតម្រូវប្រឆាំងនឹងចារីនៃបទល្មើសជាបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលជាជនរងគ្រោះ ។

បុព្វកថានៃលក្ខន្តិកៈទីក្រុងរ៉ូមប្រកាសថាប្រទេសទាំងឡាយណាដែលជាភាគីនៃលក្ខន្តិកៈនេះ “ប្តេជ្ញាចិត្តបញ្ចប់និទណ្ឌភាពចំពោះជនដៃដល់ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ” ។ ជាងនេះទៅទៀត មាត្រា២៥បញ្ជាក់ច្បាស់ថា តុលាការត្រូវមានយុត្តាធិការលើរូបវន្តបុគ្គលអនុលោមតាមលក្ខន្តិកៈនេះ÷

**មាត្រា២៥: អំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈបុគ្គល**

១) តុលាការត្រូវមានយុត្តាធិការលើរូបវ័ន្តបុគ្គលអនុលោមតាមច្បាប់លក្ខន្តិកៈនេះ ។

២) ជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅក្នុងយុត្តាធិការតុលាការ ត្រូវទទួលខុសត្រូវនិងទទួលទណ្ឌកម្មជាលក្ខណៈបុគ្គលស្របតាមច្បាប់លក្ខន្តិកៈនេះ ។

៤) គ្មានបញ្ញត្តិណាមួយនៃច្បាប់លក្ខន្តិកៈនេះ ដែលទាក់ទងទៅនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ត្រូវប៉ះពាល់ដល់ការទទួលខុសត្រូវរបស់រដ្ឋក្រោមច្បាប់អន្តរជាតិឡើយ ។

ការសំដៅទៅលើរូបបុគ្គលនៃច្បាប់នេះរួមជាមួយនឹងការពិតដែលថា មាត្រា១៣(ក) និង មាត្រា១៣(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមអនុញ្ញាតឲ្យរដ្ឋនានានិងព្រះរាជអាជ្ញាចន្លុះបង្ហាញឲ្យមានការកាត់សេចក្តីដោយផ្អែកជាសំខាន់ទៅលើសំណើនិងពត៌មានផ្តល់ដល់ជនរងគ្រោះនូវភ្នាក់ងារដែលត្រូវបានផ្តល់អំណាចចាត់ការបញ្ហានេះ ។

### កង្វះនិទណ្ឌភាព

លក្ខណៈពិសេសមួយទៀតនៃលក្ខន្តិកៈទីក្រុងរ៉ូមគឺថា ច្បាប់នេះចែងថាចារីដែលត្រូវបានចោទប្រកាន់ហើយមិនអាចប្តឹងទាមទារសុំរួចខ្លួនពីការកាត់សេចក្តីពីបទឧក្រិដ្ឋក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានទេ ។

### មាត្រា២៧ៈ អំពីភាពមិនទាក់ទងនៃសម្បទាផ្លូវការ

១) ច្បាប់លក្ខន្តិកៈនេះត្រូវអនុវត្តដោយស្មើគ្នាលើជនគ្រប់រូបដោយគ្មានការខុសប្លែកគ្នាអ្វីផ្អែកលើសម្បទាផ្លូវការឡើយ ។ ជាពិសេសម្បទាជាប្រមុខរដ្ឋ ឬរដ្ឋាភិបាល ជាសមាជិករដ្ឋាភិបាល ឬសមាជិករដ្ឋសភាជាអ្នកតំណាងដែលបានជាប់ឆ្នោត ឬជាមន្ត្រីរដ្ឋាភិបាល និងគ្មានករណីលើកលែងឲ្យជនណាម្នាក់រួចពីការទទួលខុសត្រូវក្រោមច្បាប់លក្ខន្តិកៈនេះ ឬនៅក្នុងសម្បទា ឬនៃសម្បទាផ្ទាល់នេះ មិនត្រូវបង្កបង្កើតជាមូលដ្ឋានសម្រាប់ការបន្ធូរបន្ថយទោសឡើយ ។

ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សនិងការរំលោភច្បាប់មនុស្សធម៌ នឹងលែងឃើញចារីនៃបទឧក្រិដ្ឋជៀសផុតពីការកាត់ទោសដោយសារចារីទាំងនោះជាមន្ត្រីរបស់រដ្ឋាភិបាលតទៅទៀតហើយ ។

### ផ្នែកជនរងគ្រោះនិងសាក្សី

ដោយដឹងពីសារសំខាន់នៃសាក្សី និងភាពចាំបាច់ខានមិនបានរបស់ជនរងគ្រោះនិងសាក្សី ច្បាប់លក្ខន្តិកៈផ្តល់អាណត្តិដល់ក្រឡាបញ្ជីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងការបង្កើតនូវអង្គភាពជនរងគ្រោះនិងសាក្សីនៅក្នុងការិយាល័យក្រឡាបញ្ជីដើម្បីការពារនិងផ្តល់នូវសេវាកម្មប្រឹក្សាដល់ជនរងគ្រោះនិងសាក្សីតាមការចាំបាច់ជាក់ស្តែង ។ ដោយសារផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធទៅលើស្ត្រីនិងកុមារត្រូវបានផ្តោតការយក


ជនរងគ្រោះឡើងបំភ្លឺក្នុងតុលាការ ឆ្នាំ១៩៧៩

ចិត្តទុកដាក់ជាពិសេសនៅក្នុងលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមនោះ អង្គភាពជនរងគ្រោះនិងសាក្សីនឹងត្រូវមានបុគ្គលិកជាអ្នកជំនាញការខាងប្រឹក្សាយោបល់ ចំពោះបុគ្គលដែលបានទទួលរងនូវការប៉ះទង្គិចយ៉ាងខ្លាំងដោយសារអំពើហិង្សាខាងផ្លូវភេទ ។

### មាត្រា៤៣ៈ ក្រឡាបញ្ជី

៦) ក្រឡាបញ្ជីត្រូវបង្កើតឡើងនូវអង្គភាពជនរងគ្រោះនិងសាក្សីនៅក្នុងផ្នែកក្រឡាបញ្ជី ។ ដោយមានការពិគ្រោះយោបល់ជាមួយការិយាល័យអយ្យការ អង្គភាពនេះត្រូវផ្តល់នូវវិធានការការពារនានា ការរៀបចំខាងសន្តិសុខ ការផ្តល់ឱវាទ និងជំនួយការសមស្របដទៃទៀតឲ្យដល់សាក្សីឬជនរងគ្រោះដែលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងជនដទៃទៀតដែលស្ថិតក្នុងសភាពគ្រោះថ្នាក់បណ្តាលមកពីការផ្តល់សក្ខីកម្មដោយសាក្សី ។ អង្គភាពនេះត្រូវឲ្យមានបុគ្គលិកដែលមានជំនាញខាងការប៉ះទង្គិចផ្លូវចិត្ត រួមទាំងការប៉ះទង្គិចផ្លូវចិត្តដែលទាក់ទងទៅនឹងអំពើល្មើសព្រហ្មទណ្ឌនៃការបំពានផ្លូវភេទ ។

### ការស៊ើបអង្កេត

លក្ខន្តិកៈច្បាប់ក៏បានបញ្ជាក់អំពីទស្សនៈវិស័យរបស់ជនរងគ្រោះនៅក្នុងការស៊ើបអង្កេតទៅលើបទល្មើសដែលត្រូវបានចោទប្រកាន់ក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសការផ្តល់ភារកិច្ចដល់ព្រះរាជអាជ្ញាធ្វើការជាមួយជនរងគ្រោះ ។

### មាត្រា៥៤ៈ ភារកិច្ចនិងអំណាចរបស់ព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការស៊ើបអង្កេត

១) ព្រះរាជអាជ្ញាត្រូវតែៈ

ខ) ចាត់វិធានការសមស្របដើម្បីធានាដល់ការស៊ើបអង្កេតនិងការនាំយកមកជំនុំជម្រះប្រកបដោយប្រសិទ្ធភាពក្រោមយុត្តាធិការតុលាការនេះ ហើយដើម្បីធ្វើការនេះ ត្រូវគោរពនូវប្រយោជន៍និងកាលៈទេសៈបុគ្គលនៃជនរងគ្រោះនិងសាក្សីរួមមានអាយុ ភេទ ដូចមានចែងនៅ“ក”រួមទាំងសុខភាពទៀតផង ហើយត្រូវពិចារណាលើចរិតលក្ខណៈនៃបទល្មើសព្រហ្មទណ្ឌនោះ ជាពិសេសកាលណាមានការពាក់ព័ន្ធជាមួយការបំពានខាងផ្លូវភេទ ការបំពានខាងដែនឌ័រ ឬអំពើហិង្សាមកលើកុមារ ។ និង

គ) គោរពយ៉ាងពេញលេញនូវសិទ្ធិបុគ្គលទាំងឡាយដែលបានលើកឡើងនៅក្នុងច្បាប់លក្ខន្តិកៈនេះ ។

### ការការពារនៅពេលជំនុំជម្រះ

ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមមិនត្រឹមតែចែងអំពីការស៊ើបអង្កេតតាមការបង្ហាញផ្លូវរបស់ជនរងគ្រោះទៅលើបទល្មើសក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចែងអំពីសុវត្ថិភាពរបស់ជនរងគ្រោះនៅដំណាក់កាលជំនុំជម្រះទៀតផង រួមទាំងសំអាងរបស់ជនរងគ្រោះដូចដែលមានចែងនៅក្នុងប្រការ “មុខងារនិងអំណាចរបស់អង្គជំនុំជម្រះ” ។

### មាត្រា៦៤ៈ អំពីមុខងារនិងអំណាចរបស់សភាជំនុំជម្រះ

២) សភាជំនុំជម្រះត្រូវធ្វើឲ្យប្រាកដថា ការជំនុំជម្រះមានលក្ខណៈយុត្តិធម៌ និងលឿនរហ័ស ហើយត្រូវបានធ្វើឡើងដោយមានការគោរពពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ និងគិតគូរបានសមរម្យដល់ការការពារជនរងគ្រោះនិងសាក្សី ។

ជាពិសេសជាងនេះទៅទៀត ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមតម្រូវថា តុលាការព្រហ្មទណ្ឌអន្តរជាតិការពារនូវសុខុមាលភាពរបស់ជនរងគ្រោះនិងសាក្សី នៅក្នុងរបៀបដែលឆ្លើយតបទៅនឹងការចាំបាច់របស់បុគ្គលជនរងគ្រោះនីមួយៗ ។ នៅឯអង្គជំនុំជម្រះក្តី ជនរងគ្រោះត្រូវបានផ្តល់នូវការការពារៈ

### មាត្រា៦៨ៈ អំពីការការពារជនរងគ្រោះនិងសាក្សី និងការចូលរួមរបស់ពួកគេក្នុងដំណើរការជម្រះរឿងក្តី

១) តុលាការត្រូវចាត់វិធានការសមស្របដើម្បីការពារសុវត្ថិភាព សុខុមាលភាពខាងផ្លូវកាយនិងខាងផ្លូវចិត្ត សេចក្តីថ្លៃថ្នូរ និងការនៅស្ងៀមស្ងាត់គ្មានការរំខានឆាឆៅរបស់ជនរងគ្រោះ និងសាក្សី ។ ដើម្បីធ្វើដូច្នោះ តុលាការត្រូវគិតគូរលើកត្តាទាក់ទិនទាំងអស់ រួមទាំងកត្តាអាយុ កត្តាដែនឌ័រ ដូចមានកំណត់នៅក្នុងកថាខណ្ឌទី៣ នៃមាត្រា៧ ព្រមទាំងកត្តាសុខភាព និងជាពិសេសប៉ុន្តែមិនកម្រិតត្រឹមនេះទេ ប្រភេទបទល្មើសព្រហ្មទណ្ឌដែលបទល្មើសព្រហ្មទណ្ឌនោះពាក់ព័ន្ធលើការបំពានផ្លូវភេទឬផ្លូវដែនឌ័រ ឬអំពើហិង្សាលើកុមារ ។ ព្រះរាជអាជ្ញាត្រូវចាត់វិធានការនេះ ជាពិសេសអំឡុងពេលស៊ើបអង្កេត និងការនាំយកមកជំនុំជម្រះនូវបទល្មើសព្រហ្មទណ្ឌប្រភេទនេះ ។ វិធានការទាំងអស់នេះ

មិនត្រូវមានលក្ខណៈអគតិ ឬមានលក្ខណៈមិនស្របគ្នាជាមួយសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះដោយយុត្តិធម៌និងឥតលម្អៀងឡើយ ។

ច្បាប់លក្ខន្តិកៈក៏អនុញ្ញាតឲ្យមានសវនាការជាលក្ខណៈឯកជនដែរ ប្រសិនបើវាជាការចាំបាច់ក្នុងការការពារជនរងគ្រោះ÷

**មាត្រា៦៨ៈ អំពីការការពារជនរងគ្រោះនិងសាក្សី និងការចូលរួមរបស់ពួកគេ នៅក្នុងដំណើរការជម្រះរឿងក្តី**

(២) មានការលើកលែងចំពោះគោលការណ៍សវនាការជាសាធារណៈ ដូចមានចែងក្នុងមាត្រា៦៧ សភាទាំងឡាយនៃតុលាការអាចបើកដំណើរការជម្រះរឿងក្តីផ្នែកណាមួយនៅក្នុងបន្ទប់សម្ងាត់ ឬអនុញ្ញាតឲ្យបង្ហាញភស្តុតាងតាមមធ្យោបាយគ្រឿងអេឡិចត្រូនិច ឬតាមមធ្យោបាយពិសេសផ្សេងៗទៀតដើម្បីការពារជនរងគ្រោះនិងសាក្សី ឬជនជាប់ចោទ ។ ជាពិសេសវិធានការទាំងឡាយនោះត្រូវអនុវត្តក្នុងករណីជនរងគ្រោះដោយសារការបំពានផ្លូវភេទបង្ខិតសេពសន្ថវៈ ឬកុមារដែលជាជនរងគ្រោះ ឬសាក្សី លើកលែងតែមានបញ្ជារបស់តុលាការដោយគិតគូរដល់គ្រប់កាលៈទេសៈទាំងអស់ ជាពិសេសទស្សនៈរបស់ជនរងគ្រោះ ឬរបស់សាក្សី ។

(៤) អង្គភាពការពារជនរងគ្រោះនិងសាក្សីអាចផ្តល់យោបល់ដល់ព្រះរាជអាជ្ញានិងតុលាការ អំពីវិធានការការពារ ការរៀបចំសន្តិសុខ ការការពារ និងជំនួយការដែលសមស្រប ដូចមានចែងក្នុងកថាខណ្ឌទី៦ នៃមាត្រា៤៣ ។

(៥) កាលបើការបង្ហាញភស្តុតាង ឬព័ត៌មានអនុលោមតាមច្បាប់លក្ខន្តិកៈនេះអាចនាំឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សន្តិសុខរបស់សាក្សី ឬក្រុមគ្រួសាររបស់គាត់ ព្រះរាជអាជ្ញាអាចមិនលើកឡើងនូវភស្តុតាងឬព័ត៌មាននោះ ហើយជំនួសដោយការដាក់ជូននូវកំណត់ហេតុសង្ខេបវិញ សម្រាប់គោលបំណងនៃដំណើរការជម្រះរឿងក្តីដែលបានធ្វើឡើងមុនពេលចាប់ផ្តើមការជំនុំជម្រះ ។ វិធានការនេះត្រូវអនុវត្តក្នុងរបៀបមួយ ដែលមិនមានលក្ខណៈអគតិ ឬមិនមានលក្ខណៈមិនសមស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះដោយយុត្តិធម៌ និងឥតលម្អៀងឡើយ ។

(៦) រដ្ឋអាចស្នើសុំវិធានការចាំបាច់ដែលត្រូវអនុវត្តចំពោះការការពារអ្នកបម្រើការងារ និងភ្នាក់ងាររបស់ខ្លួនព្រមទាំងការពារព័ត៌មានសម្ងាត់ឬព័ត៌មានដែលមិនចង់ឲ្យដឹងឮ ។

**ការចូលរួមនៅក្នុងដំណើរការចោទប្រកាន់**

ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមមិនត្រឹមតែចែងអំពីទស្សនវិស័យ និងផលប្រយោជន៍របស់ជនរងគ្រោះដែលជាសាក្សីនៅក្នុងដំណើរការនីតិវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលស្គាល់សិទ្ធិនិងការឆ្លងកាត់របស់ជនរងគ្រោះ និងតួនាទីដែលជនរងគ្រោះមាននៅក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌមួយដែលមានប្រសិទ្ធភាពនិងសមធម៌ ។

ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមអនុញ្ញាតឲ្យជនរងគ្រោះថ្លែងឲ្យដឹងនៅពេលដែលព្រះរាជអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិសន្និដ្ឋានថាមានព័ត៌មានគ្រប់គ្រាន់សម្រាប់ដំណើរការរឿងក្តី ហើយសុំការអនុញ្ញាតពីអង្គបុរេជំនុំជម្រះដើម្បីចាប់ផ្តើមស៊ើបអង្កេត ។

**មាត្រា១៥ៈ អំពីព្រះរាជអាជ្ញា**

(៣) បើព្រះរាជអាជ្ញាសន្និដ្ឋានថាមានមូលដ្ឋានសមហេតុផលដើម្បីបន្តការស៊ើបអង្កេត ខ្លួនត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះនូវសំណើសុំធ្វើការស៊ើបអង្កេតភ្ជាប់ជាមួយនឹងឯកសារសំអាងគាំទ្រទាំងឡាយដែលប្រមូលបាន ។ ជនរងគ្រោះអាចដាក់សេចក្តីថ្លែងការណ៍ជូនអង្គបុរេជំនុំជម្រះអនុលោមតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

ដូចគ្នានេះដែរ នៅក្នុងការលំបាកមួយចំនួនទាក់ទិនទៅនឹងការទទួលយកនូវសំណុំរឿង ឬសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីជំនុំជម្រះរឿងក្តីមួយ ជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យដាក់ជូននូវការសង្កេតផ្ទាល់របស់ខ្លួនទៅតុលាការនៅក្នុងកាលៈទេសៈដែលថាសេចក្តីថ្លែងហេតុនឹងត្រូវចេញ ។

**មាត្រា១៩ៈ អំពីការប្រជែងតវ៉ាលើយុត្តាធិការតុលាការ ឬភាពអាចទទួលយកបាននៃករណីរឿងក្តី**

(៣) ព្រះរាជអាជ្ញាអាចស្វែងរកសេចក្តីសម្រេចពីតុលាការទាក់ទងទៅនឹងចំណោទបញ្ហាអំពីយុត្តាធិការ ឬភាពអាចទទួលយកបាន ។ នៅក្នុងដំណើរជម្រះរឿងក្តីទាក់ទងទៅនឹងយុត្តាធិការ ឬភាពអាចទទួលយកបានដែលបានដាក់ស្ថានភាពនោះ អនុលោមតាមមាត្រា១៣ ព្រមទាំងជនរងគ្រោះអាចដាក់ការកត់សម្គាល់

របស់ខ្លួនជូនតុលាការបាន ។

### ការចូលរួមក្នុងពេលជម្រះក្តី

ចំណុចសំខាន់ដែលគួរឲ្យកត់សម្គាល់គឺថា ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមធ្វើយ៉ាងណាធ្វើឲ្យសំឡេងនិងឱកាសរបស់ជនរងគ្រោះត្រូវបានគេឮនៅក្នុងដំណើរក្តីព្រហ្មទណ្ឌរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ មាត្រា៦៨(៣) អនុញ្ញាតឲ្យជនរងគ្រោះមានឱកាសចូលរួមនៅក្នុងដំណើរការជំនុំជម្រះក្តី ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចៅក្រមជំនុំជម្រះ ដោយបង្ហាញចេញនូវទស្សនៈយោបល់ និងការព្រួយបារម្ភរបស់ខ្លួននៅក្នុងកាលៈទេសៈដែលសមស្រប ។

### មាត្រា៦៨ៈ អំពីការការពារជនរងគ្រោះនិងសាក្សីនិងការចូលរួមរបស់ពួកគេ នៅក្នុងដំណើរការជម្រះរឿងក្តី

៣) កាលណាប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះត្រូវប៉ះពាល់ តុលាការត្រូវអនុញ្ញាតឲ្យគេបង្ហាញ និងត្រូវបានពិចារណានូវទស្សនៈ និងកង្វល់របស់គេនៅក្នុងដំណាក់កាលនានានៃដំណើរការជម្រះរឿងក្តីដែលតុលាការបានកំណត់ថាសមស្រប និងនៅក្នុងលក្ខណៈមួយដែលមិនមានលក្ខណៈអគតិ ឬមិនមានលក្ខណៈមិនសមស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះដោយយុត្តិធម៌ និងឥតលម្អៀង ។ ទស្សនៈនិងកង្វល់នោះ អាចត្រូវបង្ហាញដោយអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះពេលដែលតុលាការពិចារណាយល់ឃើញថាសមស្របអនុលោមតាមវិធាននៃនីតិវិធីនិងភស្តុតាង ។

### អំពីការជួសជុលដល់ជនរងគ្រោះ

លក្ខណៈពិសេសមួយទៀតរបស់ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមដែលជាប្រយោជន៍ដល់ជនរងគ្រោះគឺថា ឆន្ទានុសិទ្ធិដំណោះស្រាយកែតម្រូវអនុញ្ញាតឲ្យចៅក្រមរួមបញ្ចូលនូវការជួសជុលដល់ជនរងគ្រោះនៅក្នុងសាលក្រមក្នុងទម្រង់ជាបដិទាន (ការសងវិញ) សំណងជំងឺចិត្ត និងនីតិសម្បទាកម្ម ។ លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមអនុញ្ញាតឲ្យចៅក្រមសម្រេចនូវទំហំនៃការទទួលរងការខូចខាតរបស់ជនរងគ្រោះ និងបញ្ជាឲ្យមានការជួសជុលស៊ីគ្នាទៅនឹងការខូចខាតពីសំណាក់ជនជាប់ចោទ ។

### មាត្រា៧៥ៈ អំពីការជួសជុលដល់ជនរងគ្រោះ

១) តុលាការត្រូវបង្កើតឡើងជាគោលការណ៍ដែលទាក់ទងដល់ការជួសជុលដល់ឬទាក់ទងនឹងជនរងគ្រោះរួមមាន ការសងវិញ សំណងជំងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ ។ ដោយឈរលើមូលដ្ឋាននេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការអាចកំណត់តាមសំណើ ឬតាមការស្នើរបស់ខ្លួននៅក្នុងកាលៈទេសៈពិសេសៗនូវកម្រិតវិសាលភាព និងទំហំនៃការខូចខាត ឬការបាត់បង់ និងគ្រោះថ្នាក់ដល់ឬទាក់ទងនឹងជនរងគ្រោះ ហើយថ្លែងពីគោលការណ៍ទាំងឡាយដែលខ្លួនកំពុងសំអាងលើ ។

២) តុលាការអាចចេញបញ្ជាផ្ទាល់ប្រឆាំងពិរុទ្ធជន ដោយបញ្ជាក់នូវការជួសជុលដែលសមស្របដល់ឬទាក់ទងនឹងជនរងគ្រោះ រួមមានការសងវិញ សំណងជំងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ ។ បើសមស្រប តុលាការអាចបញ្ជាថា ការផ្តល់ឲ្យសម្រាប់ការជួសជុលត្រូវធ្វើឡើងតាមរយៈមូលនិធិក្នុងភារៈគ្រប់គ្រងដូចមានចែងក្នុងមាត្រា៧៩ ។

៣) មុនពេលចេញបញ្ជាណាមួយតាមមាត្រានេះ តុលាការអាចអញ្ជើញ ហើយត្រូវមានការគិតគូរចំពោះការតំណាងពី ឬក្នុងនាមពិរុទ្ធជន ជនរងគ្រោះ ជនដែលមានផលប្រយោជន៍ ឬរដ្ឋដែលមានផលប្រយោជន៍ផ្សេងៗទៀត ។

៤) ក្នុងការអនុវត្តអំណាចរបស់ខ្លួនតាមមាត្រានេះ បន្ទាប់ពីជនណាម្នាក់ត្រូវថ្កោលទោសចំពោះបទល្មើសព្រហ្មទណ្ឌនៅក្នុងយុត្តាធិការរបស់ខ្លួន តុលាការអាចកំណត់ថាតើចាំបាច់ត្រូវរកវិធានការតាមកថាខណ្ឌទី១ នៃមាត្រា៩៣ ដើម្បីដាក់ឲ្យមានប្រសិទ្ធភាពនូវបញ្ជាដែលខ្លួនអាចធ្វើឡើងតាមមាត្រានេះឬអត់ ។

៥) រដ្ឋភាគីត្រូវដាក់ឲ្យមានប្រសិទ្ធភាពនូវសេចក្តីសម្រេចតាមមាត្រានេះ ហាក់ដូចជាបទបញ្ញត្តិនៃមាត្រា១០៩ អាចអនុវត្តបានចំពោះមាត្រានេះបានអ៊ីចឹង ។

៦) គ្មានអ្វីមួយនៅក្នុងមាត្រានេះត្រូវបានយកទៅបកស្រាយឲ្យមានលក្ខណៈអគតិធម៌ចំពោះសិទ្ធិរបស់ជនរងគ្រោះតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិឡើយ ។

### មូលនិធិក្នុងអាណត្តិព្យាបាលភាព

ចំណុចចុងក្រោយគឺថា ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមផ្តល់អាណត្តិឲ្យមានការបង្កើតជាមូលនិធិក្នុងអាណត្តិព្យាបាលភាពសម្រាប់ជន

រងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះនៃបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ៖

**មាត្រា៧៩៖ មូលនិធិក្នុងអាណត្តិព្យាបាលភាព**

១) មូលនិធិក្នុងអាណត្តិព្យាបាលភាពត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយ សម្រាប់ជាប្រយោជន៍នៃជនរងគ្រោះនិងក្រុមគ្រួសាររបស់ជនរងគ្រោះនោះ ដោយសារបទល្មើសព្រហ្មទណ្ឌដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការ ។

២) តុលាការអាចបញ្ជាឲ្យផ្ទេរប្រាក់និងទ្រព្យសម្បត្តិផ្សេងៗដែលប្រមូលបានពីការដាក់ពិន័យ ឬពីការដកហូតទ្រព្យសម្បត្តិ ចូលទៅក្នុងមូលនិធិក្នុងអាណត្តិព្យាបាលភាពតាមដីការបស់តុលាការ ។

៣) មូលនិធិក្នុងអាណត្តិព្យាបាលភាពត្រូវចាត់ចែងស្របតាមលក្ខណៈវិនិច្ឆ័យ ដែលនឹងត្រូវកំណត់ដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយ ។

មូលនិធិក្នុងអាណត្តិព្យាបាលភាពនឹងផ្តល់វិធានការជាការជួយដោះបន្ទុករបស់ជនរងគ្រោះនិងគ្រួសាររបស់ខ្លួន ។ ពិតណាស់ថា តម្លៃជាថវិកាមិនអាចមកលុបលាងការឈឺចាប់ដែលជនរងគ្រោះបានទទួលរងទេ ប៉ុន្តែមានរង្វាន់មួយចំនួនមកពីមូលនិធិក្នុងអាណត្តិព្យាបាលភាពដែលអាចធ្វើឲ្យជនរងគ្រោះត្រឡប់ទៅធាតុដើមរបស់ខ្លួនវិញ ហើយក្នុងករណីខ្លះអាចចេញថវិកាសម្រាប់ព្យាបាលសុខភាពដែលត្រូវការជាចាំបាច់និងជាប្រចាំ ដែលជាផលប៉ះពាល់ពីការរបួស ។ គួរឲ្យកត់សម្គាល់ថា មូលនិធិក្នុងអាណត្តិព្យាបាលភាពអាចរួមបញ្ចូលថវិកាដែលបានមកពីពិរុទ្ធជនក្នុងទម្រង់ជាប្រាក់ពិន័យ និងការបាត់បង់សិទ្ធិដែលបញ្ជាដោយតុលាការ ។

**សេចក្តីសន្និដ្ឋាន**

តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាដំណើរឈានទៅមុខដ៏សំខាន់ឆ្ពោះទៅរកការគាំពារនិងការទទួលស្គាល់សិទ្ធិនិងផលប្រយោជន៍របស់ជនរងគ្រោះនៃបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងលោក ។ លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមប្រឈមមុខដោះស្រាយបញ្ហានានាទាក់ទងដល់តួនាទីរបស់ជនរងគ្រោះដើរតួជាសាក្សី និងបុគ្គលដែលការពារសិទ្ធិរបស់ខ្លួនផ្ទាល់ ។ តាមវិធីនេះ លក្ខន្តិកៈច្បាប់ពង្រឹងនូវតួនាទីរបស់ជនរងគ្រោះនៅក្នុងច្បាប់អន្តរជាតិ ផ្តល់នូវអំណាចនិងភ្នាក់ងារសម្រាប់បុគ្គលដែលកន្លងមក (មិនមានតំណាងពេញមុខពេញមាត់ប្រសិនបើគ្មានអ្នកណាបំភ្លេច) នៅពេលដែលករណីឧក្រិដ្ឋអន្តរជាតិដ៏ធ្ងន់ធ្ងរត្រូវបានយកមកវិនិច្ឆ័យនៅចំពោះមុខតុលាការ ។

**សរសេរដោយ ស្វ ប៊ុនស៊ូ**



**អ្នកដែលរួចផុតពីសេចក្តីស្លាប់ ក្នុងរបបខ្មែរក្រហម**

# គម្រោងការពិសោធន៍សំខាន់ៗដែលអាចផ្តល់ជំនួយដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

គម្រោងការនេះមានដូចខាងក្រោម÷

## ១) មន្ទីរព្យាបាលជំងឺផ្លូវចិត្ត

អ្នកឯកទេសខាងផ្នែកចិត្តសាស្ត្រជឿថា ដំណើរការកាត់ទោសខ្មែរក្រហមនឹងធ្វើឲ្យប្រជាជនមួយចំនួនដែលបានទទួលការឈឺចាប់ក្នុងសម័យខ្មែរក្រហម នឹកឃើញរឿងរ៉ាវចាស់របស់ខ្លួនឡើងវិញ ហើយក្នុងករណីខ្លះទៀត ដំណើរការកាត់ទោសនេះអាចនាំឲ្យមានផលប៉ះទង្គិចខាងអារម្មណ៍កាន់តែខ្លាំងថែមទៀតចំពោះជនរងគ្រោះមួយចំនួន ។ ដូច្នេះអ្នកទាំងនេះច្បាស់ជានឹងត្រូវការជាចំបាច់នូវមន្ទីរបម្រើសេវាកម្មសុខភាពផ្នែកចិត្តសាស្ត្រក្នុងនិងក្រោយពេលដំណើរការកាត់ទោសខ្មែរក្រហមនេះ ។

បច្ចុប្បន្ន ក្នុងប្រទេសកម្ពុជាគ្មានបណ្តាញសេវាកម្មសុខភាពផ្លូវចិត្តទំនើបៗនៅឡើយទេ ។ ហេតុនេះ កិច្ចប្រឹងប្រែងមួយចំនួនគួរតែត្រូវធ្វើឡើងដើម្បីបង្កើនប្រព័ន្ធផ្តល់ការថែរក្សាសុខភាពផ្លូវចិត្តឲ្យបានច្រើនជាអតិបរិមា និងគ្រប់ច្រកល្ហកទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងពេលដំណើរការនៃតុលាការកាត់ទោសខ្មែរក្រហមដែលរួមមានតាំងពីសេវាបម្រើតាមបែបបុរាណ (មានគ្រូព្រះសង្ឃ) រហូតដល់ការធ្វើអន្តរាគមន៍ផ្នែកចិត្តសាស្ត្រនិងផ្នែកវិកលចរិតបែបទំនើបការពិភាក្សា (ការព្យាបាលរោគជាដើម) ។

## ២) សេវាកម្មផ្នែកច្បាប់សម្រាប់ជនរងគ្រោះនិងជនដៃដល់

ច្បាប់តុលាការកាត់ទោសខ្មែរក្រហមចែងថា ជនជាប់ចោទមានសិទ្ធិជួលមេធាវីដើម្បីការពាររឿងក្តីរបស់ខ្លួនតាមជម្រើសរបស់ខ្លួន ។ ប៉ុន្តែច្បាប់នេះក៏បានហាមប្រាមដែរថា ក្រុមការពារក្តីមិនអាចដឹកនាំដោយមេធាវីដែលមានសញ្ជាតិបរទេសឡើយ ។ អង្គការសហប្រជាជាតិបានបំភ្លឺរួចមកហើយថា ការធ្វើបែបនេះជាការរំលោភដល់កាតព្វកិច្ចរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀងអន្តរជាតិលើសិទ្ធិផ្នែកសង្គមកិច្ចនិងនយោបាយ ។ លើសពីនេះ ជនជាប់ចោទមួយចំនួនអាចពុំមានលទ្ធភាពជួលមេធាវីមានបទពិសោធន៍ខ្ពស់មកធ្វើជាជំនួយដល់ក្រុមការពារក្តីរបស់ខ្លួនបានទេជាពិសេស មេធាវីដែលធ្លាប់ដោះស្រាយរឿងក្តីស្មុគស្មាញក្នុងករណីអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បើតុលាការកាត់ទោសខ្មែរក្រហមពិតជានឹងត្រូវបង្កើតឡើងដើម្បីផ្តល់នូវភាពយុត្តិធម៌ ហើយសមស្របទៅតាមបទដ្ឋានអន្តរជាតិមែននោះ មធ្យោបាយមួយចំនួនគួរតែត្រូវយកមកប្រើប្រាស់ដើម្បីផ្តល់ឲ្យជនជាប់ចោទទាំងនោះនូវមេធាវីល្អៗសម្រាប់ការពារក្តីរបស់ខ្លួន ។

ច្បាប់នេះពុំបានចែងអំពីការណែនាំផ្នែកច្បាប់សម្រាប់សាក្សីទាំងឡាយដែលអាចនឹងត្រូវកោះហៅឲ្យឡើងតុលាការទេ ឬសម្រាប់ជនរងគ្រោះណាដែលមានបំណងផ្តល់ជាសំណូមពរដល់តុលាការ ឬក៏ចង់ចូលរួមក្នុងដំណើរការកាត់ទោសនេះទេ ។ គួរតែផ្តល់សេវាកម្មផ្នែកច្បាប់ដោយឥតគិតថ្លៃ និងត្រូវធ្វើឲ្យសាធារណជនទូទៅជ្រាបអំពីសេវាកម្មនេះដើម្បីឲ្យពលរដ្ឋទាំងអស់ដែលជាប់ទាក់ទិន ឬមានបំណងចង់ចូលរួមក្នុងដំណើរការកាត់ទោសនេះ អាចមានសិទ្ធិទទួលនូវការផ្តល់យោបល់ផ្នែកច្បាប់ដ៏ត្រឹមត្រូវដែលទាក់ទងទៅនឹងតុលាការនេះ ។

## ៣) កម្មវិធីការពារសុវត្ថិភាពសាក្សី

ចំពោះសាក្សីទាំងឡាយណាដែលត្រូវចូលរួមក្នុងតុលាការនេះ ឬចំពោះអ្នកដែលស្ម័គ្រចិត្តធ្វើជាសាក្សីដល់តុលាការកាត់ទោសខ្មែរក្រហមនេះ អាចនឹងទទួលការគំរាមកំហែងឬត្រូវបំភិតបំភ័យពីសំណាក់ភាគីដែលមានការចាប់អារម្មណ៍ទៅលើលទ្ធផលនៃការវិនិច្ឆ័យទោស ។ ច្បាប់តុលាការនេះបានបញ្ជាក់ដែរថា នីតិវិធីទាំងឡាយសម្រាប់អង្គជំនុំជម្រះក្តីវិសាមញ្ញនឹងត្រូវផ្អែកលើនីតិវិធីតុលាការកម្ពុជាដែលមានស្រាប់ ក៏ប៉ុន្តែបច្ចុប្បន្ននេះ គ្មាន

មធ្យោបាយមានប្រសិទ្ធភាពណាមួយដើម្បីការពារសាក្សីទាំងឡាយ មិនឲ្យមានការគំរាមកំហែងទៅលើសុខមាលភាពរបស់ខ្លួនទេ ។

ក្រុមពិសេសមួយគួរត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការគាំទ្រដល់ការរៀបចំការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងការអនុវត្តនូវនីតិវិធីទាំងនេះជាលក្ខណៈផ្លូវការមួយ ។ បើមិនមានការគាំទ្របែបនេះទេ ក្រុមនេះគួរតែរៀបចំខ្លួនជាស្រេចដើម្បីផ្តល់នូវកិច្ចការពារសាក្សី ហើយសំខាន់បំផុតនោះ គឺជួយផ្លាស់ប្តូរទីកន្លែងដល់សាក្សីទាំងនោះដូចដែលបានបញ្ជាក់នៅក្នុងដែនសមត្ថកិច្ចអន្តរជាតិរួចមកហើយ ដូចជានៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉ាន់ដា ។

## ៤) វេទិកាសាធារណៈជាតិ

វេទិកាទាំងឡាយដែលស្រដៀងគ្នាទៅនឹងកិច្ចប្រជុំសហគមន៍ដែលបានរៀបចំធ្វើឡើងកាលពីឆ្នាំមុនដោយមជ្ឈមណ្ឌលអភិវឌ្ឍសង្គម គួរតែត្រូវបានបង្កើតឡើងជាលក្ខណៈជាតិ ហើយបើអាចធ្វើទៅរួច គួរតែត្រូវបានផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍ ។ គោលបំណងនៃវេទិកាទាំងនេះគឺត្រូវផ្សព្វផ្សាយព័ត៌មានត្រឹមត្រូវច្បាស់លាស់អំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងតុលាការ ហើយត្រូវអនុញ្ញាតឲ្យប្រជាពលរដ្ឋទាំងឡាយបញ្ជាក់នូវទស្សនៈរបស់ខ្លួនទាក់ទិនទៅនឹងដំណើរការនៃការកាត់ទោសតាមប៉ុស្តិ៍វិទ្យុ ឬទូរទស្សន៍មួយ ដែលអាចធ្វើឲ្យមេដឹកនាំជាតិទាំងឡាយជ្រាបជាព័ត៌មាននូវការយល់ឃើញរបស់ប្រជាជាតិទាំងមូលជុំវិញតុលាការកាត់ទោសខ្មែរក្រហម ។

ការធ្វើដូច្នេះអាចជួយបង្កើនជាអតិបរមានូវឥទ្ធិពលនៃតុលាការទៅលើការផ្សះផ្សាជាតិ និងការពារកុំឲ្យជនអាត្មានិយមទាំងឡាយគ្របដណ្តប់លើការផ្សព្វផ្សាយពាក្យចចាមអារ៉ាមមិនពិតអំពីដំណើរការកាត់ទោសនេះ ដែលជាមូលហេតុមួយធំបំផុតដែលធ្វើឲ្យសាធារណជនទទួលព័ត៌មានមិនត្រឹមត្រូវ ។

## ៥) សង្កេតការណ៍នៅសាលតុលាការ

ដើម្បីឲ្យសាធារណជនបានដឹងឮអំពីអ្វីដែលកំពុងតែកើតមានឡើងនៅតុលាការ អ្នកសង្កេតការណ៍អាជីពមួយចំនួនគួរតែត្រូវជ្រើសរើសឲ្យមកត្រួតពិនិត្យដំណើរការកាត់ទោសនេះប្រចាំថ្ងៃ ហើយផ្សព្វផ្សាយព័ត៌មានទាំងនេះទៅកាន់សាធារណជន ។ គម្រោងការនេះអាចអនុវត្តឡើងស្របពេលជាមួយវេទិកាសាធារណៈនេះក៏បាន ឬត្រូវបង្កើតឡើងដោយឡែកតែឯងដោយត្រូវចែកចាយព័ត៌មានតាមរយៈប្រព័ន្ធអេឡិចត្រូនិកនិងអត្ថបទបោះពុម្ពផ្សាយក៏បាន ។ ជាការសំខាន់ណាស់ដើម្បីឲ្យមានការផ្សះផ្សាជាតិ អ្នកផ្សាយព័ត៌មានត្រូវចៀសវាងមនុស្សដែលមកពីមជ្ឈដ្ឋានរដ្ឋាភិបាល និងមកពីតុលាការកាត់ទោសនេះផ្ទាល់ ។

## ៦) កោសល្យវិច័យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងកត់ត្រាទុកតាមបែបវិទ្យាសាស្ត្រទំនើប នូវរណ្តៅសាកសពធំៗរាប់ពាន់ក្នុងទីតាំងវាលពិឃាតផ្សេងៗនៅទូទាំងប្រទេសកម្ពុជា ។ ភ័ស្តុតាងជាច្រើនបានបញ្ជាក់ឲ្យដឹងថា រណ្តៅស្ទើរតែទាំងអស់សុទ្ធតែជាស្នាដៃរបស់ពួកសន្តិបាលការិយាធិបតេយ្យក្នុងសម័យខ្មែរក្រហម ។ ទោះបីជាយ៉ាងនេះក៏ដោយ យើងអាចទាយទុកជាមុនថា ការបកស្រាយការពារខ្លួនមួយរបស់ជនជាប់ចោទក្នុងតុលាការលើចំណុចនេះគឺច្បាស់ជាថា សាកសពទាំងឡាយដែលនៅក្នុងរណ្តៅទាំងនោះត្រូវបានសម្លាប់ដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកក្នុងសង្គ្រាមវៀតណាម ឬជាទង្វើរបស់“ពួកក្បត់មួយចំនួន” មិនខាន ។ ដើម្បីបង្ហាញឲ្យឃើញថាការទឡ្ហីករណ៍នេះប្រាសចាកពីការពិត យើងគួរតែធ្វើកោសល្យវិច័យទៅលើគំរូមួយចំនួនដែលយកចេញពីក្នុងរណ្តៅទាំងនោះ ។

ភ័ស្តុតាងដែលបានពីការវិភាគនេះនៅពេលដែលរួមគ្នាជាមួយការបកស្រាយរបស់សាក្សីនិងភ័ស្តុតាងជាឯកសារផ្សេងទៀតដែលមានហើយស្រេចនោះ នឹងបង្កជាលក្ខណៈចាំបាច់និងគ្រប់គ្រាន់ដើម្បីបង្ហាញថា រណ្តៅទាំងនោះសុទ្ធតែជាបទឧក្រិដ្ឋរបស់សម័យខ្មែរក្រហម ។ ក្នុងរឿងក្តីនៅប្រទេសផ្សេងទៀត ដូចជានៅប្រទេស ហ្កាតេម៉ាឡា ប៊ូស្នៀ និង អ៊ុយក្រែន ការងារកោសល្យ-វិច័យត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ហើយលទ្ធផលដែលទទួលបានអាចយកទៅប្រើប្រាស់ក្នុងតុលាការបាន ។

### គម្រោងសំខាន់ៗដទៃទៀតមាន÷

#### ១) ការជួយគាំទ្រពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន

ត្រូវផ្តល់ដល់អ្នកយកព័ត៌មានអន្តរជាតិ ដែលនឹងត្រូវមក

កាន់ប្រទេសកម្ពុជាក្នុងចំនួនច្រើនសន្ធឹកសន្ធាប់ នូវសេវាកម្មផ្នែកព័ត៌មាននិងសេវាកម្មចាំបាច់ផ្សេងៗ ទៀត ។

**២) វិទ្យុទូរទស្សន៍ជាតិ និង វិទ្យុទូរទស្សន៍នៅតាមខេត្ត**

ត្រូវរៀបចំកម្មវិធីវិទ្យុទូរទស្សន៍ដោយផ្តោតលើដំណើរការតុលាការកាត់ទោសខ្មែរក្រហម ដែលកំពុងតែប្រព្រឹត្តទៅសម្រាប់អ្នកស្តាប់ទូទាំងប្រទេស ។

**៣) មជ្ឈមណ្ឌលសារព័ត៌មាន**

បង្កើតនូវមជ្ឈមណ្ឌលសារព័ត៌មាន ដែលផ្តល់ព័ត៌មានតាមរយៈអ៊ីនធឺណែតនិងតាមទូរស័ព្ទ ដើម្បីឲ្យប្រជាជនទូទៅអាចទទួលយកនូវព័ត៌មានច្បាស់ការណ៍អំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងតុលាការកាត់ទោសខ្មែរក្រហម ហើយធ្វើឲ្យប្រជាជនយល់បានថា តើតុលាការនេះអាចជះឥទ្ធិពលដល់ខ្លួនគាត់ផ្ទាល់និងដល់សហគមន៍ដែលគាត់រស់នៅយ៉ាងដូចម្តេចខ្លះ?

**៤) ការបោះពុម្ពផ្សាយឯកសារផ្នែកច្បាប់**

បង្កើតឡើងនូវការបោះពុម្ពផ្សាយរបាយការណ៍សារព័ត៌មានខិត្តប័ណ្ណនិងសៀវភៅផ្សេងៗ ដើម្បីជម្រាបជាព័ត៌មានដល់សាធារណជននូវសកម្មភាពទាំងឡាយក្នុងតុលាការ ។

**៥) ការសម្រួលដល់ការធ្វើញត្តិនិងពាក្យបណ្តឹង**

បុគ្គលនិងសហគមន៍ផ្សេងៗ អាចមានបំណងចង់ធ្វើញត្តិទាក់ទិនទៅនឹងការកាត់ទោស នៅឯតុលាការឬប្តឹងតវ៉ាជាផ្លូវការមកលើចុងចោទណាមួយតែពួកគេពុំដឹងថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីធ្វើដូច្នោះបាន ។ គម្រោងនេះអាចធ្វើឡើងដោយឡែកឬដោយស្របទៅនិងសេវាកម្មផ្នែកច្បាប់សម្រាប់ជនរងគ្រោះនិងជនដៃដល់ ។

**៦) ការហ្វឹកហ្វឺនផ្នែកច្បាប់ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលបានចែងក្នុង (ច្បាប់ខ្មែរក្រហម)**

មេធាវីកម្ពុជាមួយចំនួនតូចប៉ុណ្ណោះ (ដោយមិនគិតពីប្រជាជនកម្ពុជាទូទៅ) ដែលមានចំណេះដឹងពិស្តារអំពីប្រភេទផ្សេងៗ នៃច្បាប់ដែលនឹងត្រូវប្រើប្រាស់ក្នុងការចោទប្រកាន់ជនសង្ស័យនៅក្នុងតុលាការ ។ ដូច្នេះវាមានសារសំខាន់ណាស់ បើកម្មវិធីហ្វឹកហ្វឺនបែបនេះអាចអនុវត្តបានចាប់ពីឥឡូវនេះទៅ ។

**៧) ប្រធានបទនៃការចុះទៅសិក្សាស្រាវជ្រាវៈ កងទ័ពវ័យក្មេង ជនជាតិភាគតិច និងការរំលោភបំពានផ្លូវភេទ**

មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងសិក្សាស្រាវជ្រាវលើប្រធានបទផ្សេងៗ ដែលទាក់ទងទៅនិងសម័យខ្មែរក្រហម ។ ប៉ុន្តែយើងឃើញថា នៅពេលដែលតុលាការកាត់ទោសខ្មែរក្រហមកាន់តែឈានចូលមកដល់ ព័ត៌មានដ៏សន្ធឹកសន្ធាប់ថ្មីៗ ទៀតបានផ្លាយចេញមក ព្រោះប្រជាជនជាច្រើននាំគ្នារំឭកនូវអ្វីដែលខ្លួនបានចងចាំនិងបានកើតឡើងពីអតីតកាល ។ ព័ត៌មានទាំងនេះគួរតែត្រូវបានប្រមូលហើយចងក្រងទុកដើម្បីយកមកវិភាគសម្រាប់កូនចៅខ្មែរជំនាន់ក្រោយ ។

**៨) ផ្តល់ព័ត៌មានដល់ផ្ទះដែលផ្តល់នូវព្រឹត្តិការណ៍សំខាន់ៗទាក់ទងទៅនិងប្រវត្តិសាស្ត្រ**

ប្រជាជនកម្ពុជាភាគច្រើនភ័យខ្លាចខ្លាំងពេក នាំឲ្យប៉ះពាល់ដល់ផ្នែកនយោបាយរបស់តុលាការកាត់ទោសខ្មែរក្រហមឬមិនមានលទ្ធភាពទាញយកប្រយោជន៍ពីសេវាផ្តល់ព័ត៌មាននិងការគាំទ្រដែលអាចនឹងបង្កើតឡើង ។ កម្មវិធីផ្តល់ព័ត៌មានដល់ផ្ទះគួរតែត្រូវបានបង្កើតឡើង ។

**៩) គម្រោងជំនួយផ្នែកស៊ើបអង្កេត**

ក្រុមអ្នកស៊ើបអង្កេតរបស់តុលាការ ពិសេសអ្នកមកពីបរទេសអាចមានបំណងចង់ទាក់ទងជាមួយប្រជាជនឬទៅកាន់ទីតាំងនៅតាមខេត្តនានា ដោយមិនចាំបាច់ពឹងផ្អែកទាំងស្រុងទៅលើឯកសាររបស់រដ្ឋាភិបាល ។ សេវាកម្មផ្សេងៗ ដើម្បីជាជំនួយដល់មធ្យោបាយធ្វើដំណើរនៅតាមខេត្តនិងការជួយស្វែងរកទីតាំងនិងអ្នកភូមិគួរត្រូវផ្តល់ជូនដល់ក្រុមអ្នកស៊ើបអង្កេតទាំងនេះ ។

**ឆាំង យុ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **ធាតុឈានមុខៈ** គឺឈានមុខខាងជំហរខាងស្មារតីខាងសកម្មភាព និងប្រយុទ្ធមិនរួញរា ។ (កំណត់ហេតុលេខ១៨១)

◆ **អរិយធម៌ៈ** គឺជាទំនៀមទម្លាប់ប្រពៃណីសង្គម ស្ថាបត្យកម្មផ្សេងៗ ដែលមាននៅក្នុងសង្គម សិល្បៈ អក្សរ ។ល ។

(កំណត់ហេតុ អុីវ)

# សេចក្តីកែតម្រូវរបស់ព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា




នៅក្នុងកាសែត *The Cambodia Daily* ចេញផ្សាយថ្ងៃអង្គារ ទី៣ ខែធ្នូ ឆ្នាំ២០០២ គេអាចអានឃ្លាជាពិសេសដូចតទៅនេះ÷ «...» អតីតមេដឹកនាំខ្មែរក្រហមទីពីរ នួន ជា និយាយថា នៅក្នុងរបបឆ្វេងនិយមជ្រុល យ៉ាងហោចណាស់ កម្មាភិបាលថ្នាក់លើបានព្យាយាមឲ្យប្រជាជនគ្រប់រូបមានបាយហូបគ្រប់គ្រាន់ ។ «របបមុនមិនល្អទេ ហើយមានប្រជាជនក្រីក្រច្រើន ។ យើងបានព្យាយាមធ្វើឲ្យគ្រប់ៗគ្នាមានសិទ្ធិស្មើគ្នា ហើយឲ្យមានបាយហូបគ្រប់ៗគ្នា (នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ។ នួន ជា និយាយដូចនេះនៅថ្ងៃសៅរ៍ នៅឯលំនៅដ្ឋានរបស់ខ្លួន នៅទីក្រុងប៉ៃលិន» ។

◆◆◆

«របបមុនមិនល្អទេ ហើយមានប្រជាជនក្រីក្រច្រើន» ។

ប្រសិនបើ នួន ជា «និយាយសំដៅសង្គមរាស្រ្តនិយម» ដែលបញ្ជាក់ឲ្យឃើញថា «របបអតីតកាលពុំល្អនិងមានប្រជាជនក្រីក្រច្រើន» ខ្ញុំក៏មានកាតព្វកិច្ច (ដោយមិនចំពោះ) ក្នុងការដាក់ជូនពិនិត្យនិងធ្វើការវិនិច្ឆ័យដូចខាងក្រោម នូវសក្ខីភាពមួយផ្នែកក្នុងចំណោមសក្ខីភាពយ៉ាងច្រើនរបស់បុគ្គលទាំងឡាយដែលស្រលាញ់យុត្តិធម៌ ដែលបានសរសេរនិងចុះផ្សាយដោយឯកឯងក្នុងកាសែតរៀងៗខ្លួនរបស់គេ របស់អ្នកកាសែតល្បីៗនៃពិភពលោកសេរីដែលឯករាជ្យបំផុត និងដែលស្រលាញ់ការពិតយុត្តិធម៌ភាពមិនលម្អៀង÷

◆ កាសែត *"LES ECHOS"* ចេញផ្សាយថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៦៥ ។ នេះជាសេចក្តីដកស្រង់÷ «...ឧស្សាហូបនីយកម្មនៅប្រទេសកម្ពុជាបាន "បានកំណត់ជាប់នូវគោលដៅផ្សេងៗប្រកបដោយលក្ខណៈសមហេតុផលនិងមិនខ្វល់ពីបញ្ហាលទ្ធិឡើយ ប៉ុន្តែដោយយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការផ្សេងៗខាងក្នុងប្រទេសនិងលទ្ធភាពក្នុងការនាំចេញ» ។ កាសែតប្រចាំថ្ងៃដ៏ល្បីរបស់បារាំងបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ឧស្សាហកម្មឯកជន (ជិត៣០០០សហគ្រាសតូចៗដែលធ្វើឲ្យមានការងារថ្មីចំនួន២៦០០០កន្លែង ។ ខ្ញុំសង្កត់បញ្ជាក់ ន.សីហនុ) ហើយបង្ហាញឲ្យឃើញនូវ «អត្ថប្រយោជន៍និងការលើកទឹកចិត្តយ៉ាងច្រើនដល់ការធ្វើវិនិយោគរបស់បណ្តាអ្នកមូលធនជាតិបរទេស» ។ *LES ECHOS* បានសន្និដ្ឋានថា «ដោយសារការលាយបញ្ចូលគ្នាដ៏ប៉ិនប្រសប់នូវអ្វីដែលខ្លួនអាចរកឃើញ ដើម្បីឲ្យមានលំនាំត្រូវសមទៅនឹងសេចក្តីត្រូវការផ្សេងៗរបស់ខ្លួនក្នុងលទ្ធិសង្គមនិយមនិងលទ្ធិសេរីនិយមនេះ កម្ពុជាអាចសម្រេចគោលដៅបំពាក់នូវមូលដ្ឋានសេដ្ឋកិច្ចដ៏រឹងមាំមួយ ដែលលើមូលដ្ឋាននេះកម្ពុជាអាចបង្កើតនយោបាយដ៏ស័ក្តិសិទ្ធមួយក្នុងការអភិវឌ្ឍន៍ប្រទេស (ខ្ញុំសង្កត់បញ្ជាក់ ន. សីហនុ) ។ ការលាយបញ្ចូលគ្នានូវភាពប្រុងប្រយ័ត្ននិងភាពមោះមុតនេះ បានបង្ហាញឲ្យឃើញនូវរបៀបជាវិជ្ជមានដែលប្រទេសកម្ពុជាបានឆ្លើយតបទៅនឹងការលុបចោលជំនួយអាមេរិកកាំងនៅឆ្នាំ១៩៦៤ (ការកត់សម្គាល់របស់ខ្ញុំ÷ តាំងពីឆ្នាំ១៩៦៣ គឺពុំមែនឆ្នាំ១៩៦៤ទេ ប្រទេស

កម្ពុជាសម័យសង្គមរាស្ត្រនិយមបានផ្តើមគំនិតបដិសេធមិនទទួលជំនួយអាមេរិកាំងជាស្ថាពរ) ។ ទឹកប្រាក់ចំនួនប្រហែល២០លានដុល្លារ ដែលសហរដ្ឋអាមេរិកផ្តល់ឲ្យជារៀងរាល់ឆ្នាំ (កំណត់សម្គាល់របស់ន.សីហនុៈ ៣០លានដុល្លារ) តាំងពីឆ្នាំ១៩៥៣ មានតម្លៃស្មើនឹង៦ភាគរយនៃថវិកាជាតិត្រូវបានជំនួសភ្លាមៗដោយប្រភពធនធានផ្សេងៗទៀត (ខ្ញុំសង្កត់បញ្ជាក់ៈ ន.សីហនុ) ។ ជាពិសេសគឺដោយសារការខិតខំប្រឹងប្រែងការធ្វើការងារ និងការប្រកាន់វិន័យផ្ទាល់របស់ខ្លួន (ខ្ញុំសង្កត់បញ្ជាក់ៈ ន.សីហនុ) ដែលប្រជារាស្ត្រខ្មែរបានធ្វើឲ្យសម្រេចពិតប្រាកដនូវឆន្ទៈងើបមុខឡើងវិញរបស់ខ្លួននិងបានផ្តល់គំរូមួយដល់បណ្តារដ្ឋថ្មីទាំងអស់ដែលទើបចេញផុតពីការធ្វើអាណានិគមរបស់បរទេស» ។

◆ លោក ហ្វែរណង់ ប៉ារ៉ែល (M. FERNAND PARREL) ក្នុងកាសែត «LA CROIX» ឆ្នាំ១៩៦៦ ។ សេចក្តីដកស្រង់ៈ «ខ្ញុំបានមកដល់ទីក្រុងភ្នំពេញជាថ្មី ជាទីក្រុងមួយដែលត្រូវធ្វើឲ្យផ្លាស់ប្តូរសភាពទ្រង់ទ្រាយទាំងស្រុង ។ (...) ជាប្រទេសដ៏កម្រមាននៅអាស៊ី គ្មានអ្នកសុំទានក្នុងប្រជាជាតិមួយប្រកបដោយសុភមង្គល ។ (ខ្ញុំសង្កត់បញ្ជាក់ៈ ន.សីហនុ) ដោយធ្វើដំណើរត្រាច់ចរខ្វាត់ខ្វែងក្នុងទីក្រុង ខ្ញុំត្រូវបានធ្វើឲ្យភ្ញាក់ផ្អើលនឹងភាពរីកលូតលាស់មួយដែលសម្រេចបាន ។ ផ្លូវថ្នល់ធំៗប្រកបដោយភាពស្អាតឥតហ្មងនៅអាស៊ី (វាជារឿងដែលត្រូវតែកត់សម្គាល់) ។ ផែនការនគរូបនីយកម្ម(របៀបរៀបចំទីក្រុង)ដ៏ពិតប្រាកដមួយ មាននាទីពិសេសខាងការធ្វើឲ្យរាជធានីរបស់ខ្មែរមានការប្រែប្រួល ដែលអំណឹះតទៅត្រូវបានចារឹកនៅក្នុងបញ្ជីឈ្មោះបណ្តាទីក្រុងដែលស្អាតប្រឡឹង និងដែលជាទីគាប់ចិត្តជាងគេនៅអាស៊ីចុងបូព៌ា ។ ខ្ញុំកោតស្ញប់ស្ញែងបំផុត នៅពេលដែលឆ្លងស្ពានដ៏ល្អស្កឹមស្កៃពីរមានសភាពថ្មីសន្លាង និងប្រកបដោយបច្ចេកទេសខុសគ្នា ប៉ុន្តែទទួលស្វាគមន៍ភ្ញៀវដែលមកដល់ដូចគ្នា ។ (ការកត់សម្គាល់របស់ខ្ញុំៈ នោះគឺស្ពានសង្គមរាស្ត្រនិយមឆ្លងកាត់ទន្លេសាប និងស្ពានព្រះមុនីវង្ស ឆ្លងកាត់ទន្លេបាសាក់ដែលតម្លៃនៃការកសាងត្រូវបានបង់ថ្លៃទាំងស្រុងដោយរដ្ឋាភិបាលសង្គមរាស្ត្រនិយមផ្ទាល់ឲ្យសហគ្រាសឯកជនមួយរបស់ជប៉ុននិងរបស់បារាំង) ។ ម្យ៉ាងទៀតស្តាតអូឡាំពិកជាមួយអ្នកកីឡាទាំងអស់របស់ខ្លួនដែលទទួលបានលទ្ធផលយ៉ាងល្អ ។ (...) នៅខាងក្នុងផ្ទៃប្រទេសពុំមានអ្វីអាចបំភ្លេចបានឡើយ (ខ្ញុំគូសបញ្ជាក់ៈ ន.សីហនុ)» ។

◆ លោក JERROLD SCHECTER ក្នុងសៀវភៅរបស់លោកក្រោមចំណងជើងថា «THE NEW FACE OF BUDDHA» ចេញផ្សាយឆ្នាំ១៩៦៧ ។ សេចក្តីដកស្រង់ៈ «ចំពោះប្រជាកសិករនៅតាមជនបទ សម្តេច សីហនុ គឺជាស្តេចដែលមានទឹកព្រះទ័យមេត្តាផ្តល់ជាក្រណាត់ សាងសង់ទំនប់ ។ សម្តេចមានព្រះទ័យអើពើចំពោះសេចក្តីត្រូវការផ្សេងៗរបស់ប្រជាកសិករ» ។

◆ លោក GUY LAGORCE ក្នុងកាសែត «L'EQUIPE» លេខចេញផ្សាយថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៧ ។ សេចក្តីដកស្រង់ៈ «ពហុកីឡដ្ឋានអូឡាំពិកនៅទីក្រុងភ្នំពេញ គឺជាកិត្តិនាមដ៏រុងរឿងមួយ ។ ខ្ញុំគិតថា ក្នុងពិភពលោកនេះគ្មានទីក្រុងណាមួយផ្សេងទៀត អាចអួតខ្លួនមានពហុកីឡដ្ឋានដ៏ល្អឆើតឆាយដូចនេះទេ ។ រដ្ឋធានីជាច្រើនរបស់អឺរ៉ុប ហើយមុនគេបង្អស់គឺ ទីក្រុងប៉ារីសនឹងសប្បាយរីករាយដែលមានកីឡាដ្ឋានមួយដូចគ្នានេះ ។ កន្លែងហាត់កីឡាកាយសម្ព័ន្ធដ៏ធំល្វឹងល្វើយនិងទំនើបបំផុត អាងហែលទឹកជាច្រើនកន្លែង កន្លែងលេងកីឡាគ្រប់ប្រភេទទាំងអស់ នេះជាសោភណភាពដ៏កម្រមានមួយ ។ (...) ។ ខ្ញុំមានឱកាសធ្វើដំណើរចម្ងាយ៣០០គីឡូម៉ែត្រ ដោយឆ្លងកាត់តាមជនបទនានារបស់កម្ពុជា ។ ក្នុងភូមិទាំងអស់សុទ្ធតែមានតារាងបាល់ទាត់ តារាងបាល់ទះ ហើយដែលនៅលើតារាងទាំងនោះពោរពេញទៅដោយមនុស្សយ៉ាងច្រើន ។ នៅទីក្រុងភ្នំពេញ គេបានបញ្ចប់ការសាងសង់សាកលវិទ្យាល័យថ្មីមួយដែលល្អឥតខ្ចោះ ហើយដែលគេឃើញមានកន្លែងហាត់កាយសម្ព័ន្ធ ទីលានអត្តពលកម្ម និងអាងហែលទឹកខ្នាតអូឡាំពិកនៅក្នុងនោះផង» ។

◆ លោក BERNARD COURET ក្នុងទស្សនាវដ្តី «LE CRI DU MONDE» ចេញផ្សាយឆ្នាំ១៩៦៨ ។ សេចក្តីដកស្រង់ៈ «ទោះបីជាមានការគាបសង្កត់ពីប្រទេសធំៗក៏ដោយ ក៏សម្តេច សីហនុ នៅតែមិនព្រមរាថយ ។ (...) ដោយមានស្ថិរភាពនយោបាយប្រទេសកម្ពុជាត្រូវដឹងគុណសង្គមរាស្ត្រនិយម ការប្រមូលផ្តុំរបស់ប្រជាជាតិ អំពីគំនិតសហគមន៍ សង្គមនិយម និងប្រជាមានិត (...) ។ ប្រទេសកម្ពុជាសម័យទំនើប បានបេះលាយផ្សំយ៉ាងស៊ីសង្វាក់នូវ

របនាសម្ព័ន្ធនៃលទ្ធិប្រជាធិបតេយ្យ ដែលទទួលដំណែលពីចំណែកមរតកនៃជនជាតិក្រិចអំពីប្រពៃណីសហគមន៍ដែលទោរទន់ទៅរករាជាធិបតេយ្យ តាមលក្ខណៈពិសេសដោយឡែករបស់ខ្មែរ ។ (...)គ្មាននរណាមួយអាចប្រកែកថា សម្ដេចព្រះ នរោត្តម សីហនុ ជាដំបូងនិងមុនអ្វីៗទាំងអស់ គឺជាអ្នកស្នេហាមាតុភូមិដ៏មានភក្ដីមួយអង្គចំពោះប្រទេសកម្ពុជានិងប្រជារាស្ត្រខ្មែរ ។ ព្រះអង្គមានរបៀបវិនិច្ឆ័យដ៏ជ្រាលជ្រៅមួយអំពីភាពថ្លៃថ្នូរ និងអភិមានះជាតិ ។ នៅពេលទាក់ទងនឹងប្រជារាស្ត្រ ព្រះអង្គមានខន្តីមួយស៊ើរតែដូចទេវតា ព្រះរាជចរិតល្អមួយ និងការបន្ទោនព្រះកាយចំពោះរាស្ត្រតូចតាចនិងអ្នកក្រខ្សត់ ។ (...) ការសន្ទនាគ្នាដែលមិនផ្លាស់ប្ដូររវាងប្រជារាស្ត្រនិងស្ដេចក្នុងក្របខ័ណ្ឌនៃសង្គមរាស្ត្រនិយមបានធ្វើឲ្យរលាយបាត់នូវការរិភាគផ្សេងៗរបស់ពួកអ្នកសង្កេតការណ៍ស៊ើរភ្លើង ដែលរហន់ចោទរបបរបស់ព្រះអង្គថាជារបបកាន់អំណាចផ្ដាច់ការ ដោយមិននិយាយពីបណ្ដាគូប្រឆាំងដែលចេញមុខផងទេ ។ គេគ្រាន់តែពិនិត្យដោយយកចិត្តទុកដាក់នូវការប្រព្រឹត្តិទៅនៃការប្រជុំសមាជជាតិដែលរួមប្រជុំរៀងរាល់៦ខែម្ដង ដោយមិននិយាយពីសវនាការប្រជារាស្ត្រ ដើម្បីញាំងឲ្យជឿថាពុំមានស្លាកស្នាមណាមួយនៃលទ្ធិផ្ដាច់ការក្នុងរបបសម្ដេច សីហនុ ឡើយ ។ (...) ព្រះអង្គពុំដែលកាត់ផ្ដាច់ការសន្ទនាជាមួយប្រជារាស្ត្រទាល់តែសោះ ។ ទម្រង់នៃលទ្ធិប្រជាធិបតេយ្យដែលមាននាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា(...) គឺជាទម្រង់តែមួយគត់ដែលអាចស្ថិតស្ថេរបាន ។ សកម្មភាពរបស់ព្រះប្រមុខរដ្ឋ មានច្រើនស្អេកស្កះ ។ ក្នុងមួយសប្ដាហ៍ បើព្រះអង្គពុំដឹកនាំការប្រជុំការងារមួយទេ ក៏ព្រះអង្គយាងទៅសម្ពោធសមិទ្ធិថ្មីមួយដែរ ។ នៅទីនេះ សម្ដេចកំពុងតែបើករដូវភ្ជួររាស់ នៅទីនោះសម្ដេចកំពុងថ្លែងសុន្ទរកថាទៅកាន់យុវជននៅគ្រប់ទីកន្លែង សម្ដេចបានថ្លែងព្រះរាជសុន្ទរកថា ពន្យល់អំពីនយោបាយរបស់ព្រះអង្គ ជំរុញកសិករទាំងឡាយឲ្យបំពេញការងារ ជំរុញមន្ត្រីរាជការឲ្យមានសេចក្ដីទៀងត្រង់ ជំរុញកងទ័ពឲ្យមានការប្រុងប្រយ័ត្ន ។ ដោយមិនបេះនឿយព្រះកាយពល សម្ដេចបានយាងត្រាច់ចរខ្វាត់ខ្វែងពាសពេញប្រទេស ដើម្បីសណ្ដាប់ការប្ដឹងតវ៉ាដែលលើកឡើងដោយពលរដ្ឋនៅតាមតំបន់ដាច់ស្រយាលនានា និងដើម្បីថ្លែងពីព្រះរាជបំណងផ្ទាល់របស់ព្រះអង្គនៅកាន់ប្រជាពលរដ្ឋវិញ ។ (...) នៅពេលមានទឹកជំនន់ នៅពេលមានខបទ្ទុវហេតុព្រំដែនមួយកើតឡើង (...)សម្ដេចបានយាងតាមខទ្ទម្ភាគចក្រទៅដល់(...)មូរដៃព្រះភូសា(ដៃអាវ) ហើយចាប់ផ្ដើមធ្វើការ ។ ជាមួយពួកអ្នកជនបទ ព្រះអង្គបានប្រើ ចបកាប់ ញញួរ យាងចុះភក់ដើម្បីកសាងទំនប់ទឹកសម្រាប់ឲ្យទឹកហូរតាមប្រឡាយ ។ នៅលើដីដែលជាកម្មសិទ្ធិរបស់ព្រះរាជបល្ល័ង្ក ព្រះអង្គបានស្ថាបនាផ្ទះគំរូជាច្រើន សម្រាប់ពួកអ្នកក្រខ្សត់ជាងគេ(...) ។ ព្រះអង្គបានចេញសោហ៊ុយឲ្យអ្នកទាំងនោះដោយហិបប្រាក់ផ្ទាល់របស់ព្រះអង្គ និងសង់លំនៅដ្ឋានថ្មី រៀបឲ្យអ្នកទាំងនោះរស់នៅតាមផ្លូវថ្នល់ជាច្រើន(...) ។ ដើម្បីការពារ “ឯករាជ្យភាព” រយៈពេល១៥ឆ្នាំ និងការស្ថាបនាជាតិនិងបូរណភាពដែនដីរបស់ព្រះអង្គ សម្ដេច សីហនុ បានតស៊ូដើម្បីឲ្យព្រំដែនរបស់កម្ពុជាត្រូវទទួលស្គាល់ក្នុងកម្រិតបច្ចុប្បន្ន ។ (...)សន្តិភាពមិនត្រឹមតែគ្របដណ្ដប់លើទូទាំងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែក៏ស្ថិតនៅក្នុងដួងចិត្តប្រជារាស្ត្រគ្រប់រូបដែរ ។ ប្រការនេះ ជាការសម្រេចបានលទ្ធផលដ៏ល្អបំផុតរបស់ប្រទេសកម្ពុជាប្រាកដណាស់” ។

◆ *លោក PAUL GRIMES ក្នុងព្រឹត្តិបត្រ PHILADELPHIA EVENING AND SUNDAY BULLETIN ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ* “ភ្នំពេញជាទីក្រុងទំនើបពិសេសដែលមានមនុស្សរស់នៅ៦០ម៉ឺននាក់ ។ ក្នុងរយៈពេលតិចជាង១៥ឆ្នាំ សម្ដេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ បានប្រែក្លាយតំបន់ការពារផ្នែកខាងក្រោយរបស់អាណានិគមបារាំងដែលគេមិនយកចិត្តទុកដាក់ឲ្យក្លាយជាធានីមួយដែលរចនាឡើងហ្មត់ចត់ ហើយដែលផ្លូវសំខាន់ៗរបស់ធានីនេះត្រូវបានប្រសិទ្ធនាមតាមឈ្មោះរបស់បុគ្គលល្បីល្បាញទាំងឡាយក្នុងប្រវត្តិសាស្ត្រខ្មែរ តាមឈ្មោះបណ្ដាប្រទេសជាមិត្ត និងតាមឈ្មោះឥស្សរជនអន្តរជាតិនានា ដូចជាលោក ហ្សារលដឺហ្គោល និង ម៉ៅ សេទុង ជាដើម ។ ប្រៀបធៀបជាមួយធានីដទៃទៀតនៅអាស៊ី ក្រុងភ្នំពេញបានលេចធ្លោឡើងជាទីក្រុងសន្តិភាព មានរបៀបរៀបរយ និងរាក់ទាក់ក្នុងលក្ខណៈមិត្តភាពបំផុតចំពោះបណ្ដាភ្ញៀវអាមេរិកាំង (*ការកត់សម្គាល់របស់ខ្ញុំៈ* ចាប់តាំងពីឆ្នាំ១៩៦៣ ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយម

បានបដិសេធមិនទទួលជំនួយរបស់សហរដ្ឋអាមេរិកជាស្ពាពរ៣០ លានដុល្លារក្នុងមួយឆ្នាំ) និងនៅឆ្នាំ១៩៦៥ បានកាត់ផ្ដាច់ចំណងទាក់ទងការទូតជាមួយទីក្រុងវ៉ាស៊ីនតោនឌីស៊ី ប៉ុន្តែបានបន្តទទួលស្វាគមន៍បណ្ដាភ្ញៀវអាមេរិកាំងដោយមិត្តភាពជាទីបំផុត (ភ្ញៀវទេសចរ ឥស្សរជននានា ដូចជា លោកព្រឹទ្ធសមាជិក MIKE MANSFIELD ជាដើម ។ល ។...ន.សីហនុ) ។ ព្រះអង្គ (សីហនុ) បានសាងសង់មន្ទីរពេទ្យនិងសាលារៀនរាប់រយខ្នង(ខ្ញុំគូសបញ្ជាក់ៈ ន.សីហនុ) ។ កម្មវិធីសាងសង់ផ្លូវរបស់ព្រះអង្គ(...) ។ ម្នាក់ៗហាក់ដូចជាប្រុងប្រៀបរៀបចំខ្លួនជាស្រេចក្នុងការទទួលស្គាល់ថា ការរំលោភច្បាប់ទាំងនេះ ដែល(បណ្ដាលមកពីអំពើពុករលួយ) ប្រហែលជាមានតិចជាងគេនៅប្រទេសអាស៊ីភាគច្រើន ។ (ការកត់សម្គាល់របស់ខ្ញុំៈ លោក PAUL GRIMES (សហរដ្ឋអាមេរិក) បានកត់សម្គាល់ថា នៅប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយម អំពើពុករលួយ (បាតុភូតនៃពិភពលោក) ត្រូវបានរឹតត្បិតយ៉ាងខ្លាំងជាងបណ្ដាប្រទេសភាគច្រើននៅអាស៊ីទៅទៀត ។ (ន.សីហនុ) ។

◆ លោក M.A. BOUJON ក្នុងព្រឹត្តិបត្រ LA TRIBUNE DE GENEVE ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ ប្រទេសកម្ពុជាជាកោះសន្តិភាពក្នុងចំណោម «ប្រទេសដែលគ្មានអ្នកណាគ្មានស្ដាប់បង្គាប់អ្នកណា» នៅអាស៊ីភាគអាគ្នេយ៍គឺជាប្រទេសមួយពេញទៅដោយឧត្ដមគតិ ដែលជាប្រការលើកកម្លាំងចិត្តយ៉ាងខ្លាំងប្រៀបធៀបជាមួយនឹងផ្នត់គំនិតបែបលោកខាងលិចរបស់យើង ។

◆ R.P នៅក្នុងព្រឹត្តិបត្រ LA SUISSE ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ «ដោយសារការងាររបស់ខ្លួន ប្រទេសកម្ពុជាបានងើបឈរឡើងនិងរកឃើញកំរូនៃបណ្ដាអតីតអ្នកសាងសង់អង្គររបស់ខ្មែរឡើងវិញ» ។

◆ លោក ROBERT GAFNER នៅក្នុងកាសែត JOURNAL DE SIERRE (ប្រទេសស្វីស) ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ សម្ដេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ បានខំប្រឹងប្រែងធ្វើឲ្យកម្ពុជាមានលក្ខណៈជាប្រទេសឧស្សាហកម្ម ប៉ុន្តែជាពិសេស ព្រះអង្គមានព្រះរាជបំណងចង់ឲ្យប្រជាពលរដ្ឋម្នាក់ៗមានអ៊ីៗបរិភោគគ្រប់គ្រាន់និងរស់នៅប្រកបដោយសុភមង្គល ។ (...) ការទស្សនាក្នុងរោងចក្រនិងរោងសិប្បកម្មនានា កំពុងលេចឡើងនៅគ្រប់ទីកន្លែង ហើយក្នុងការរៀបចំជាសហករណ៍ ជាក្រុមសិប្បករ បានបង្ហាញឲ្យឃើញការយកព្រះទ័យយកចិត្តដាក់ប៉ុនណាដែលសម្ដេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ខំប្រឹងធ្វើការនិងលះបង់ព្រះកាយដើម្បីសុភមង្គលរបស់ជនរួមជាតិទាំងអស់» ។

FEUILLE D'AVIS DE SAINTE-CROIX (ប្រទេសស្វីស) ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ «ស្រូវដុះលូតលាស់យ៉ាងល្អដាច់កន្ទុយភ្នែក (...)បន្លែនិងផ្លែឈើគ្រប់ប្រភេទមានច្រើនអនេក ។ ទឹកត្រូវបានទប់ក្នុងទំនប់ជាច្រើនដែលទំនប់ខ្ពស់ៗជាងគេសម្រាប់ធ្វើជាផ្លូវថ្នល់ ។ (...)សម្ដេចព្រះនរោត្តម សីហនុ ត្រូវបានស្រឡាញ់ចូលចិត្តរួមគ្នាពីប្រជារាស្ត្ររបស់ព្រះអង្គ ។ ប្រជាពលរដ្ឋនៃប្រទេសកម្ពុជាសុទ្ធតែជាមនុស្សប្រកបដោយសុភមង្គល ។ (...)កសិកម្មកំពុងមានការរីកលូតលាស់ ។ (...) ប្រការទាំងនេះកំពុងតែសម្រេចរូបរាងឡើងក្នុងភាពសោមនស្សជាឯកច្ឆន្ទ និងត្រេកអររីករាយរបស់ប្រជារាស្ត្រនេះ» ។

◆ H.V. ក្នុងកាសែត LE JOURNAL DE GENEVE ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ «ប្រទេសកម្ពុជាដែលជាកោះសន្តិភាពនៅកណ្ដាលភូមិភាគអាស៊ីអាគ្នេយ៍ នេះត្រូវបានធ្វើឲ្យឈឺចាប់ខ្លាំងនិងបែកបាក់គ្នាដោយសារសង្គ្រាម(...) លទ្ធិសង្គមនិយមព្រះពុទ្ធសាសនារបស់ព្រះអង្គគឺផ្អែកលើភាពសំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ ។ (...)ក្នុងប្រទេសដដែលនេះ ជាទីដែលគ្រឿងយន្ត Bulldozer ទំនើប ខ្លាំងនិងធំដូចសត្វដំរី បានឆ្ការព្រៃនិងឈូសដីធ្វើផ្លូវថ្នល់ឆ្លងកាត់ទីនោះ ។ សម្ដេចព្រះ នរោត្តម សីហនុ ចេះសម្ដែងឲ្យឃើញនយោបាយពិសេសដោយឡែកមួយយ៉ាងប៉ិនប្រសប់ ដែលមហិច្ឆតាកំពូលគឺការពារសន្តិភាពខាងក្នុងព្រំដែនប្រទេសរបស់ព្រះអង្គ និងការកែលម្អស្ថានភាពរស់នៅរបស់ប្រជារាស្ត្រ ព្រះអង្គឲ្យបានប្រសើរជាងមុន (ខ្ញុំសង្កត់បញ្ជាក់ៈន.សីហនុ) ។ ម្យ៉ាងទៀត នេះជាការចាប់ផ្ដើមធ្វើដែលចូលរួមដោយកងទ័ពមួយចំនួន៣៨០០០នាក់ (...)ជាអ្នកស្ថាបនាដើម្បីសុភមង្គលរបស់ប្រជាជាតិ» ។

◆ FEUILLE D'AVIS DE SAINTE-CROIX ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្ដីដកស្រង់ៈ «បន្ទាប់ពីការកាន់កាប់

ផ្សេងៗចំនួន៨សតវត្សរ៍ វាល្មមហើយដែលប្រទេសកម្ពុជាក្រោមការដឹកនាំប្រកបដោយទេពកោសល្យរបស់ព្រះ នរោត្តម សីហនុ ក្នុងរយៈពេល១៥ឆ្នាំនៃឯករាជ្យភាព ដើម្បីប្រែក្លាយឲ្យទៅជារដ្ឋមួយក្នុងចំណោមរដ្ឋនានាដែលជឿនលឿនជាងគេនៅបូព៌ាទិស ។ អនក្ខរភាពបានរលាយបាត់ស្ទើរតែទាំងស្រុង ។ រោងចក្រនានាបានតាំងនៅស្ថិតស្ថេរ ហើយផ្លូវថ្នល់ទាំងឡាយត្រូវបានស្ថាបនាឡើង ។ ស្ពានជាច្រើនត្រូវបានសង់ឆ្លងកាត់ទន្លេសាបដែលជាទន្លេដ៏ធំ (និងទន្លេបាសាក់ៈ ន.សីហនុ) ។ (...) កសិកម្មកំពុងតែរីកលូតលាស់ ។ (...) ប្រការទាំងនេះ កំពុងតែសម្រេចរូបរាងឡើងក្នុងភាពសោមនស្សជាឯកច្ឆន្ទ និងត្រេកអររីករាយរបស់ប្រជារាស្ត្រនេះ (...) ដែលសប្បាយនឹងទុកដាក់ខត្តមគតិរបស់ខ្លួនក្នុងការកើតឡើងវិញនៃប្រជាជាតិខ្លួនជាកោះសន្តិភាពមួយ...)» ។

◆ FEUILLE D'AVIS DE LAUSANNE ចេញផ្សាយខែតុលា ឆ្នាំ១៩៦៨ ។ សេចក្តីដកស្រង់ៈ «ម៉ាស៊ីនបូមទឹកជាច្រើនត្រូវបានផ្តល់សម្រាប់ឲ្យកសិករបូមទឹកបញ្ចូលស្រែ ។ (...) ដោយនាំដើរលេងគ្រប់ទីកន្លែងឆ្លងកាត់ប្រទេសរបស់ព្រះអង្គ សម្តេចព្រះនរោត្តម សីហនុ បានណែនាំឲ្យបញ្ចូលដំណាំថ្មីៗទៀត ដូចជាដំណាំកាហ្វេជាដើម ហើយយើងបានឃើញព្រះអង្គសម្ពោធកម្មន្តសាលជាច្រើន» ។

◆ La Presse de COULOMMIERS ចេញផ្សាយខែវិច្ឆិកា ឆ្នាំ១៩៦៨ ។ សេចក្តីដកស្រង់ៈ «សម្តេច សីហនុ បានសម្រេចធ្វើឲ្យព្រះរាជាណាចក្រព្រះអង្គទៅជារដ្ឋឯករាជ្យនិងកោះសន្តិភាពមួយដោយជោគជ័យ (...) ជាប្រទេសមួយដែលកំពុងតែធ្វើការពង្រីកគ្រប់វិស័យទាំងអស់ៈ កសិកម្ម ឧស្សាហកម្ម សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ។ លើសពីនេះទៀត ខ្សែភាពយន្តឯកសារមួយរបស់លោក ម៉ាសែលតាឡាបូត៍ Marcel Talabot ដែលជាសក្ខីភាពមួយនៃការខ្នះខ្នែងរបស់មនុស្សដ៏ល្បីល្បាញម្នាក់» ។

◆ CONNAISSANCE DU MONDE ចេញផ្សាយខែវិច្ឆិកា ឆ្នាំ១៩៦៨ ។ សេចក្តីដកស្រង់ៈ «ជាប្រទេសល្អកំពុងមានការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចនិងប្រជាសាស្ត្រដែល កុមារា កុមារី និងពួកយុវជនបញ្ចេញឲ្យឃើញការសប្បាយរីករាយនិងភាពក្លៀវក្លាក្នុងការរស់នៅ» ។

◆ ARGUS DE LA PRESSE (ក្រុងប៉ារីស) ចេញផ្សាយខែវិច្ឆិកា ឆ្នាំ១៩៦៨ ។ សេចក្តីដកស្រង់ៈ «ប្រទេសកម្ពុជាស្ថិតនៅមាត់ទ្វារនៃជម្លោះដ៏ខ្លាំងសម្បើមនៅវៀតណាម ហើយនៅតែបន្តការខំប្រឹងប្រែងប្រកបដោយសមានចិត្តឆ្ពោះទៅរកការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចមួយដ៏ក្លាហាន ។ ពិតហើយថា តាំងពីទទួលឯករាជ្យរបស់ខ្លួន(ទើបនឹង១៥ឆ្នាំ) ប្រទេសកម្ពុជាហាក់ដូចជារកឃើញប្រភេទនៃភាពក្សេមក្សាន្តមួយដែលបន្តធានាសុភមង្គលកម្រិតខ្ពស់បំផុតរបស់ប្រជាពលរដ្ឋខ្លួន ជាជាងព្រួយបារម្ភនឹងសង្គ្រាមធ្វើសញ្ញ័យផ្សេងៗដែលតម្រូវឲ្យបង់ខាតប្រាក់កាសយ៉ាងច្រើនសម្រាប់ប្រជារាស្ត្រខ្មែរ» ។

◆ លោក BERNARD K. GORDON នៅក្នុង ASIA SURVEY ចេញផ្សាយខែមករា ឆ្នាំ១៩៦៩ ។ សេចក្តីដកស្រង់ៈ «សម្តេច សីហនុ បានយាងចូលរួមជាព្រះរាជអធិបតីភាពដោយផ្ទាល់ព្រះអង្គក្នុងពិធីសម្ពោធសាលារៀន ឱសថាល័យថ្មីៗ ស្ទើរតែពុំមានលោះសប្តាហ៍ណាមួយឡើយ» ។

◆ កាសែត LE BIEN PUBLIC ចេញផ្សាយថ្ងៃទី៨ ខែមករា ឆ្នាំ១៩៦៩ ។ សេចក្តីដកស្រង់ៈ «ក្នុងតំបន់ដាច់ស្រយាលនានា និងដែលពិបាកចូលដល់ កងទ័ពខេមរភូមិន្ទខ្មែរបានកសាងសាលារៀន ផ្លូវថ្នល់ ស្ពាន និងមន្ទីរពេទ្យយ៉ាងច្រើន» ។

◆ លោក JACQUES LAURENT ក្នុងទស្សនាវដ្តី PARIS-MATCH ចេញផ្សាយខែមីនា ឆ្នាំ១៩៧០ ។ សេចក្តីដកស្រង់ៈ «សម្តេច សីហនុ បានប្រើប្រាស់ពួកបារាំង ដើម្បីប្រមូលខេត្តបីមកវិញ ដែលប្រទេសថៃជាសម្ព័ន្ធមិត្តរបស់ជប៉ុនបានដណ្តើមយក ។ បន្ទាប់មក សម្តេច បានយកព្រះទ័យទុកដាក់ទាមទារឯករាជ្យរបស់ប្រទេសព្រះអង្គពីក្រុងប៉ារីសដោយសន្តិវិធី ។(...) ភាពរស់នៅដោយក្សេមក្សាន្តរបស់កម្ពុជាដែលប្រកបដោយភាពសុខសាន្តនេះគឺជាស្នាមព្រះហស្តរបស់សម្តេច ព្រះនរោត្តម សីហនុ ដោយមិនអាចប្រកែកបាន» ។

◆ លោក PAUL GRIMES នៅក្នុងព្រឹត្តិបត្រ BULLETIN, NEWS ANALYSIS ចេញផ្សាយនៅសហរដ្ឋអាមេរិក ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧០ ។ សេចក្តីដកស្រង់ៈ «សម្តេច សីហនុ បានចំណាយពេល៥ ទៅ៦ថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីយាងទៅកាន់

តំបន់ឆ្ងាយដាច់ស្រយាល និងសម្តែងព្រះរាជកាយវិការស្និទ្ធស្នាលជាមួយប្រជារាស្ត្ររបស់ព្រះអង្គ ។ ព្រះអង្គបានកសាងសាលារៀន និងមន្ទីរពេទ្យជាច្រើន ហើយព្រះអង្គបានទទួលការគោរពប្រណិ-ប័តន៍យ៉ាងខ្ពង់ខ្ពស់ពីប្រជារាស្ត្រស្ទើរគ្រប់ទីកន្លែង» ។

◆ កញ្ញា KATE WEBB នៅក្នុងទូរលេខមួយរបស់ទីភ្នាក់ងារពត៌មាន U.P.I នៅទីក្រុងភ្នំពេញក្រោមរបបគ្រប់គ្រងរបស់ លន់ ណុល (សាធារណរដ្ឋខ្មែរ) ។ សេចក្តីដកស្រង់ៈ «ន.សីហនុ ជាអ្នកកសាងទីក្រុងភ្នំពេញដោយផ្ទាល់ព្រះអង្គដោយផ្ចិតផ្ចង់ ពីភូមិដែលមានតែដីហុយ និងពីការិយាល័យធ្វើការរបស់អាណានិគមបារាំងដែលមានតែមួយចំនួនតូចប៉ុណ្ណោះ» ។

◆ ទីភ្នាក់ងារសារពត៌មាន AP ក្រុងវ៉ាស៊ីនតោនឌីស៊ី ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧០ ។ សេចក្តីដកស្រង់ៈ «លោកព្រឹទ្ធសមាជិក MIKE MANSFIELD បាននិយាយថា សម្តេច មានព្រះបញ្ញាញាណ ហើយទទួលខុសត្រូវចំពោះការថែរក្សាឲ្យអព្យាក្រឹតភាពនិងសមាសភាពកម្ពុជានៅគង់វង្ស» ។

◆ លោក ARNOLD DIBBLE, SUNDAY REPORT នៅក្នុងទូរលេខទីភ្នាក់ងារពត៌មាន U.P.I នៅទីក្រុងម៉ានីល ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧០ ។ សេចក្តីដកស្រង់ៈ «លក្ខណៈអព្យាក្រឹតភាពរបស់ សីហនុហាក់ដូចជាបានតម្រូវចិត្តបុកទាំងសងខាងល្អជាងគេបង្អស់» ។

◆ លោក BERTIL GALLAND ក្នុងព្រឹត្តិបត្រ FEUILLE D'AVIS DE LAUSANNE ចេញផ្សាយថ្ងៃអង្គារ ទី៥ ខែធ្នូ ឆ្នាំ១៩៧០ ។ សេចក្តីដកស្រង់ៈ «នៅប្រទេសកម្ពុជាមានខុសប្រាហកម្មមួយដែលទើបនឹងលេចឡើង ។ អ្វីៗដែលផ្តល់ប្រយោជន៍បានពុសុសសាយគ្រប់ទិសទី ។ រោងចក្រទាំងឡាយមានការរីកចម្រើន (ខ្ញុំគូសបញ្ជាក់ៈន.សីហនុ) អ្វីដែលផ្តល់ប្រយោជន៍ទីមួយគឺឯករាជ្យភាពរបស់មាតុភូមិត្រូវបានការពារយ៉ាងខ្លាំងក្លា ទោះបីជាមានការគាបសង្កត់ ការប្រើល្បិចកលផ្សេងៗក៏ដោយ ។ ប្រវត្តិ-សាស្ត្រនឹងផ្តល់យុត្តិធម៌ឲ្យសម្តេច» ។

◆លោក PETER SHARROCK ទីភ្នាក់ងារពត៌មាន REUTER ភ្នំពេញថ្ងៃ២៣ ខែធ្នូ ឆ្នាំ១៩៧០ ។ សេចក្តីដកស្រង់ៈ «មុនពេលទម្លាក់សម្តេច សីហនុ ពីតំណែងកាលពីខែមីនា មុនឯកសារបញ្ជាក់ពីស្រូវអង្ករ និងប្រាក់ចំណូលបានមកពីការនាំចេញទូទៅត្រូវបានព្យាករណ៍ ។ ស្តុកបម្រុងទុកសម្រាប់ដោះដូរជាមួយបរទេសនៅមានគ្រប់គ្រាន់ ។ (...) ក្រោយពីមានឯករាជ្យម្ចាស់ការផ្នែកសេដ្ឋកិច្ចគួរសមនៅក្នុងអំឡុងពេលប្រាំបួនឆ្នាំមុនដំបូងនៃសង្គ្រាម (កំណត់សម្គាល់របស់សម្តេច សីហនុៈ ឯករាជ្យ សេដ្ឋកិច្ច របស់កម្ពុជានេះ បានត្រូវធ្វើឲ្យហិនហោចរហូតដល់ខែទី៩ បន្ទាប់ពីរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាមរតកមានប្រយោជន៍មួយដែលបន្សល់ទុកដោយសង្គមរាស្ត្រនិយម ។ ប៉ុន្តែ ដូចដែលលោក PETER SHARROCK បានអះអាងនៅពេលនោះថា គឺឆ្នាំ១៩៧១ មានឱនភាពផ្នែកសេដ្ឋកិច្ចដ៏ធ្ងន់មួយនិងការពឹងផ្អែកខាងសេដ្ឋកិច្ចទាំងស្រុងមួយទៅលើសហរដ្ឋអាមេរិក)» ។

◆ លោក YVES-GUY BERGÈS ក្នុងទស្សនាវដ្តីប្រចាំខែ "LECTURE POUR TOUS" ចេញផ្សាយខែមេសា ឆ្នាំ១៩៧១ ។ សេចក្តីដកស្រង់ៈ «សន្តិភាពត្រូវបានការពារយ៉ាងអស្ចារ្យដោយព្រះមហាក្សត្រ នរោត្តម សីហនុ រហូតមកដល់ឆ្នាំចុងក្រោយ (១៩៧០) ។ (...) ប្រទេសដែលគួរឲ្យចូលចិត្តរស់នៅ(...) បានលិចសន្សឹមៗនិងប្រែប្រួលខុសពីសភាពដើម ។ សៀមរាបគឺជាទីក្រុងដ៏មនោរម្យមួយមានភូមិគ្រឹះតូចៗកប់បាត់ទៅក្នុងដើមឈើធំៗពណ៌បៃតងស្រងាត់ និងមានរុក្ខវិថីធំទូលាយជាច្រើន» ។

◆ លោក ALLAIN DAWSON នៃទីភ្នាក់ងារសារពត៌មាន U.P.I ទីក្រុងភ្នំពេញថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧១ ។ សេចក្តីដកស្រង់ៈ «កំពង់សោមគឺទីក្រុងមួយដែលកសាង ដោយអតីតព្រះប្រមុខរដ្ឋ នរោត្តម សីហនុ» ។

◆ លោក MALCOLM W.BROWNS ក្នុងកាសែត THE NEW YORK TIMES ចេញផ្សាយថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧២ ។ សេចក្តីដកស្រង់ៈ «ពេលដែលប្រជារាស្ត្រខ្មែរជួបវិបត្តិ ក៏បាននឹកដល់រាជាធិបតេយ្យ ។ ប្រជារាស្ត្ររបស់ព្រះអង្គមានការអាឡោះអាល័យចំពោះ«ថ្ងៃដែលខ្លួនធ្លាប់សប្បាយ» កាលពីពីរឆ្នាំកន្លងទៅ នៅពេលដែលទឹកដីនេះជាព្រះរាជាណាចក្រ មានការហូបចុកបរិបូរណ៍ សម្បូណ៌សប្បាយ និងសុខសន្តិភាព ។ អនុស្សាវរីយ៍រាជានិយមនៅមានច្រើនពាសវាលពាសកាលនៅឡើយ ។ (...) ការនឹកឃើញដល់សម្តេច សីហនុ នៅតែរស់រវើកជានិច្ច» ។

◆ *ទស្សនាវដ្តី FAR EASTERN ECONOMIC REVIEW ចេញផ្សាយថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧២ ។ សេចក្តីដកស្រង់ៈ «បើក្រឡេកមើលទៅក្រោយវិញ មានប្រជាជនមួយចំនួនកំពុងតែយល់ដឹងនូវគតិបណ្ឌិតនៃនយោបាយរបស់សម្តេច សីហនុ» ។*

◆ *កាសែត THE NEW YORK TIMES ចេញផ្សាយថ្ងៃពុធទី៤ ខែកក្កដា ឆ្នាំ១៩៧៣ ។ សេចក្តីដកស្រង់ៈ «ការទទួលស្គាល់តួនាទីដ៏សំខាន់របស់សម្តេច សីហនុ នៅក្នុងនយោបាយប្រទេសកម្ពុជាពិតជាត្រឹមត្រូវណាស់ ។(...) វាច្បាស់ណាស់ថា រដ្ឋាភិបាលសម្តេច សីហនុ នឹងមានការលម្អៀងមកខាងកម្ពុជា ដែលជាការប្រឆាំងជំទាស់នឹងឥទ្ធិពលពីទីក្រុងហាណូយ ទីក្រុងប៉េកាំង និងទីក្រុងមូស្គូ ក៏ដូចជាពីទីក្រុងវ៉ាស៊ីនតោនអ៊ីចឹងដែរ ពោលគឺជាអ្វីដែលវាគួរតែកើតមាន» ។*

◆ *លោក HENRY S.BRANDSHER ក្នុងកាសែត WASHINGTON STAR, NEWS ចេញផ្សាយថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៣ ។ សេចក្តីដកស្រង់ៈ «ប្រជាជនជាច្រើនចង់បាននូវអ្វីដែលធ្លាប់មានកាលពី«សម័យសម្តេច សីហនុ» ។*

◆ *កញ្ញា SYLVANA FOA នៃទីភ្នាក់ងារពត៌មាន U.P.I ក្រុងភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៣ ។ សេចក្តីដកស្រង់ៈ «អ្នកការទូតមួយរូបដែលប្រទេសរបស់ខ្លួនមានសម្ព័ន្ធភាពយ៉ាងសកម្មជាមួយរបប លន់ ណុល និយាយថា សម្តេច សីហនុ ធ្វើឲ្យប្រជារាស្ត្ររបស់ព្រះអង្គមានហូប មានចុកបរិបូរណ៍ សម្បូណ៌សប្បាយ និងមានសន្តិភាព» ។*

◆ *លោក ROLAND PIERRE PARINGAUX នៃទីភ្នាក់ងារពត៌មាន A.F.P ភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៣ ។ សេចក្តីដកស្រង់ៈ «ក្នុងប្រទេសមួយគេគ្មានឃើញអ្នកសុំទានណាម្នាក់ឡើយមុនសម័យសង្គ្រាម» ។*

◆ *លោក FRANÇOIS NIVOLON ក្នុងកាសែត LE FIGARO ចេញផ្សាយថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៣ ។ សេចក្តីដកស្រង់ៈ «កសិករថ្នាក់កណ្តាលបានគិតពិចារណាដោយសមហេតុផលថាៈ ពេលដែលសម្តេច សីហនុ នៅក្នុងស្រុក គឺពុំមានសង្គ្រាមទេ ហើយយើងក៏មិនក្រក្សត់ដែរ ។ ឥឡូវនេះ នៅក្នុងស្រុកកើតមានសង្គ្រាម ហើយយើងទាំងអស់បានធ្លាក់ខ្លួនក្រ ខ្វះមុខខ្វះក្រោយ» ។*

◆ *លោក ALEXANDRE CASELLA នៅក្នុងសារពត៌មាន «២៤HEURES» ចេញថ្ងៃ១១ ខែធ្នូ ឆ្នាំ១៩៧៣ ក្រុងឡូហ្សាន ។ សេចក្តីដកស្រង់ៈ «យើងមិនគួរផ្តួលរំលំសម្តេច សីហនុ ទាល់តែសោះ ។ មនុស្សដែលនិយាយពាក្យទាំងនេះមកកាន់ខ្ញុំពុំមែនជាយុទ្ធិកជនម្នាក់របស់សម្តេច សីហនុ ទេ ប៉ុន្តែជាឥស្សរជនជាន់ខ្ពស់ម្នាក់របស់សាធារណរដ្ឋខ្មែរដែលផ្ញើមកឲ្យខ្ញុំនូវគុល្យការបីឆ្នាំនៃរបបថ្មីនោះ ជាតុល្យការមួយដែលមានលំនាំទៅរកភយន្តរាយទាំងស្រុង» ។*

◆ *លោក MATT FRANJOLA នៃទីភ្នាក់ងារពត៌មាន AP ក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៤ ។ សេចក្តីដកស្រង់ៈ «ឥឡូវនេះ គេពិបាកនឹកដល់ប្រទេសកម្ពុជាកាលពី៤ឆ្នាំកន្លងទៅដែលជាព្រះរាជាណាចក្រនៅតំបន់ត្រូពិចមួយដែលប្រជាកសិកររស់នៅក្នុងភាពរុងរឿង» ។*

◆ *កាសែត LE MONDE ចេញផ្សាយថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៥ ។ សេចក្តីដកស្រង់បទវិចារណកថារបស់កាសែតៈ ការស្រលាញ់ជាតិមាតុភូមិគ្មានព្រេះស្រាំ ឆន្ទៈជាតំណាងអ្នកសាងសង់ប្រាសាទអង្គររបស់កម្ពុជាបានជំរុញឲ្យសម្តេចនាំមុខការប្រយុទ្ធមួយដែលនៅក្នុងរយៈពេលនោះ ព្រះអង្គបានឈ្វេងយល់និងមានបន្ទូលជារឿយៗពីរឿងនោះ ។ សម្តេចនឹងបាត់បង់អំណាចទាំងអស់របស់ព្រះអង្គដែលមានជាយូរមកហើយ ។ សម្តេចបានដោះព្រះកាយផុតពីវិញ្ញាសានេះដោយភាពថ្លៃថ្នូរ ។ សម្តេចពុំបានដាក់រាជក្រោមការវាយប្រហារយ៉ាងខ្លាំងក្លាពីការឈ្លានពានមួយរបស់បរទេសទេ ។ (...) ព្រះអង្គចេះបញ្ចប់ប្រកបដោយភាពក្លៀវក្លានិងក្លាហាននូវគ្រោះថ្នាក់នៃខ្សែស្រឡាយរបស់ព្រះអង្គ» ។*

◆ *លោក FRANÇOIS NIVOLON ក្នុងកាសែត LE FIGARO លេខចេញផ្សាយថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៨០ ។ សេចក្តីដកស្រង់ៈ «នៅដើមឆ្នាំ១៩៨០ ប្រទេសកម្ពុជាមានលក្ខណៈជាប្រទេសថ្កុំថ្កើងរុងរឿង ។ ជញ្ជីងចំណូលចំណាយរបស់ប្រទេសមានលំនឹង ។ ការប្រូតកាត់នៅឆ្នាំ១៩៦៩ បានទទួលផលស្រូវយ៉ាងសម្បើម និងផ្តល់ផលលើសមួយដែលអាចនាំចេញបានចំនួន៤០០ពាន់តោន ។ រោងចក្រចម្រាញ់ប្រេងកាតនៅកំពង់សោម និងផ្លូវដែកដែលភ្ជាប់*

កំពង់ផែនេះមកកាន់ទីក្រុងភ្នំពេញ បានត្រូវបើកសម្ពោធឲ្យប្រើប្រាស់ ។ បណ្តាញផ្លូវថ្នល់ទាំងអស់មានលក្ខណៈល្អប្រសើរបំផុត ហើយវិស័យទេសចរណ៍បានស្គាល់នូវសន្ទុះរីកចម្រើនថ្មីមួយ ជាមួយការចុះចតរបស់យន្តហោះធំៗ និងការកសាងសណ្ឋាគារជាច្រើន» ។

◆លោក KEITH B.RICHBURG នៅក្នុងកាសែត WASHINGTON POST ចេញផ្សាយថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៨៧ ។ សេចក្តីដកស្រង់៖ «សម្តេចព្រះ នរោត្តម សីហនុ ដឹកនាំប្រទេសកម្ពុជាឲ្យទទួលបាននូវឯករាជ្យនៅឆ្នាំ១៩៥៣» ។

◆ កាសែត THE CHRISTIAN SCIENCE MONITOR ចេញផ្សាយខែឧសភា ឆ្នាំ១៩៨៧ ។ សេចក្តីដកស្រង់៖ «បុគ្គលិកជំនួយបរទេសនៅទីក្រុងភ្នំពេញនិងប្រជាជនកម្ពុជាភាគច្រើននិយាយថា ប្រជាកសិករមួយភាគធំនៅតែស្រលាញ់ចូលចិត្តសម្តេច សីហនុ ហើយពួកគេនៅចងចាំពីសម័យកាលដ៏រុងរឿង និងសុខសន្តិភាពក្នុងអំឡុងពេលដែលព្រះអង្គគ្រប់គ្រងប្រទេសនាទសវត្សរ៍ឆ្នាំ១៩៦០ មុនពេលដែលមានភាពវឹកវរច្របូកច្របល់នៃរបបស្តាំនិយម លន់ ណុល និងរបបចង់បានភាពបរិសុទ្ធឥតខ្ចោះដ៏ឃោរឃៅរបស់ខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត» ។

◆ លោក JACQUES BEKAERT ក្នុងកាសែត BANGKOK POST ចេញផ្សាយថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៨៧ ។ សេចក្តីដកស្រង់៖ «ប្រទេសដែលធ្លាប់តែមានអំណាច និងមានមោទកភាព បានបាត់បង់កម្លាំងនិងឥទ្ធិពលរបស់ខ្លួនយ៉ាងច្រើននៅក្នុងអំឡុងប៉ុន្មានសតវត្សរ៍កន្លងទៅ ទោះបីជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០និង ១៩៦០ ព្រះរាជាណាចក្រកម្ពុជាឃើញដូចជាគំរូមួយនៃអព្យាក្រឹតភាពឆ្លាតវៃនៅក្នុងសមុទ្រសង្គ្រាមយ៉ាងណាក៏ដោយ ។ (...) ប្រជាជន ទទួលស្គាល់សារសំខាន់ពិសេសរបស់សម្តេច សីហនុ ។ (...)ករណីលោក ហ្សាល ឌឺហ្គោល ក៏មិនខុសគ្នាដែរ ។ (...) ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៥០ សម្តេច សីហនុ មិនដែលផ្លាស់ប្តូរព្រះរាជតម្រិះរបស់ព្រះអង្គឡើយអំពីបញ្ហាដ៏សំខាន់នេះ ពោលគឺឯករាជ្យភាពនិងបូរណភាពទឹកដីនៃប្រទេសកម្ពុជា» ។

◆ ទីភ្នាក់ងារសារព័ត៌មាន A.F.P ទីក្រុងភ្នំពេញថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៨៧ ។ អ៊ីម៉ាំ មូសា មូហាមេត អាលី បានគូសបញ្ជាក់ថា «ក្រោមការគ្រប់គ្រងរបស់សម្តេច សីហនុ ការរស់នៅមានលក្ខណៈងាយស្រួលបំផុត ហើយសហគមន៍មូស្លីមសុទ្ធតែមានជីវភាពធូរធារ» ។

◆ (កញ្ញា) Paula CHIN, (កញ្ញា) Fay WILLEY ជាមួយ (លោក) Ron MOREAU ក្នុងទស្សនាវដ្តី NEWSWEEK ចេញផ្សាយថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៨៧ ។ សេចក្តីដកស្រង់៖ «ប្រជាជនកម្ពុជាជាច្រើននៅតែនិយាយពោរពេញដោយការស្រលាញ់ពេញចិត្តចំពោះយុគសម័យដ៏រុងរឿងនៃជំនាន់របស់សម្តេច សីហនុ ដូចដែលពលរដ្ឋកម្ពុជាមួយរូបបានពោលថា នៅគ្រានោះពុំមានសង្គ្រាមទេ ហើយប្រាក់បៀវត្សរ៍មានកម្រិតខ្ពស់ ចំណែកឯសាច់មាន់ក៏មានតម្លៃថោក» ។

◆ កាសែត THE JAPAN TIMES ចេញផ្សាយថ្ងៃអាទិត្យទី៣១ ខែមករា ឆ្នាំ១៩៨៨ ។ សេចក្តីដកស្រង់៖ «កេរ្តិ៍ឈ្មោះរបស់សម្តេច សីហនុ ជាបុរសសុចរិតមានប្រជាជនខ្មែរស្រលាញ់ចូលចិត្តនិងដើរតាមច្រើន..» ។

◆ លោក JAMES PRINGLE ក្នុងកាសែត THE AUSTRALIAN ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ១៩៨៨ ។ សេចក្តីដកស្រង់៖ «គេ (ប្រជាជនកម្ពុជា) ចាត់ទុកពេលដែល សម្តេច សីហនុ គ្រប់គ្រងប្រទេសថាជា«យុគសម័យមាស» ។

◆ លោក JAMES PRINGLE នៅក្នុងទស្សនាវដ្តី "FAR EASTERN ECONOMIC REVIEW" ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៨៨ ។ សេចក្តីដកស្រង់៖«...ឥឡូវត្រូវបានចាត់ទុកថា ជាយុគសម័យមាសនៅពេលដែលសម្តេចសីហនុដឹកនាំប្រទេសកម្ពុជាជានៅទសវត្សរ៍ឆ្នាំ១៩៦០ ។ (...) នៅក្នុងឆ្នាំងមានសុទ្ធតែសាច់មាន់ នៅក្នុងហោប៉ៅមានសុទ្ធតែក្រដាសប្រាក់ ហើយនិងសន្តិភាពដែលជាសន្តិភាពដ៏ពិសិដ្ឋ» ។

◆ LA LIBRE BELGIQUE ចេញផ្សាយថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៨៨ ។ សេចក្តីដកស្រង់៖ «ប្រទេសកម្ពុជានេះជាអតីតជង្រុកស្រូវមួយ(...) ។ កាលពីដើមប្រទេសកម្ពុជាអ្នកនាំស្រូវចេញដ៏ធំ ។

◆ លោក THIERRY DESJARDINS ក្នុងកាសែត LE FIGARO ចេញផ្សាយថ្ងៃពុធ ទី៤ ខែមករា ឆ្នាំ១៩៨៩ ។ សេចក្តី

ដកស្រង់ៈ «ប្រទេសកម្ពុជារបស់សម្តេច សីហនុ គឺជាជង្រុកស្រូវមួយក្នុងចំណោមជង្រុកស្រូវធំៗ នៃពិភពលោក» ។

◆ លោក RAPHAEL MORATA ក្នុងទស្សនាវដ្តី POINT DE VUE ចេញផ្សាយថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៣ ។ សេចក្តីដកស្រង់ៈ «ខ្ញុំនៅនឹកឃើញសម័យដែលសម្តេច សីហនុ គ្រប់គ្រងប្រទេស ។ នៅពេលនោះ កម្ពុជាជាប្រទេសដែលមានសំណាងល្អមួយ នេះជាការប្រកាសរបស់ព្រះសង្ឃវ័យចំណាស់មួយអង្គ ។ អ្នករកស៊ីមិននៅនឹងកន្លែងម្នាក់បានបន្ថែមថាៈ គេបានរៀបរាប់ពីសម័យព្រះអង្គកាន់អំណាចប្រាប់ខ្ញុំថាមនុស្សទាំងអស់តាំងពីកសិកររហូតដល់មន្ត្រីរាជការសុទ្ធតែមានការងារធ្វើនិងរស់នៅដោយភាពសម្បូណ៌សប្បាយ ។

◆◆◆

របបដែលកាន់អំណាចបន្តបន្ទាប់គ្នាពីរ គឺរបប លន់ ណុល (សាធារណរដ្ឋខ្មែរ) ពីឆ្នាំ១៩៧០ដល់១៩៧៥ និងរបប ប៉ុល ពត (ខ្មែរក្រហម-កម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨) បានជះឥទ្ធិពលមកលើសង្គមរាស្ត្រនិយមនិងរូបខ្ញុំនូវពាក្យមួលបង្កាច់និងអ្វីៗដែលផ្ទុយនឹងការពិតមិនសមទំនងមួយចំនួនធំ ហើយប្រការនេះគឺដើម្បីបិទបាំង (នូវអ្វីដែលជាកិច្ចការចាំបាច់មួយដែលមិនអាចធ្វើបាន) «ស្នាដៃ» អាក្រក់ផ្ទាល់របស់ពួកគេ ។ ដើម្បីធ្វើឲ្យមានការពិតនៃប្រវត្តិសាស្ត្រឡើងវិញនិងការពារសង្គមរាស្ត្រនិយម ខ្ញុំមិនត្រូវការចំណាយពេលវេលាធ្វើជាអ្នកជជែកការពារម្នាក់ដើម្បី«បុព្វហេតុផ្ទាល់របស់ខ្លួន»ឡើយ ។ ក្នុងស្រុកនេះនិងនៅទីដទៃទៀត ខ្ញុំគ្រាន់តែសុំអនុញ្ញាតបង្ហាញជូនចំពោះប្រិយមិត្តអ្នកអានប្រុស-ស្រីដ៏ថ្លៃថ្នូររបស់ខ្ញុំ នូវសក្ខីភាពទាំងឡាយដែលកើតឡើងដោយឯកឯងប្រកបដោយលក្ខណៈច្បាស់លាស់បំផុត មិនអាចបដិសេធបាន និងត្រឹមត្រូវគ្មានល្អៀង ហើយស្របតាមសភាពពិតដែលបង្ហាញពីការចូលចិត្តចំពោះសង្គមរាស្ត្រនិយមរបស់ពួកអ្នកកាសែតល្បីៗនៃពិភពលោកសេរីមួយដែលពុំមែនជា «សម្ព័ន្ធមិត្ត»ខ្ញុំ ឬពុំមែនជាមិត្តរបស់ខ្ញុំផងទេ ។

◆◆◆

នៅពេលនេះ ខ្ញុំសូមលើកយកសម្តីខ្លះៗ និង«អំណះអំណាង» របស់លោក នួន ជា មកបញ្ជាក់ជូន ។

ឥឡូវនេះខ្ញុំសូមអនុញ្ញាតពិនិត្យពាក្យសម្តី និង«អំណះអំណាង»របស់គាត់ ហើយបង្ហាញនូវកំណត់សម្គាល់របស់ខ្ញុំទល់នឹង«អំណះអំណាង» ឬ «ការអួតក្អេងក្អាង» ទាំងនោះ ។

ប្រភពៈ កាសែត THE CAMBODIA DAILY ចេញផ្សាយថ្ងៃអង្គារ ទី៣ ធ្នូ ឆ្នាំ២០០២ៈ

I. «...មានប្រជាជនក្រីក្រច្រើន» ។

ចំពោះបញ្ហានេះ ខ្ញុំសូមឲ្យប្រិយមិត្តអ្នកអានទាំងប្រុស-ស្រីរបស់ខ្ញុំអានឡើងវិញនូវសក្ខីភាពជាសាក្សីខាងលើទាក់ទងជាពិសេសនឹងស្ថានភាពពិតប្រាកដនៃប្រជាជនកម្ពុជា ទាក់ទងនឹងកសិកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់យើង ។ សក្ខីភាពជាសាក្សីទាំងនេះគឺវាគ្រប់គ្រាន់ណាស់ទៅ ហើយដើម្បីបង្ហាញឲ្យឃើញពីពុតត្បុតអាក្រក់របស់លោក នួន ជា និងរបបខ្មែរក្រហមរបស់គាត់ទាំងស្រុង ក្នុងឋានៈគាត់ជាអ្នកភូតកុហក និងជាអ្នកចោទប្រកាន់ប្រកបដោយអសុទ្ធចិត្តបំផុត ។

II. លោក នួន ជា បាននិយាយកាលពីថ្ងៃសៅរ៍នៅផ្ទះរបស់គាត់នាទីក្រុងប៉ៃលិនថា «...យើងបានព្យាយាមធ្វើឲ្យគ្រប់ៗគ្នាមានសិទ្ធិស្មើគ្នា ហើយឲ្យគ្រប់ៗគ្នាមានបាយហូប (នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ។

ការកត់សម្គាល់របស់ខ្ញុំៈ «ធ្វើឲ្យគ្រប់ៗគ្នាមានសិទ្ធិស្មើគ្នា»ៈ របបខ្មែរក្រហម (១៧មេសា ១៩៧៥ ដល់៦មករា១៩៧៩) បានលេចចេញឡើងដូចរបបសក្តិភូមិលើសពី៥០០ភាគរយ ។ ក្នុងរបបនេះប្រជាជនកម្ពុជាទាំងប្រុសទាំងស្រីត្រូវបានបែងចែកជាបីវណ្ណៈ ។

វណ្ណៈទីមួយៈ (គឺវណ្ណៈនាយចៅហ្វាយផ្តាច់ការ ពួកអ្នកប្រើអំណាចផ្តាច់ការប្រុស-ស្រី ដែលមានសិទ្ធិអំណាចទាំងអស់ រួមទាំងអំណាចបញ្ជាឲ្យគេធ្វើទារុណកម្មប្រជាជនរហូតដល់ស្លាប់ ឬសម្លាប់ដោយរបៀបឃោរឃៅបំផុតមិនថាអ្នកណាជាអ្នកណាឡើយ និងមានអ្វីៗទាំងអស់ដែលជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជារបស់ប្រជាជាតិនិងប្រជាជនខ្លួន)ៈ ប៉ុល ពត និងពួកអ្នកប្រើអំណាចផ្តាច់ការប្រុស-ស្រី ដែលគាត់ចាត់ទុកជាបណ្តា«សមមិត្ត» ដ៏សំខាន់បំផុតរបស់ខ្លួន (ពួកមេដឹកនាំ) ។

វណ្ណៈទីពីរៈ គឺវណ្ណៈ «កម្មាភិបាល» និង «យុទ្ធជន» ដែលមាន

ជំនឿទុកចិត្ត"ដាច់ខាត" (ប៉ុន្តែដែលគេអាចធ្វើការពិនិត្យឡើងវិញ) ចំពោះ "នាយចៅហ្វាយ"ទាំងឡាយ(វណ្ណៈទីមួយ) ។

វណ្ណៈទីពីរនេះ មានសិទ្ធិ មានផ្ទះសម្បែង បេះផ្លែឈើ និងមានម្ហូបអាហារគ្រប់គ្រាន់ ។

វណ្ណៈទីបីៈ គឺវណ្ណៈទាសករ ដែលគេដកហូតទ្រព្យសម្បត្តិដើមទាំងអស់ ផ្ទះសម្បែង ឬខ្ទមស្លឹក ស្រែចម្ការ ឬអំពកដីតូចៗ ដោយមិននិយាយពីគ្រឿងអលង្ការកំប៉ិកកំប៉ុកផងទេ ។ល ។ ... ហើយដែលគេបំបាត់មិនឲ្យមានសិទ្ធិឬសេរីភាពដ៏តិចតួចថែមទៀត ដែលជារៀងរាល់ថ្ងៃ អ្នកទាំងនោះបានទទួលតែរបបអាហារដ៏អត្តខាត់មួយប៉ុណ្ណោះ ហើយមិនគ្រប់គ្រាន់សម្រាប់បំពេញការស្រេកឃ្លានឡើយ ដោយគេឲ្យធ្វើការគ្មានការឈប់សម្រាក ហើយគេអាចធ្វើទារុណកម្ម ឬសម្លាប់ទៅតាមអំពើចិត្ត តាមអារម្មណ៍មួយហ្វូងរបស់ចៅហ្វាយៗ ។

ក្នុងវណ្ណៈទីបីនេះ ក្រៅពីជនរួមជាតិរបស់យើង ជាកសិករ ឬកម្មករ គឺមានភាគច្រើនបំផុត ជាបញ្ញវ័ន្ត វិស្វករ គ្រូពេទ្យ គ្រូបង្រៀន អ្នកជំនួញ គហបតី បណ្ដាសមាជិកនៃព្រះរាជវង្សានុវង្ស អ្នកតស៊ូក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥ ប៉ុន្តែ ជា"មិត្ត" របស់ "ក្រុងហាណូយ" និង "ក្រុងមូស្គូ" ឬប្រទេសមួយនៃលោកសេរី... ។ តើ "របស់នោះ"ឬ ដែលលោក នួន ជា ឲ្យឈ្មោះថា "គ្រប់ៗគ្នាសុទ្ធតែមានសិទ្ធិស្មើៗគ្នា"? ។

◆◆◆

ភ្នំពេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២

## សេចក្ដីបន្ថែមក្រោយពីចុះហត្ថលេខា

ក) សង្គមរាស្ត្រនិយម មានលទ្ធភាពផ្ដល់ឲ្យកសិករប្រុស-ស្រីរបស់យើងនូវដីធ្លីទាំងអស់ (ដីស្រែ ។ល ។...) ដែលជាកម្មសិទ្ធិរបស់ព្រះរាជបល្ល័ង្ក (ឬព្រះបរមរាជវាំង) ហើយនៅលើដីទាំងនោះ ប្រជាកសិករប្រុសស្រីជាទីស្នេហាទាំងនេះបានរស់នៅនិងធ្វើការ ។ ដីទាំងនោះបានក្លាយទៅជាកម្មសិទ្ធិរៀងៗខ្លួនរបស់ពួកគេជាស្ថាពរ ។

ខ) សង្គមរាស្ត្រនិយមបានរារាំងមិនឲ្យពួកអ្នកមាននិងពួក "អ្នកមានអំណាច" ដណ្ដើមយកតែម្នាក់ឯងនូវដីធ្លីដែលជាកម្មសិទ្ធិរបស់បណ្ដាជនរួមជាតិក្រីក្រ ឬអ្នកដទៃទៀតឡើយ ។

គ) ពួកនិស្សិតដែលចាកចេញពីមហាវិទ្យាល័យរបស់គេ ហើយដែលមិនធ្វើការនៅទីក្រុង ត្រូវបានលើកទឹកចិត្តដោយសង្គមរាស្ត្រនិយមឲ្យប្រែក្លាយខ្លួនទៅជាអ្នកស្រែចម្ការ ។ សង្គមរាស្ត្រនិយមបានផ្ដល់ដីធ្លីទំនេរៗឲ្យគេ និងផ្ទះសម្បែង សត្វពាហនៈ និងឧបករណ៍ សម្រាប់ប្រកបការងារ ។ ម្យ៉ាងទៀត សហករណ៍កសិកម្មជាច្រើនត្រូវបានបង្កើតឡើងសម្រាប់ពួកគេទាំងនោះ ដែលមិនធ្វើការនៅទីក្រុង ហើយដែលយល់ព្រមតាំងលំនៅឋាននៅតាមខេត្តនិងនៅតាមតំបន់ទាំងឡាយដែលយើងធ្វើឲ្យទៅជាតំបន់កសិកម្ម ឬចិញ្ចឹមសត្វ ។

ឃ) ដូចដែលពួកអ្នកកាសែតលោកខាងលិចល្បីៗបានប្រាប់ឲ្យដឹងក្នុងអត្ថបទចុះផ្សាយក្នុងកាសែតធំៗរបស់ពួកគេ (ក្នុងទសវត្សរ៍ឆ្នាំ១៩៦០, ១៩៧០ និង១៩៨០)ថា នៅសម័យសង្គមរាស្ត្រនិយមពុំឃើញមានអ្នកសុំទានម្នាក់ឡើយ ហើយប្រជាជនតូចតាចម្នាក់ៗទាំងប្រុសក៏ដូចស្រីបានបរិភោគអាហារទៅតាមការស្រេកឃ្លានរបស់គេ ។

ង) តើពួកខ្មែរក្រហមរបស់ពួក ប៉ុល ពត, នួន ជា ។ល ។ ...បានធ្វើអ្វីខ្លះសម្រាប់ប្រជាជនតូចតាចទាំងនេះ? ។ ពួកគេបានរឹបអូសកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកទាំងនោះគ្មានសល់ (ផ្ទះសម្បែង ខ្ទមស្លឹក ដីស្រែចម្ការ គ្រឿងអលង្ការ សត្វពាហនៈ ។ល ។...) ពួកគេបានធ្វើឲ្យអ្នកទាំងនោះទៅជាទាសករ ដោយគ្មានសេរីភាពសិទ្ធិណាមួយសោះឡើយ លើកលែងតែ"សិទ្ធិ" ត្រូវគេប្រមាថធ្វើទារុណកម្មនិងសម្លាប់ចោលប៉ុណ្ណោះ ។

ត្រូវធ្វើឲ្យខ្វល់ចិត្តរៀងរាល់ថ្ងៃដោយការស្រេកឃ្លាន (ប្រជាជនតូចតាច)ទាំងប្រុស ទាំងស្រី ពុំមានសិទ្ធិប្រមូលផ្លែឈើទុំ ឬស្អុយរលួយដែលធ្លាក់ពីដើមរបស់វាដើម្បីបរិភោគថែមទៀត ។ គឺរឿងទាំងនេះហើយដែលពួកគេ(ខ្មែរក្រហម) ហៅ"បដិវត្តប្រជាមានិត" ការតស៊ូរហូតស្លាប់របស់ "ប្រជាជន" ទល់នឹង "រាជានិយមសក្តិភូមិ"!!!

ព្រះហស្តលេខា

នរោត្តម សីហនុ

ភ្នំពេញថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២

**ប្រែសម្រួលក្រៅផ្លូវការ ដោយ ទេព ម៉េងឃាន**

# យុត្តិធម៌សម្រាប់កម្ពុជា

នៅក្នុងខណៈដែលមានការពិភាក្សាពីរឿង សាដាមហ៊ូសេន នៅឯអង្គការសហប្រជាជាតិ ក៏មានព័ត៌មានជាប្រវត្តិសាស្ត្រមួយដែរ គឺការផ្តោតសំខាន់ទៅលើរបប ប៉ុល ពត ។ ខ្មែរក្រហមបានសម្លាប់ប្រជាជន កម្ពុជាអស់រយៈពេលមួយភាគបួននៃសតវត្សរ៍កន្លងទៅហើយ ។

នៅក្នុងការបោះឆ្នោតកាលពីថ្ងៃពុធ ទី១៩ ខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិបានចាត់តាំងមន្ត្រីអង្គការសហប្រជាជាតិឲ្យចរចាសាជាថ្មីជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ការបោះឆ្នោតមិនកើតមានឡើងដោយងាយៗនោះឡើយកាលពីពេលមុន ។ ប៉ុន្តែក្រោមការដឹកនាំរបស់ប្រទេសបារាំងនិងប្រទេសជប៉ុន ព្រមទាំងការគាំទ្ររបស់សហរដ្ឋអាមេរិកនិងរដ្ឋាភិបាលផ្សេងៗទៀត មហាសន្និបាតអង្គការសហប្រជាជាតិបានប្រើកម្លាំងជំរុញលើបញ្ហានេះ ។ ប៉ុន្តែការដែលថាមានរដ្ឋាភិបាលចំនួន៣០សម្រេចចិត្តធ្វើអនុបវាទនោះ បង្ហាញឲ្យឃើញថា កិច្ចខិតខំប្រឹងប្រែងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសគឺអាចជួបបញ្ហាមួយចំនួននៅពេលខាងមុខ ។ ជាការគួរឲ្យសោកស្តាយដែលថា ការបោះឆ្នោតជាកត្តាដែលត្រូវបញ្ចូលក្នុងការវិនិច្ឆ័យ ។ កាលពីខែកុម្ភៈកន្លងមកអង្គការសហប្រជាជាតិបានបញ្ចប់កិច្ចចរចាជាមួយកម្ពុជា ។ ភាគីទាំងសងខាងបានធ្វើសម្បទានសំខាន់ៗទៅវិញទៅមក ហើយជាលទ្ធផលកម្ពុជាបានអនុម័តច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការទីក្រុងភ្នំពេញដើម្បីស៊ើបអង្កេតនិងកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែលនៅរស់និងជាមេគំនិតធ្វើឲ្យប្រជាជនកម្ពុជាស្លាប់អស់ប្រមាណមួយលានប្រាំពីរសែននាក់ ។ ប៉ុន្តែការមិនទុកចិត្តគ្នារវាងក្រុមចរចាទាំងសងខាង រួមជាមួយនឹងសម្ពាធដ៏ខ្លាំងក្លាពីសំណាក់អ្នកគាំទ្រសិទ្ធិមនុស្សដែលរិះរកគ្រប់មធ្យោបាយប្រកបដោយភាពមិនប្រាកដប្រជា ក្នុងការដាក់គំនិតរបស់ខ្លួនស្តីពីបទដ្ឋានច្បាប់ទៅលើដំណើរការជម្រះរឿងក្តី ប្រការទាំងអស់នេះបានជំរុញឲ្យអង្គការសហប្រជាជាតិសម្រេចចិត្តដើរចេញពីការចរចា ។ អ្វីដែលអ្នករិះគន់ទាំងនេះមិនបានគិតដល់គឺថាតើអ្នកចរចាទាំងសងខាងបានខិតចូលជិតគ្នាដល់កម្រិតណាហើយដើម្បីឈានទៅសម្រេចកិច្ចព្រមព្រៀងមួយពិតប្រាកដនោះ ។ ការចរចាដ៏លំបាកលំបិនជាមួយរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមពីឆ្នាំ១៩៩៧ ហើយបន្តរហូតដល់ក្រោយការស្លាប់ដែលប្រកបដោយមន្ទិលសង្ស័យរបស់ ប៉ុល ពត នៅតាមព្រំដែនថៃ-កម្ពុជានាឆ្នាំ១៩៩៨ ។ ឧបសគ្គធំៗមួយចំនួនត្រូវបានជម្រះរួចហើយ ។ ប្រសិនបើគិតពីបញ្ហាទម្លាក់គ្រាប់បែកជាសម្ងាត់របស់រដ្ឋការលោកនិចសុន មកលើប្រទេសកម្ពុជានៅក្នុងសង្គ្រាមវៀតណាម និងឯកសារសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជាខ្លួនឯងនៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយឃើញថា អ្នកចរចាបានឈានដល់កិច្ចព្រមព្រៀងដ៏មាំទាំមួយដែលថា ការផ្តោតសំខាន់របស់តុលាការគឺសំដៅតែទៅលើមេដឹកនាំខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយរបប ប៉ុល ពត ពីឆ្នាំ១៩៧៥ - ១៩៧៩ប៉ុណ្ណោះ ។

អ្នកចរចាបានយល់ស្របគ្នាទៅលើការចូលរួមយ៉ាងសំខាន់ពីអន្តរជាតិនៅក្នុងតុលាការកម្ពុជាថ្មីគ្រប់ថ្នាក់ដែលនឹងត្រូវបង្កើតឡើងជាពិសេសសម្រាប់បម្រើគោលដៅនេះ ។ សហព្រះរាជអាជ្ញានិងសហចៅក្រមអន្តរជាតិ ព្រមទាំងចៅក្រមបរទេស នឹងត្រូវតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សហព្រះរាជអាជ្ញាអន្តរជាតិមានអំណាចចោទប្រកាន់ ។ រាល់សេចក្តីសម្រេចតាមផ្លូវតុលាការតម្រូវឲ្យមានការឯកភាពយ៉ាងហោចណាស់ពីចៅក្រមអន្តរជាតិម្នាក់ដែរ ។

ឥឡូវនេះនៅពេលដែលការបោះឆ្នោតរបស់មហាសន្និបាតអង្គការសហប្រជាជាតិបានកើតឡើងហើយនោះ វាជាការសំខាន់ណាស់ថា គម្រោងការនេះគួរតែចាប់ផ្តើមសាឡើងវិញឲ្យបានឆាប់បំផុត ។ ប្រសិនបើមេដឹកនាំខ្មែរក្រហមមិនត្រូវបាននាំយកមកកាត់ទោសចំពោះមុខតុលាការនោះទេ ប្រជាជនកម្ពុជានៅតែបន្តរស់នៅក្រោមភាពអយុត្តិធម៌ជារៀងរហូត ។ សូម្បីតែមកដល់ថ្ងៃនេះក្តីកិច្ចខិតខំប្រឹងប្រែងក្នុងការទ្រទ្រង់ច្បាប់ឲ្យមានប្រសិទ្ធភាពនៅកម្ពុជា ត្រូវបានប៉ះពាល់ដោយគំរូដិតដាមរបស់មេដឹកនាំខ្មែរក្រហមដែលមានវ័យកាន់តែចាស់ និងរស់នៅក្នុងប្រទេសកម្ពុជា រត់គេចពីយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តក្នុងទំហំមួយដ៏គួរឲ្យព្រឺព្រួច ។ និរទណ្ឌភាពដែលបន្តអូសបន្លាយនៅកម្ពុជាក៏នឹងធ្វើឲ្យអន្តរាយដល់ដល់ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិចំពោះយុត្តិធម៌ពិភពលោកដែរ ។

បញ្ហាមួយចំនួនដែលធ្វើឲ្យការចរចាត្រូវបរាជ័យ មិនត្រូវបណ្តោយឲ្យមានរូបរាងជាថ្មីទៀតឡើយ ។ បញ្ហាវិលទៅវិលមកអំពីបញ្ហាច្បាប់ បញ្ហាលើកលែងទោស និង ឥទ្ធិពលរបស់អង្គការសហប្រជាជាតិ ត្រូវបានដោះស្រាយរួចរាល់អស់ហើយ ។ សេចក្តីអំពាវនាវរបស់សកម្មជនសិទ្ធិមនុស្ស សុំឲ្យចាត់តាំងដោយអង្គការសហប្រជាជាតិនូវតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសកម្ពុជា ដែលជាទ្រឹស្តីមួយដែលបានរកឃើញនិងបដិសេធជាយូរណាស់មកហើយនោះ ព្រមទាំងការទទូចហើយទទូចទៀតចង់បានយុត្តិធម៌មួយដែលស៊ើរតែឥតខ្ចោះនោះ គឺមិនខុសអ្វីទៅនឹងការប្រថុយប្រថានបាត់បង់ផលប្រយោជន៍ដែលទទួលបាននោះទេ ។

ការធានាជាលក្ខណៈអន្តរជាតិនឹងជួយធានាដល់យុត្តិធម៌នៅកម្ពុជាដែលគួរឲ្យជឿទុកចិត្តបាន ។ រដ្ឋាភិបាលដែលមានចំណាប់អារម្មណ៍អាចបង្កឲ្យមានគណៈកម្មការមួយសម្រាប់ត្រួតពិនិត្យ ។ ប្រការទាំងនោះនឹងចាំបាច់ត្រូវផ្តល់ថវិកាបន្តិចបន្តួចសម្រាប់ដំណើរការតុលាការ ពិសេសដើម្បីឲ្យតុលាការនេះប្រតិបត្តិទៅតាមទម្រង់ជាអាជីពច្បាស់លាស់ និងដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា ។ ចំណែកឯអង្គការសហប្រជាជាតិវិញ អាចដកខ្លួនថយមិនចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការនេះ ប្រសិនបើឧទាហរណ៍ថាមានអំពើពុករលួយ ឬមានការរំលោភសិទ្ធិ ។

ក្រោយពី២០ឆ្នាំបានកន្លងផុតទៅ មេដឹកនាំខ្មែរក្រហមជិតដល់ថ្ងៃឡើងតុលាការមួយដែលមានលក្ខណៈចំហនិងអាចជឿទុកចិត្តបាន ។ ប្រសិនបើអ្នកគាំទ្រយុត្តិធម៌អន្តរជាតិជួយមេដឹកនាំខ្មែរក្រហមឲ្យរួចផុតពីសំណាញ់ច្បាប់នោះ តើវាគួរឲ្យខ្មោចផ្សាយ៉ាងណាទៅ! ។

**ដេវីដ សែហ្វ័រ**

## ពាក្យស្លោកខ្មែរក្រហម

◆ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់និងក្តៅគគុកជាប់ជានិច្ច ដើម្បីការពារគ្រប់ផ្នែកជាមុន លើគ្រប់ឧបាយកលពិសពុលរបស់ខ្មាំង។

◆ តម្កល់ឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពដែនដី និងកិត្តិយសជាតិ ឱ្យខ្ពស់ជាងអ្វីៗទាំងអស់។

◆ កម្ចាត់ជាច់ខាតយួនឈ្លានពានវាតទីលេបទឹកដី ឱ្យវិនាសអន្តរធានពីទឹកដីកម្ពុជាជារៀងរហូត។

◆ បុគ្គលម្នាក់ៗ អង្គភាពនីមួយៗ ប្រទេសទាំងមូល ត្រូវរៀនសូត្រឱ្យបានល្អតាមគំរូវីរភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់របស់សមរភូមិមុខ។

(សៀវភៅកំណត់ហេតុលេខ ០៧៦)

◆ កែប្រែបច្ចេកទេស បង្កបង្កើនផល ខាងទឹក ដី ជី ពូជដាំដុះ និងខាងថែរក្សាឱ្យបានចម្រើនជាប់ជានិច្ច។

◆ កម្ចាត់ការខ្ជះខ្ជាយ កសាងគោលជំហរសន្សំសំចៃកម្រិតខ្ពស់ជាច់ខាត។

◆ ការពារពង្រឹងពង្រីករដ្ឋអំណាចបដិវត្តន៍ និងការផ្តាច់ការបដិវត្តន៍ជាច់ខាត។

(សៀវភៅកំណត់ហេតុលេខ១៣៥ កណហ)

◆ ត្រូវមានស្មារតីរក្សាការសម្ងាត់ខ្ពស់។

(សៀវភៅកំណត់ហេតុ អ៊ីវ)

# មេធាវី តាម៉ុក ប្រកាស

ប្រធានក្រុមមេធាវី លោក បែនសុន សម័យ ការពារជនជាប់ចោទឈ្មោះ អ៊ុង ជឿន ហៅ តាម៉ុក សូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចកម្ពុជានិងស្នងការខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស សូមអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនបាននៅក្រៅឃុំជាបណ្តោះអាសន្ន ដោយឈរលើមូលដ្ឋានសុខភាព សិទ្ធិមនុស្ស និង មនុស្សធម៌ ។

អ៊ុង ជឿន ត្រូវបានចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា២ ក្រឹត្យច្បាប់លេខ០១ ចុះថ្ងៃទី១៥ កក្កដា ១៩៧៩ និង មាត្រា៩និង៣៩ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានឃុំខ្លួននៅតុលាការយោធា តាមដីកាឃុំខ្លួនលេខ១៥/២០០២ ដក, ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ ។

បច្ចុប្បន្ននេះ អ៊ុង ជឿន ហៅ តាម៉ុក នឹងគម្រប់អាយុ៧៧ ឆ្នាំ នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៣ នេះ (តាម៉ុក កើតនៅថ្ងៃទី៧ រោជ ខែបុស្ស ព.ស២៤៦៩ ត្រូវនឹងថ្ងៃអង្គារ ខែមករា ឆ្នាំ ១៩២៦) សព្វថ្ងៃ គាត់មានសុខភាពទ្រុឌទ្រោមយ៉ាងខ្លាំង ដែលទាមទារឲ្យមានការព្យាបាលជិតដល់នៅទីកន្លែងសមរម្យមួយដែលមានអំណោយផលទាំងសុខភាពរាងកាយទាំងផ្លូវចិត្តផង ដូចដែលមេធាវីរបស់ជនជាប់ចោទបានធ្វើសំណូមពរជាច្រើនលើកច្រើនសាមកហើយ ។

ដោយពិនិត្យឃើញថា ការរៀបចំតុលាការមួយដើម្បីធ្វើការកាត់ទោសតាមច្បាប់ដែលចោទប្រកាន់ដល់ការប្រព្រឹត្តិរបស់ថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅមិនទាន់បានដំណើរការនៅឡើយ ហើយអាចអូសបន្លាយពេលវេលាទៀតផង ទោះជាអង្គការសហប្រជាជាតិបានសម្រេចរៀបចំឡើងវិញរវាងភាគីនានានោះក៏ដោយ ក៏ត្រូវប្រើពេលវេលាយូរដែរ ។ ដូច្នេះ ខ្ញុំអំពាវនាវសូមការអនុញ្ញាតឲ្យឈ្មោះ អ៊ុង ជឿន ហៅ តាម៉ុក បានស្ថិតនៅក្រៅឃុំជាបណ្តោះអាសន្ន ដើម្បីធ្វើការព្យាបាលខ្លួន ហើយនឹងចូលខ្លួននៅពេលណាដែលមានដីកាកោះហៅពីតុលាការ ។

ការិយាល័យមេធាវីយើងខ្ញុំសូមបញ្ជាក់ថា យោងតាមស្មារតីនៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនាឆ្នាំ ១៩៤៨ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដែលត្រូវបានចុះហត្ថលេខាដោយឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា (SNC) ហើយដែលត្រូវប្រកាសទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ពិសេសនៅក្នុងជំពូកទីពីររបស់ខ្លួននោះ ជនជាប់ចោទឈ្មោះ អ៊ុង ជឿន ត្រូវតែទទួលបាននូវកិច្ចការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូរ ដូចពលរដ្ឋឯទៀតដែរ ។ ក្នុងគោលគំនិតនេះ ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរទេនោះ បុគ្គលឈ្មោះ អ៊ុង ជឿន នេះ ត្រូវតែទទួលនូវការថែទាំបីបាច់ក្នុងស្ថានភាពមួយសមរម្យដូចពលរដ្ឋដទៃទៀតដែរ ។

ការបន្តឃុំខ្លួនឈ្មោះ អ៊ុង ជឿន ដោយឥតគិតដល់ស្ថានភាពអាយុជីវិត សុខភាព និងសិទ្ធិពលរដ្ឋមួយដែលជនជាប់ចោទត្រូវតែមានសិទ្ធិទទួលបានដូចជាពលរដ្ឋកម្ពុជាឯទៀតនោះ គឺជាការផ្ទុយនឹងច្បាប់ ផ្ទុយនឹងស្មារតីមនុស្សជាតិទាំងអស់ ។ មិនតែប៉ុណ្ណោះ ការបន្តឃុំខ្លួនបែបនេះ មិនខុសអ្វីពីការប្រើអំពើអសីលធម៌ទល់នឹងអសីលធម៌ដែលជាទង្វើផ្ទុយស្រឡះនឹងស្មារតីនីតិរដ្ឋ និងស្មារតីស្វែងរកយុត្តិធម៌នៃអារ្យប្រទេសនោះឡើយ ។

បែនសុន សម័យ បន្ថែមទៀតថា តាម៉ុក និយាយថា "ពិភពលោកបានផ្សព្វផ្សាយជាទូទៅ ដោយចោទទៅលើរូបគាត់ថាជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់ប្រជាពលរដ្ឋខ្មែរពីរលាននាក់ ក៏ប៉ុន្តែអង្គការសហប្រជាជាតិ និងអង្គការសិទ្ធិមនុស្ស ពុំបានស៊ើបអង្កេតពីប្រទេសទាំងឡាយដែលជាអ្នកគាំទ្រដល់របបខ្មែរក្រហម

នាម័យនោះទេ ។ ហើយក៏ដោយសារមានការគាំទ្រពីប្រទេសមួយចំនួន និងអង្គការសហប្រជាជាតិដែរ ទើបរបបខ្មែរក្រហមអាចមានដំណើរការទៅបាន ។ ហើយឥឡូវនេះប្រទេសជឿនលឿនខាងលិចនេះ បែរជាស្នើសុំឲ្យធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅវិញ" ។ តាម៉ុក និយាយថា "ពលរដ្ឋក្នុងពិភពលោក



តាម៉ុក

នឹងដឹងរឿងពិតថ្ងៃណាមួយ នៅពេលណាមានពន្លឺស្រឡះក្រោយពីសូរ្យគ្រាសលែងបាំងព្រះអាទិត្យ ហើយខ្ញុំជឿជាក់ថា នៅពេលនោះមុខតែពលរដ្ឋគ្រប់រូបមានការភ្ញាក់ផ្អើលមិនខានឡើយ" ។ ដល់ថ្ងៃទី៩ មករា ២០០៣ គាត់គម្រប់អាយុ៧៧ឆ្នាំ នៅថ្ងៃខួបកំណើតនេះ តាម៉ុក សុំវិទ្យុតូចមួយ ។

តាម៉ុក បន្តថា នៅក្នុងពេលសង្គ្រាម ជនរងគ្រោះស្លូតត្រង់ត្រូវបានគេសម្លាប់ដោយវង្កាល ឧទាហរណ៍ ដូចជាជនជាតិអាហ្វហ្គានីស្ថាន ត្រូវបានទទួលរងគ្រោះដោយការទម្លាក់គ្រាប់បែកសម្លាប់ជនស៊ីវិលរាប់ពាន់នាក់ដោយសហរដ្ឋអាមេរិក ។ តើកងទ័ពសហរដ្ឋអាមេរិកនោះត្រូវបានគេធ្វើការកាត់ទោសពីឧក្រិដ្ឋកម្មសង្គ្រាមដែរឬទេ ។ ហេតុអ្វីបានជាគ្មានការកាត់ទោសពួកគេដូច្នេះ? តើលោកអាចបញ្ជាក់នូវការកាប់សម្លាប់នោះដោយមិនមានការគ្រោងទុក ឬដោយអចេតនាយ៉ាងណា? តើពួកគេអាចនិយាយថា វាគ្រាន់តែជាការខុសឆ្គងមួយតូចហើយអាចសុំទោសចំពោះកំហុសនោះ ។ តើរូបគាត់(តាម៉ុក) អាចមានភ័ព្វវាសនាការសុំលើកលែងទោសយ៉ាងដូច្នេះបានដែរឬទេ? ពិសេសទៅទៀត ពេលនេះសហរដ្ឋអាមេរិកប្រកាសទម្លាក់គ្រាប់បែកទៅលើបូរណភាពទឹកដីប្រទេសអ៊ីរ៉ាក់ តើសហរដ្ឋអាមេរិកអាចស្មានបានទេ តើថាជនស៊ីវិលនិងកុមារត្រូវរងគ្រោះយ៉ាងណា តើគេអាចចោទថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានដែរឬទេ?" ។

តាម៉ុក បានអះអាងថាគាត់គ្មានទោសទេ ហើយគាត់មិនបានគ្រប់គ្រងផ្ទាល់និងទទួលខុសត្រូវរាល់មេទាហានទាំងអស់នោះឡើយ ពីព្រោះពួកគេជាច្រើនធ្វើប្រតិបត្តិការដោយឡែកពីគ្នានៅតំបន់ដាច់ស្រយាលផ្សេងគ្នា ហើយកាលនោះក៏វាគ្មានប្រព័ន្ធទាក់ទងគ្នាបានទេ ។ បញ្ហាសំខាន់គឺថា "តើនរណាជាអ្នកចេញបញ្ជា ហើយអ្នកណាជាអ្នកអនុវត្តបញ្ជា និង តើអ្នកណានៅពីក្រោយនិងគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យនោះ គេមិនអាចទម្លាក់កំហុសទៅលើនាយទាហានជាន់ខ្ពស់នៅក្នុងសម័យខ្មែរក្រហមបានទេ ពីព្រោះពួកគេគ្មានអំណាច និងពុំអាចច្បាំងតទល់នឹងសត្រូវណាទេ ហើយជំនាន់ខ្មែរក្រហម ទាហានមានភារកិច្ចបង្កបង្កើនផល សាងសង់ថ្នល់និងស្ពានប៉ុណ្ណោះ ។

តាម៉ុក និយាយថា "ពលរដ្ឋពិភពលោកទាំងអស់នឹងជ្រាបពីឆាកល្ខោនសោកនាដកម្មនៃប្រវត្តិសាស្ត្រខ្មែរនេះ ហើយពួកគេគ្រប់ៗគ្នានឹងបានដឹងថាតើអ្នកណាខ្លះដែលពាក់ព័ន្ធទៅនឹងខ្មែរក្រហមនេះ" ។ តាម៉ុក បានស្នើថា "ដោះលែងខ្ញុំឲ្យនៅក្រៅឃុំស្របច្បាប់ស្តីពីសិទ្ធិមនុស្ស ឬរកការពិតដល់ខ្ញុំ" នេះជាការបញ្ជាក់និងការអំពាវនាវចុងក្រោយរបស់ តាម៉ុក ។

មេធាវីការពារជនជាប់ចោទសូមអះអាងថា កូនក្តីរបស់ខ្លួននៅតែត្រៀមខ្លួនជានិច្ចនឹងចូលខ្លួនមកបំភ្លឺតុលាការនៅគ្រប់ពេលវេលា ដោយឥតមានគេចវេះឡើយ ។

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២

# អ្វីដែលប៉ាត្រូវការគឺ សន្តិភាព

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រទេសកម្ពុជាមានសង្គ្រាមស៊ីវិលរវាងកងទ័ពខ្មែរក្រហមជាមួយនិងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅក្នុងប្រទេសពោរពេញទៅដោយភាពអស្ថិរភាព ។ ជារឿយៗមានពត៌មានអំពីការផ្ទុះគ្រាប់បែកតាមទីប្រជុំជននានា នៅក្នុងទីក្រុងភ្នំពេញហើយច្រើនបំផុតនៅអំឡុងពេលបុណ្យជាតិ ។ ខ្ញុំធ្លាប់បានឮសំឡេងគ្រាប់បែកផ្ទុះនៅក្បែរផ្ទះរបស់ខ្ញុំ ។ រឿងរ៉ាវទាំងនេះ ធ្វើឲ្យខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ។ ខ្ញុំតែងតែយល់សប្តិជាញឹកញាប់ ឃើញរបបខ្មែរក្រហមវិលមកវិញជាថ្មីម្តងទៀត ទោះបីជាខ្ញុំមិនដឹងថាតើរបបខ្មែរក្រហមនោះមានទិដ្ឋភាពបែបណាក៏ដោយ ។ តាមការនិទានរបស់ចាស់ៗនិងមេរៀននៅក្នុងសាលា ខ្ញុំមិនដឹងថា ប្រសិនបើរបបខ្មែរក្រហមវិលត្រឡប់មកវិញ តើខ្ញុំនឹងបានរៀនទៀត ហើយបានជួបនឹងមិត្តភក្តិជាទីស្រលាញ់ ដែលតែងតែធ្វើឲ្យខ្ញុំសប្បាយចិត្តជារៀងរាល់ថ្ងៃទៀតដែរឬក៏យ៉ាងណាទេ ។ រឿងដែលធ្វើឲ្យភ័យខ្លាចបំផុតនោះគឺ ខ្ញុំប្រាកដជាត្រូវធ្វើដំណើរលើកំណាត់ផ្លូវដ៏វែងនិងគ្មានទិសដៅ អមជាមួយនិងសំឡេងអាវុធផ្ទុះខ្លាំងៗមិនខាន ព្រោះម៉ាក់ធ្លាប់ប្រាប់ថា ពេលដែលប្រទេសមានសង្គ្រាម ភាគីទាំងសងខាងនឹងប្រើកាំភ្លើងនិងគ្រាប់បែកដើម្បីដណ្តើមជ័យជម្នះរៀងៗខ្លួន ។ ខ្ញុំតែងបន់ស្រន់សូមឲ្យឆាប់ធំ ដើម្បីងាយស្រួលក្នុងការជួយខ្លួនឯង នៅពេលដែលមានការជម្លៀស ។

ការភ័យខ្លាចទាំងនេះ បានបន្លាចខ្ញុំពេញអំឡុងពេលនៃកុមារភាពរបស់ខ្ញុំ ។ នៅក្នុងយប់មួយនៃថ្ងៃចូលឆ្នាំខ្មែរ (ឆ្នាំនោះខ្ញុំរៀននៅសាលាចតុមុខ) គឺជាពេលដែលត្រូវទទួលទេវតាឆ្នាំថ្មីប្រជាជននៅក្នុងទីក្រុងភ្នំពេញបាននាំគ្នាបាញ់កាំភ្លើងដើម្បីទទួលទេវតា ។ ស្នូរកាំភ្លើងបានដាស់ខ្ញុំឲ្យភ្ញាក់ពីដំណេកដ៏ស្កប់ស្កល់ ។ ខ្ញុំភ្ញាក់លោតចុះពីលើគ្រែ ហើយស្ទុះទៅបិទបង្អួចយ៉ាងប្រញាប់ដោយភ័យខ្លាចមានគ្រាប់ខ្លាតចូល បន្ទាប់មកខ្ញុំលូនចូលក្រោមគ្រែ ព្រោះខ្ញុំយល់ច្រឡំថានេះជាស្នូរកាំភ្លើងសង្គ្រាម ។ ដោយអំណាចនៃការភ័យខ្លាច ខ្ញុំមិនអាចគេងលក់វិញឡើយ ។ នៅក្នុងយប់នោះ ម៉ាក់និងប៉ាក៏បានរំឭកឡើងវិញអំពីព្រឹត្តិការណ៍ដែលគាត់មិនអាចបំភ្លេចបាននៅក្នុងជីវិត ហើយដែលបានកើតឡើងក្នុងថ្ងៃបុណ្យចូលឆ្នាំខ្មែរកាលពីឆ្នាំ១៩៧៥ ។

ប៉ា (គីម ភឿន) មានស្រុកកំណើតនៅក្នុងខេត្តព្រះត្រពាំង (កម្ពុជាក្រោម) ចំណែកម៉ាក់ (ចិន ធីតា) មានស្រុកកំណើតនៅក្នុងខេត្តស្វាយរៀង ។ ក្រោយពីបងស្រីទីពីររបស់ខ្ញុំឈ្មោះ ច័ន្ទទេវី ចាប់កំណើតនៅក្នុងឆ្នាំ១៩៧៣ ប៉ាត្រូវបានរដ្ឋការចាត់តាំងឲ្យទៅធ្វើជាប្រធានមន្ទីរបសុពេទ្យប្រចាំខេត្តកំពង់ចាម ដែលពេលនោះហៅថា ចៅក្រសួងបសុពេទ្យខេត្តកំពង់ចាម ។ ម៉ាក់គឺជាសាស្ត្រាចារ្យម្នាក់នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក៏បានសុំផ្លាស់ទៅបង្រៀននៅវិទ្យាល័យកំពង់ចាមវិញ ។ នៅទីនោះសង្គ្រាមរវាងខ្មែរក្រហមនិងរបបសាធារណរដ្ឋខ្មែរបានធ្វើឲ្យទីក្រុងកំពង់ចាមរង្គោះរង្គើ ដោយសារស្នូរកាំភ្លើងនិងគ្រាប់បែកផ្ទុះជារៀងរាល់ថ្ងៃ ។ ប្រជាជនស៊ីវិលត្រូវស្លាប់និងរបួសជាបន្តបន្ទាប់ ។ សង្គ្រាមអូសបន្លាយពេលកាន់តែវែងធ្វើឲ្យមនុស្សស្លាប់និងរបួសកាន់តែច្រើន ហើយក៏ធ្វើឲ្យប្រជាជនធុញទ្រាន់នឹងសង្គ្រាមកាន់តែខ្លាំង ។

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ វិទ្យុបានប្រកាសឲ្យទាហានរបបសាធារណរដ្ឋខ្មែរដាក់អាវុធចុះ ហើយបញ្ឈប់ការតស៊ូ និងរៀបចំកាណូតទៅទទួលកងទ័ពខ្មែរក្រហមដែលនៅត្រើយម្ខាងទៀតនៃទន្លេចូលមកទីរួមខេត្តកំពង់ចាម ។ ក្រោយពីចូលដល់ទីរួមខេត្តកំពង់ចាមហើយ ខ្មែរក្រហមបានកោះហៅអ្នករដ្ឋការទាំងអស់ទៅចូលរួមប្រជុំ ។ ប៉ារបស់ខ្ញុំបានចូលរួមនៅក្នុងការប្រជុំនោះដែរ ។ នៅពេលដែលប៉ាត្រឡប់មកពីប្រជុំវិញ គាត់មានទឹកមុខរីករាយណាស់ ។ គាត់ទន្ទេញតែពាក្យមួយម៉ាត់គត់គឺ«សន្តិភាព» ។ ដោយសារធុញទ្រាន់នឹងសង្គ្រាមខ្លាំងពេក ប៉ារំភើបចិត្តយ៉ាងខ្លាំងនៅពេលសង្គ្រាមត្រូវបានបញ្ចប់ ទោះបីជាការបញ្ចប់នោះអាចបណ្តាលឲ្យគាត់បាត់បង់តួនាទីដ៏ល្អក៏ដោយ ។

ប៉ាសប្បាយចិត្តពេញមួយថ្ងៃ ។

ព្រឹកឡើងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តាសិន និង យាយកូវ ជាអ្នកធ្វើការនៅក្នុងផ្ទះបាននាំគ្នាទៅផ្សារ ។ មិនយូរប៉ុន្មានពួកគាត់បានត្រឡប់មកវិញប្រាប់ម៉ាក់ថា ប្រពន្ធទាហានរបបសាធារណរដ្ឋខ្មែរជាច្រើនកំពុងនាំគ្នាស្ពាយបង្វេចដើរចេញពីបន្ទាយទាហាន ហើយយំនៅតាមផ្លូវ ព្រោះប្តីរបស់គាត់ត្រូវកងទ័ពខ្មែរក្រហមចាប់បញ្ជូនចេញពីបន្ទាយទាំងអស់ ។ ប្រមាណកន្លះម៉ោងក្រោយមក មានកងទ័ពខ្មែរក្រហមពីរនាក់ដើរចូលមកក្នុងផ្ទះខ្ញុំ ហើយភ្ជង់កាំភ្លើងបញ្ជាឲ្យម៉ាក់និងប៉ារៀបចំអីវ៉ាន់ចេញពីផ្ទះក្នុងរយៈពេល១៥នាទី ដោយប្រាប់ថា អង្គការត្រូវការបោសសម្អាតខ្មាំង អង្គការនឹងឲ្យប្រជាជនចូលមករស់នៅវិញក្នុងអំឡុងបីថ្ងៃក្រោយ ។ ដោយមានការជឿជាក់បែបនេះហើយ ទើបម៉ាក់មិនបានយកទ្រព្យសម្បត្តិអ្វីទៅតាមទាំងអស់ ក្រៅពីសម្លៀកបំពាក់អង្ករនិងរបស់របរប្រើប្រាស់បន្តិចបន្តួច ។

នៅពេលនោះមានបុគ្គលិកមួយចំនួនរបស់ប៉ា មិនទាន់បានបើកប្រាក់ខែនៅឡើយ ។ ម៉ាក់និងប៉ាបានយកប្រាក់ខែបុគ្គលិកដែលនៅសល់និងបញ្ជីបើកប្រាក់ខែបុគ្គលិកជាប់ទៅជាមួយ ។ នៅតាមផ្លូវធ្វើដំណើរ ប៉ាបានបើកប្រាក់ខែឲ្យបុគ្គលិកដែលគាត់បានជួបជាបន្តបន្ទាប់ ព្រោះគាត់យល់ថា ស្ថិតនៅក្នុងស្ថានភាពជ្រួលច្របល់បែបនេះ បុគ្គលិកទាំងនោះច្បាស់ជាត្រូវការប្រាក់ដើម្បីចាយវាយមិនខាន ។ នៅល្ងាចថ្ងៃទី១៧ មេសា ពេលដែលក្រុមគ្រួសាររបស់ខ្ញុំបានធ្វើដំណើរទៅដល់ភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ទើបបានដឹងថា លុយដែលម៉ាក់និងប៉ាខំស្ពាយតាមនោះពុំអាចចាយវាយបានទៀតទេ ។ នៅភូមិចម្ការសាមសិបនេះ ជាកន្លែងដែល តាសីម និង យាយកូវ ត្រូវអង្គការបំបែកចេញពីម៉ាក់និងប៉ា ។ ចាប់តាំងពីពេលនោះមក ម៉ាក់និងប៉ាមិនដែលជួបតាយាយម្តងទៀតឡើយ ។

នៅតាមផ្លូវពេញព្រៀបទៅដោយប្រជាជនជម្លៀស ។ កងទ័ពខ្មែរក្រហមបានបាញ់ឡើងលើដើម្បីបញ្ជាឲ្យប្រជាជនធ្វើដំណើរបង្កើនល្បឿនទៅមុខ ។ គ្មាននរណាម្នាក់ដឹងថា តើខ្លួនត្រូវបញ្ជាឲ្យធ្វើដំណើរទៅទីណាឡើយ ។

ម៉ាក់និងប៉ាបានចេញដំណើរពីភូមិចម្ការសាមសិប ដោយជិះ



គីម កែវកញ្ញា និងក្រុមគ្រួសារ

ទុកនៅភូមិមហាសៀក ឃុំមហាខ្ញូង ស្រុកកោះសូទិន ។ ទៅដល់ភូមិមហាសៀក ម៉ាក់និងប៉ាត្រូវអង្គការប្រមូលឲ្យធ្វើពលកម្មជាមួយក្រុមអ្នករដ្ឋការ ។ ម៉ាក់ជាស្ត្រីតែម្នាក់គត់នៅក្នុងក្រុមនោះ ។ ថ្ងៃមួយ បងស្រីទីពីររបស់ខ្ញុំមានជំងឺ ម៉ាក់ក៏បានទៅសុំថ្នាំពីប្រធានពេទ្យយោធាម្នាក់ដែលធ្លាប់រស់នៅក្នុងស្រុកជាមួយគ្នា ។ នៅពេលដែលម៉ាក់ឲ្យបងស្រី ច័ន្ទទេវី សំពះអរគុណ ប្រធានពេទ្យយោធាម្នាក់នោះបានប្រាប់វិញថា «សម័យនេះគេលែងសំពះទៀតហើយ ហើយក៏មិនត្រូវឲ្យកូនហៅម៉ាក់បែបនេះទៀតដែរ គឺត្រូវប្តូរហៅម៉ែវិញ» ។

ក្រោយពីចេញពីផ្ទះបានពីរបុបីថ្ងៃ គឺនៅថ្ងៃទី២០ មេសា ម៉ាក់បានទាមទារត្រឡប់ទៅផ្ទះវិញ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមបានប្រាប់ថា អង្គការមិនទាន់បោសសម្អាតខ្មាំងអស់នៅឡើយ ។ កម្មាភិបាលខ្មែរក្រហមបានបដិសេធមិនឲ្យម៉ាក់និងប៉ាត្រឡប់មកផ្ទះវិញជាច្រើនដង ទើបម៉ាក់និងប៉ាដឹងថា គាត់គ្មានសង្ឃឹមថាអាចត្រឡប់មកផ្ទះវិញបានឡើយ ។ ដោយសារទឹកដីខេត្តកំពង់ចាមមិនមែនជាស្រុកកំណើត ម៉ាក់និងប៉ាបានសម្រេចចិត្តធ្វើដំណើរទៅខេត្តស្វាយរៀងដែលជាស្រុកកំណើតរបស់ម៉ាក់ ។ ពេលទៅដល់វត្តសួរ នៅក្នុងខេត្តស្វាយរៀង ម៉ាក់បានជួបអ្នកជិតខាងម្នាក់ដោយចៃដន្យ កាលពីគាត់នៅទីរួមខេត្តស្វាយរៀង ឈ្មោះ ពូង៉ូវ ។ ពូង៉ូវ បានឃាត់ម៉ាក់មិនឲ្យត្រឡប់ទៅស្រុកកំណើត ហើយណែនាំឲ្យទៅជួបតាម្នាក់ឈ្មោះ តានាង ដែលធ្វើការនៅរោងម៉ាស៊ីនស្រូវ នៅភូមិចាន់ទ្រី ឃុំចាន់ទ្រី ស្រុករមាសហែក ។ តានាង ជាអ្នកកិនស្រូវឲ្យខ្មែរក្រហម ប៉ុន្តែគាត់ជាភ្នាក់ងារសម្ងាត់របស់វៀតណាម មានតួនាទីជួយបញ្ជូនប្រជាជនវៀតណាមត្រឡប់ទៅស្រុកវិញ ។

ដោយយល់ថា ប្រទេសខ្មែរគ្មានស្ថិរភាព ប៉ាបានសម្រេចចិត្តនាំក្រុមគ្រួសារទៅស្រុកកំណើតរបស់គាត់វិញ គឺខេត្តព្រះត្រពាំង ទឹកដីកម្ពុជាក្រោម ។

តានាង បានព្យាយាមជួយម៉ាក់និងប៉ាឲ្យឆ្លងដែនទៅប្រទេសវៀតណាម ដោយយោគយល់ដល់លោកតាចិន សំ ជាឪពុករបស់ម៉ាក់ខ្ញុំដែលគាត់ធ្លាប់គោរពនិងធ្លាប់មានគុណចំពោះគាត់ ។

ម៉ាក់នៅចាំយ៉ាងច្បាស់ថា នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំបានឆ្លងផុតពីទឹកដីខ្មែរចូលដល់ខេត្តតាយនិញនៃប្រទេសវៀតណាម ។ អស់រយៈពេល៤៦ថ្ងៃគត់ ដែលម៉ាក់និងប៉ាបានចំណាយពេលវេលាដើម្បីស្វែងរកកន្លែងដែលគ្មានសង្គ្រាម ។

នៅថ្ងៃស្អែកឡើងគឺថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៥ មានរឿងមួយបានធ្វើឲ្យប៉ាភ្ញាក់ផ្អើល ។ នៅពេលដែលប៉ាយករបស់របរបន្តិចបន្តួចដែលបានដាក់តាមខ្លួនទៅលក់ដើម្បីដូរយកលុយសម្រាប់ចាយវាយក្នុងការធ្វើដំណើរទៅស្រុកកំណើត ប៉ាបានជួបយុវជនម្នាក់ ។ យុវជននោះបានបបួលប៉ាឲ្យចូលរួមក្រុមរបស់គេជាក្រុមដែលរៀបចំក្នុងបំណងបង្កជាកម្លាំងវាយដណ្តើមអំណាចពីខ្មែរក្រហម ។ ប៉ាបានសួរទាំងឆ្ងល់ថា «នៅក្នុងរបបសង្គមរាស្ត្រនិយម មានការរិះគន់ថា សម្តេច សីហនុ ដឹកនាំមិនបានល្អ ទើបលោកសេនាប្រមុខ លន់ ណុល ធ្វើរដ្ឋប្រហារ ។ នៅពេលលោកសេនាប្រមុខ លន់ ណុល ឡើងកាន់អំណាច ក៏មានការប្រឆាំងថា ជារបបពុករលួយ ទើបខ្មែរក្រហមផ្តួលរលំ ។ ពេលនេះខ្មែរក្រហមដែលកសាងភាពចលាចលក្នុងប្រទេស ទើបនឹងឡើងកាន់អំណាចមិនទាន់បានបីខែផង ស្រាប់តែមានប្រជាជនដែលមិនសប្បាយចិត្ត បានបង្កើតជាចលនាផ្តួលរំលំទៀត ។ តើប្រទេសខ្មែរនឹងមានសង្គ្រាមប៉ុន្មានលើកទៀត? តើពេលណាទើបប្រទេសខ្មែរមានអ្នកដឹកនាំដ៏ល្អនឹងគួរឲ្យទុកចិត្ត?» ។ ប៉ាបន្ថែមថា គាត់មិនចង់ឲ្យមានសង្គ្រាមទៀតឡើយ អ្វីដែលគាត់ចង់បានគឺសន្តិភាព ។

**គឹម កែវកន្និដ្ឋា**

## ពន្យល់ពាក្យខ្មែរក្រហម

**បដិវត្តន៍:** ការរំលំរបបចាស់ចោល ហើយកសាងរបបថ្មី ។

**យុត្តិធម៌:** អំពើប្រព្រឹត្តល្អត្រឹមត្រូវមិនលម្អៀងដោយគតិណាមួយទេ ។

**ប្រវត្តិសាស្ត្រ:** ស្នាដៃផ្សេងៗដែលមានពីបុរាណនៅក្នុងសង្គមដូចជាអង្គរ និងស្នាដៃរបស់វីរបុរសតស៊ូជំនាន់មុនៗ បានចងក្រងទុក ។ (សៀវភៅកំណត់ហេតុ អុីវ)

## លិខិតពីអ្នកទោសរបស់ ម៉ម ណៃ

*ខ្ញុំបានអាន «ស្វែងរកការពិត» រៀងរាល់យប់ ដែលលោកផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ។ ខ្ញុំសូមជម្រាបលោក ពេលអានខ្ញុំរំជួលក្នុងចិត្តខ្លាំងណាស់ ពេលខ្លះខ្ញុំយំទាំងមិនដឹងខ្លួន ខ្ញុំស្រមៃឃើញហេតុការណ៍ទាំងអស់ហាក់ដូចជានៅថ្មីៗ ខ្ញុំស្រមៃឃើញប៉ា ម៉ាក់ ព្រមទាំងបងប្អូនខ្ញុំស្លាប់យ៉ាងវេទនាបំផុត មិនខុសពីអ្នកទោសទួលស្លែងទេមើលទៅ ។ ម្យ៉ាងទៀត ក្នុងអ៊ីនធឺណែត ខ្ញុំបានឃើញរូបលោកគ្រូខ្ញុំ គឺលោក គីម សួរ បើមានឱកាស សូមលោកជួយផ្តល់អាស័យដ្ឋានរបស់គាត់ឲ្យខ្ញុំផង ឬបើមានលទ្ធភាពជួយជម្រាបគាត់ផងថា ខ្ញុំជាសិស្សម្នាក់របស់គាត់ក្នុងកំឡុងឆ្នាំ១៩៧០-១៩៧១ នាមដើមរបស់ខ្ញុំគឺ ថោង គីមសូរ្យតេជ បច្ចុប្បន្ននេះ ខ្ញុំដូរឈ្មោះហើយ ខាងក្រោមនេះគឺអាសយដ្ឋានរបស់ខ្ញុំ៖* KIM DET, 161 DE LUBLIN, LAVAL. P.Q H7M.4T8, CANADA ។

*ម្យ៉ាងទៀត ខ្ញុំមានមិត្តម្នាក់ធ្លាប់ជាប់ក្នុងមន្ទីរឃុំឃាំងនៅជាយដែនក្រោមការគ្រប់គ្រងរបស់ ម៉ម ណៃ ហៅ ចាន់ (សមមិត្តចាន់) ។ បើលោកយល់ថាមានប្រយោជន៍ខ្លះ ខ្ញុំនឹងផ្តល់ជូនលោកជាខ្សែអាត់ ឬជារបាយការណ៍ ខ្ញុំអាចជួយលោកបានតាមលោកត្រូវការ ។*

*ជាទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធិពរ សូមឲ្យលោកព្រមទាំងសហការីទាំងអស់មានកម្លាំងបរិបូណ៌និងជ័យជម្នះគ្រប់ទិសទី ក្នុងភារកិច្ចស្រាយបំភ្លឺភាពខ្មៅងងឹតក្នុងរបបប្រល័យពូជសាសន៍ក្នុងមាតុភូមិរបស់យើង ។ សូមឲ្យព្រលឹងនៃជនរងគ្រោះជួយជាកម្លាំង ។*

*គួរពុំគួរសូមលោកអភ័យទោស ។* *ម៉ុងរ៉េអាល់, ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១*

**បន្ថែម៖** *លោក គីម សួរ ជាសិស្សរបស់ សមមិត្ត ឌុច ក្នុងបទសម្ភាសន៍ប្រវត្តិ ឌុ, ច ។* **គីម ដេត**

## លិខិតពីអ្នកយាម តាម៉ុក

*ខ្ញុំបាទឈ្មោះ គឿន សុផល ជាទាហានរំសាយ (២៤-១១-០១) សព្វថ្ងៃរស់នៅភូមិគោករមៀត ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។*

*ក្រោយពីបញ្ចប់ជីវិតជាទាហានមក ខ្ញុំបាទមានពេលទំនេរច្រើន ។ ថ្ងៃមួយ ខ្ញុំបាទបានធ្វើដំណើរទៅលេងផ្ទះបងជីដូនមួយខ្ញុំនៅតាខ្មៅ ខេត្តកណ្ដាល ហើយខ្ញុំក៏បានឃើញទស្សនាវដ្ដីស្វែងរកការពិតចំនួន៦ច្បាប់ ក្នុងនោះមានចេញផ្សាយលេខ២៥ ខែមករា ឆ្នាំ២០០២, លេខ២៦ ខែកុម្ភៈ ឆ្នាំ២០០២, លេខ២៧ ខែមីនា ឆ្នាំ២០០២, លេខ៣០ ខែមិថុនា ឆ្នាំ២០០២, លេខ៣២ ខែសីហា ឆ្នាំ២០០២, លេខ៣៣ ខែកញ្ញា ឆ្នាំ២០០២ ។ ពេលនោះខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយក៏បានខ្ចីគាត់យកមកមើលគ្រាន់កំដរពេលទំនេរ ពីព្រោះមួយជីវិតនេះ ខ្ញុំចូលចិត្តអានកាសែតនិងទស្សនាវដ្ដីផ្សេងៗដែលនិយាយភាសាខ្មែរ ព្រោះខ្ញុំមិនចេះភាសាបរទេស ។*

*ខ្ញុំបាទសូមនិយាយថយក្រោយវិញ រយៈពេលដែលខ្ញុំធ្វើទាហាននៅស្ថាប័នអយ្យការយោធាកន្លងមក រាជរដ្ឋាភិបាលបានចាប់ខ្លួនមេទ័ពខ្មែរក្រហម តាម៉ុក និង ឌុច យកមកឃុំខ្លួនក្នុងស្ថាប័ននេះ ហើយខ្ញុំមានតួនាទីជាបុគ្គលិកយុត្តិធម៌យោធា និងជាអ្នកយាមតាម៉ុក ផ្ទាល់តែម្ដង ។ ខ្ញុំតែងតែសួរដេញដោល តាម៉ុក ជាច្រើន អំពីសម័យកាល ប៉ុល ពត កាន់អំណាច ហើយចម្លើយមានដូចក្នុងទស្សនាវដ្ដីស្វែងរកការពិតរបស់លោកចំនួន៦ច្បាប់ខ្លះៗដែរ ។ ដោយរូបខ្ញុំបាទបានចាប់កំណើតនៅឆ្នាំ១៩៦៩ ជីវិតក្នុងរបបខ្មែរក្រហមក្មេងពេក មិនយល់មិនដឹងនូវសម័យខ្មែរក្រហមកាន់អំណាច ។*

*លោកនាយកជាទីគោរពនិងជាទីរាប់អាន ខ្ញុំសូមលើកដៃទាំងពីរសំពះពីចម្ងាយថា៖ គំនិតដែលខ្ញុំសរសេរក្នុងកូនលិខិតនេះទាំងប៉ុន្មាន គឺរូបខ្ញុំបាទសូមខ្ចីទស្សនាវដ្ដីស្វែងរកការពិតដែលចេញផ្សាយហើយពីលេខ១រហូតដល់លេខ២៤ និងលេខថ្មីៗបន្តទៀតបានដែរឬទេ? ខ្ញុំសន្យាថាមិនធ្វើឲ្យបាត់បង់ រក្សាទុកជូនលោកវិញ ពីព្រោះខ្ញុំឃើញតម្លៃមួយច្បាប់៧០០០រៀល តម្លៃនេះថ្លៃណាស់សម្រាប់ជីវិតខ្ញុំជាអ្នកស្រែ ។ ខ្ញុំសូមជូនពរលោកនាយកជួបតែសេចក្ដីសុខនិងសម្រេចភារកិច្ច ។*

*សូមលោកនាយកមេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។* *គោករមៀត, ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០២*

*ពីខ្ញុំ គឿន សុផល*




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនិងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 37, January 2003.
Funded by Norway, Sweden, Switzerland, the Netherlands and USA.